សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Économiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# សារៈប្រយោជន៍សារការីក្នុងបញ្ញាសន្តិកម្មកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ ក. **រឹម លក្ខណា**
ក. **ទ៉ាន់ថា សុជាលីន**

សាស្ត្រាចារ្យណែនាំ
លោក **គាន់ សុទ្ធម៉ូលីន**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២៥ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Économiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# សារៈប្រយោជន៍សារការីក្នុងបញ្ហា សន្តតិកម្មកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ក. **រឹម លក្ខណា**

ក. **វ៉ាន់ថា សុជាលីន**

សាស្ត្រាចារ្យណែនាំ

លោក **ភាន់ សុទ្ធប៉ូលីន**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៥ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **រឹម លក្ខណា** និងឈ្មោះ **ទ៉ាន់ថា សុជាលីន** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមដឹងគុណជាអនេកកប្បការចំពោះអ្នកមានគុណទាំងទ្វេ ដែលបានផ្តល់កំណើតដល់រូបកូនៗមានថ្ងៃនេះដែលគ្មានអ្វីប្រៀបផ្ទឹមបាន និងការខិតខំបីបាច់ថែរក្សារូបកូនទាំងកម្លាំងកាយ ចិត្ត ដោយពុំខ្លាចនឿយហត់ ពិសេសនោះ គឺការផ្តល់ជាជំបូន្មាន ការជំរុញនូវទឹកចិត្តឱ្យតស៊ូក្រេបជញ្ជក់ចំណេះដឹងតាំងពីថ្នាក់បឋម រហូតដល់បច្ចុប្បន្ន និងឈានដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រនាពេលខាងមុខ។

ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់ឱកាសឱ្យយើងខ្ញុំទាំងពីរបានពង្រីកនូវចំណេះដឹងទូទៅក្នុងសាលាក៏ដូចជាផ្សព្វផ្សាយប្រធានបទខាងលើដល់អ្នកសិក្សាផ្នែកច្បាប់ តាមរយៈសារណាបញ្ចប់ការសិក្សាដ៏មានតម្លៃមួយនេះ។

ជាពិសេសសូមគោរពដល់សាស្ត្រាចារ្យណែនាំ លោក **គាន់ សុទ្ធម៉ូលីន** ដែលបានចំណាយពេលវេលាផ្ទាល់ខ្លួន ពីការងារ និងទាំងពេលវេលាក្នុងរង្វង់គ្រួសារសម្រាប់ផ្តល់ជាការណែនាំ ត្រួសត្រាយ បង្ហាញផ្លូវ រួមទាំងបង្ហាញពីចំណុចដែលត្រូវកែតម្រូវក្នុងប្រធានបទដោយមិនគិតពីការនឿយហត់អ្វីឡើយ រហូតដល់សារណាមួយនេះទទួលបានលទ្ធផលជាស្ពាពប្រកបដោយគុណភាព និងប្រសិទ្ធិភាព។

**លោក និងលោកស្រី សាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់ចំណេះដឹងដល់ការបង្ហាត់បង្រៀន ដំបូន្មានណែនាំ បទពិសោធន៍ល្អៗ ដល់យើងខ្ញុំតាំងពីថ្នាក់សិក្សាឆ្នាំមូលដ្ឋាន រហូតដល់ថ្នាក់បញ្ចប់បរិញ្ញាបត្រប្រកបដោយឧត្តមភាព និងវឌ្ឍនភាព។

**សិស្សច្បង រៀមច្បងរួមការងារ និងមិត្តនិស្សិត** ដែលបានស្និតស្នាញចំពោះការរកឯកសារ ផ្តល់ជាការណែនាំ កែតម្រូវទាំងផ្នែកអក្ខរាវិរុទ្ធ និងអត្ថន័យ ដោយឈរលើគោលការណ៍ច្បាប់ ពិសេសនោះគឺការជំរុញទឹកចិត្តប្រកបដោយភាពកក់ក្តៅចំពោះការងារមួយនេះ។

យើងខ្ញុំសូមលើកម្រាមដៃដប់ បួងសួងដល់វត្ថុសក្តិសិទ្ធិទាំងឡាយទាំងពួង អស់ទេវតា សូមចូលថែរក្សាអ្នកមានគុណទាំងទ្វេ ដែលបានបីបាច់ថែរក្សាកូនឱ្យឈានដល់ចំណុចនៃមាគ៌ាមួយនេះ និងថ្នាក់ដឹកនាំដែលបានដឹកនាំប្រទេសប្រកបដោយសន្តិភាព សុខ សុវត្ថិភាពពេញបរិបូណ៌សម្រាប់ប្រជាជាតិកម្ពុជាទាំងមូល រហូតដល់មានថ្នាលបណ្តុះចំណេះដឹងសម្រាប់និស្សិត ក្រោមការដឹកនាំដោយលោកឯកឧត្តម សាស្ត្រាចារ្យ ដែលបានជួយទំនុកបម្រុងទាំងផ្នែកសម្ភារៈ និងស្មារតី ចំពោះសារណាមួយនេះ សូមឱ្យលោកអ្នកទាំងអស់គ្នាជួបប្រទះតែសេចក្តីសុខ សំណាងល្អ ពិសេសសូមជួបតែពុទ្ធពរទាំងបួនប្រការគឺៈ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

ក្នុងអំឡុងរយៈពេល ៤ ឆ្នាំនៃការក្រេបជញ្ជក់យកចំណេះវិជ្ជានៃបរិញ្ញាបត្រនីតិសាស្ត្រ យើងខ្ញុំទាំងពីរនាក់ពិតជាបានទទួលយកនូវបទពិសោធន៍ និងទ្រឹស្តីជាច្រើនក្នុងមុខវិជ្ជាសិក្សាក៏ដូចជាកម្មវិធីផ្សេងៗ ដែលធ្វើឱ្យយើងខ្ញុំទាំងពីរនាក់មានគំនិត និងសម្បជញ្ញៈក្នុងការផ្តួចផ្តើមឱ្យមាននូវប្រធានបទមួយនេះ ទាក់ទងទៅនឹង **សារៈប្រយោជន៍សារការីក្នុងបញ្ហាសន្តតិកម្មកម្ពុជា** ដែលតាមរយៈការបង្កើតរូបរាងឡើងនូវសារណាមួយនេះ គឺជាកម្មវត្ថុក្នុងការវាស់ស្ទង់ចំណេះដឹង ក៏ដូចជាបំពេញបន្ថែមនូវតម្រូវការចាំបាច់នៃចន្លោះណាមួយក្នុងការអនុវត្តច្បាប់ ដោយផ្តើមចេញពីការខិតខំប្រឹងប្រែងពីយើងខ្ញុំទាំងពីរនាក់អស់រយៈពេលប៉ុន្មានខែកន្លងមក។ ក្នុងទឹកចិត្តមួយនៃការសរសេរគឺគ្រាន់តែសង្ឃឹមថា សារណាមួយនេះនឹងអាចជា មធ្យោបាយមួយក្នុងចំណោមវិធីនៃការទទួលយកទៅសិក្សាបន្តត្រង់ចំណុច ដែលពាក់ព័ន្ធប្រកបដោយប្រសិទ្ធិភាព។ ចំពោះប្រទេសកម្ពុជា ការសិក្សាទៅលើចំណុចនៃប្រធានបទនេះនៅមានកម្រិត និងភាពខ្វះខាតនៃឯកសារស្រាវជ្រាវក៏ដូចជាអ្នកជំនាញការបំភ្លឺឱ្យមានភាពជាក់លាក់ប្រកបដោយគតិយុត្តភាពនៅឡើយ។ ហេតុនេះហើយអាចនិយាយបានថា ការចងក្រងឡើងនូវសារណាមួយនេះ គឺពិតជាមានភាពលំបាកបន្តិច ប៉ុន្តែភាពលំបាកនេះមិននាំឱ្យការស្រាវជ្រាវនូវខ្លឹមសារសារណាមួយនេះត្រូវបង្អាក់នោះទេ។ ផ្ទុយទៅវិញ គឺជាកត្តាជំរុញទឹកចិត្តមួយផ្នែកថា អ្វីៗដែលបានមកមិនមែនកើតឡើងដោយគ្រាន់តែមានគំនិតថាចង់ធ្វើគឺបាននោះទេ តែត្រូវព្យាយាម អត់ធ្មត់ ជម្នះ បើទោះបីជាមានការលំបាក ដូច្នេះលទ្ធផល គឺជាគុណតម្លៃដែលមិនអាចកាត់ថ្លៃបាន។

ក្រឡេកមកមើល ភាពចាំបាច់ក្នុងការប្រតិបត្តិកិច្ចការដោយសារការីក្នុងសន្តតិកម្ម ពិតជាមានភាពប្រទាក់ក្រឡាគ្នាតាំងពីមានវត្តមានសារការីរហូតឈានចូលទៅដល់ដំណាក់កាលនៃការធ្វើសន្តតិកម្ម ដែលនេះជាបញ្ហាគតិយុត្តមួយចូលខ្លួនមកបង្ហើបបង្ហាញដល់អ្នកសិក្សាឱ្យបានឈ្វេងយល់។ យើងសង្កេតឃើញថា ជាគោលការណ៍គ្រឹះក្នុងការបង្កើតប្រធានបទខាងលើ យើងខ្ញុំទាំងពីរបានប្រមូលផ្តុំនូវឯកសារមួយចំនួនដែលជាភាពចាំបាច់ក្នុងការពន្លេចនូវខ្លឹមសារគួរជាទីចាប់អារម្មណ៍ពីសំណាក់អ្នកសិក្សាទាំងឡាយពិសេសជាការស្រាយនូវចម្ងល់ និងមានមន្ទិលក្នុងចង្កោមអ្នកច្បាប់។

ក្នុងនោះទៀតសោត អ្វីដែលសំខាន់ សារណាមួយនេះត្រូវបានស្រង់ចេញជាពិសេសពីក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ដែលក្រមនេះបានគោរពលើគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនបានយ៉ាងល្អបំផុត ដោយគោរពទៅលើជនម្នាក់តាំងពីបុគ្គលរូបនោះចាប់កំណើតរហូតដល់ស្លាប់បាត់បង់ជីវិត ហើយបុគ្គលនោះនៅតែអាចបង្ហាញឆន្ទៈចុងក្រោយដោយស្របទៅតាមច្បាប់។ ពិសេសមានអ្នកជួយក្នុងការដោះស្រាយបញ្ហានេះទៅតាមច្បាប់ឱ្យមានភាពរលូនទៅមុខ ដែលបុគ្គលម្នាក់នេះហើយត្រូវបានគេឱ្យឈ្មោះថា **សារការី**។ ម្យ៉ាងវិញទៀតក៏មានការដកស្រង់នូវខ្លឹមសារដែលមិនមែនជាខេមរៈភាសាយកមកពន្យល់បំភ្លឺដើម្បីឱ្យកាន់តែច្បាស់លាស់ និងជា

គោលគំនិតនៃប្រធានបទនេះផងដែរ។ ប៉ុន្តែយើងខ្ញុំបានគិត និងជឿជាក់ថាការផ្តោតទៅលើការពន្យល់ ការបកស្រាយន័យនៃប្រធានបទខាងលើនេះក៏ដូចជាការប្រើបច្ចេកសព្ទ នីតិសព្ទ លើសពីនេះទៅទៀតការបកប្រែ និងការកែសម្រួលអក្ខរាវិរុទ្ធតែងតែមានកំហុសឆ្គងដោយជៀសមិនខាន ទោះជាស្ថិតក្នុងការផ្ចិតផ្ចង់យ៉ាងណាក្តី ហេតុនេះសូមមេត្តា ខន្តី អភ័យទោសអំពីសំណាក់អ្នកអាន លោកគ្រូ អ្នកគ្រូ មិត្តភក្តិជាទីរាប់អាន និងអ្នកសិក្សាពីគ្រប់មជ្ឈដ្ឋានដើម្បីធ្វើការកែលំអក្នុងន័យស្ថាបនា ដោយយើងខ្ញុំទាំងពីរនាក់ទន្ទឹងរង់ចាំការផ្តល់ជាគំនិតក្នុងការទទួលការកែលំអំពីសំណាក់អ្នកសិក្សាគ្រប់កម្រិត ដោយក្តីសោមនស្សគ្រប់ពេលវេលាជានិច្ច។

សូមអរគុណ!!!

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............ ១

**ជំពូកទី១**

**សារការីនៅក្នុងសន្តតិកម្មកម្ពុជា**

**ផ្នែកទី១៖ សញ្ញាណទូទៅនៃវិជ្ជាជីវៈសារការីក្នុងសន្តតិកម្ម** ............ ៥

**កថាខណ្ឌទី១៖ អត្ថន័យនៃសារការីចំពោះសន្តតិកម្ម** ............ ៥

១. និយមន័យ ............ ៥

២. ប្រតិបត្តិការរបស់សារការីចំពោះសន្តតិកម្ម ............ ៥

**កថាខណ្ឌទី២៖ បច្ចុប្បន្នភាពនៃសារការីនៅកម្ពុជា** ............ ៦

១. ការបណ្តុះបណ្តាលសារការី ............ ៦

២. មន្ទីរសារការី ............ ៧

**ផ្នែកទី២៖ ការវិវត្តន៍នៃតួនាទីសារការីនៅក្នុងសន្តតិកម្ម** ............ ៨

**កថាខណ្ឌទី១៖ ប្រវត្តិនៃតួនាទីសារការីនៅក្នុងសន្តតិកម្ម** ............ ៨

១. សម័យអាណានិគមនិយមបារាំង ដល់ការចាប់ផ្តើមរបបកម្ពុជាប្រជាធិបតេយ្យ ............ ៨

២. ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ............ ១៣

**កថាខណ្ឌទី២៖ ផលប្រយោជន៍នៃការវិវត្តវត្តមានសារការីក្នុងសន្តតិកម្ម** ............ ២១

១. បញ្ហាដែលកើតឡើងជាញឹកញាប់នៅក្នុងសន្តតិកម្ម ............ ២២

២. ផលប្រយោជន៍នៃការផ្លាស់ប្តូរមន្ត្រីពីសង្គមចាស់ ទៅជាសារការីនៅក្នុងសន្តតិកម្ម ............ ២៤

**ផ្នែកទី៣៖ ទំនួលខុសត្រូវរបស់សារការី** ............ ២៥

**កថាខណ្ឌទី១៖ ភាតព្វកិច្ចសារការី** ............ ២៥

១. កាតព្វកិច្ចផ្តល់យោបល់ ............ ២៥

២. កាតព្វកិច្ចគោរពការសម្ងាត់វិជ្ជាជីវៈ ............ ២៦

**កថាខណ្ឌទី២៖ ទំនួលខុសត្រូវចំពោះកំហុសវិជ្ជាជីវៈ** .................... ២៦
១. ផ្នែករដ្ឋប្បវេណី .................... ២៦
២. ផ្នែកព្រហ្មទណ្ឌ .................... ២៦

## ជំពូកទី២

## សារៈប្រយោជន៍សារការីចំពោះសន្តតិកម្ម

**ផ្នែកទី១៖ មុខងាររបស់សារការីមុនចាប់ផ្តើមសន្តតិកម្ម** .................... ២៨
**កថាខណ្ឌទី១៖ ការផ្តល់ប្រឹក្សាផ្នែកច្បាប់** .................... ២៨
១. ការប្រឹក្សាយោបល់ .................... ២៨
២. ត្រួតពិនិត្យលក្ខណៈសម្បត្តិជនដែលមានវត្តមានក្នុងការធ្វើមតកសាសន៍ .................... ៣១
**កថាខណ្ឌទី២៖ ការថែរក្សា និងការតម្កល់មតកសាសន៍** .................... ៣៣
១. ការតម្កល់ .................... ៣៣
២. ការរក្សាទុក .................... ៣៤
**ផ្នែកទី២៖ មុខងារសារការីនៅពេលសន្តតិកម្មចាប់ផ្តើម** .................... ៣៥
**កថាខណ្ឌទី១៖ ការរៀបចំចាត់ចែងសន្តតិកម្ម** .................... ៣៥
១. ករណីសារការីជាអ្នកប្រតិបត្តិមតកសាសន៍ .................... ៣៥
១.១. ការធ្វើបញ្ជីសារពើភ័ណ្ឌ .................... ៣៥
១.២. សិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក .................... ៣៦
២. កិច្ចការដែលត្រូវបញ្ជាក់ .................... ៣៧
២.១. មតកសាសន៍ .................... ៣៧
២.២. សន្តតិជន .................... ៣៨
**កថាខណ្ឌទី២៖ មុខងារក្នុងដំណាក់កាលបែងចែក** .................... ៣៩
១. ការប្រឹក្សាយោបល់ករណីគ្មានមតកសាសន៍ .................... ៣៩

២. ការបង្កើតកិច្ចព្រមព្រៀងបែងចែកចំណែកមត៌ក ........ ៤០
**ផ្នែកទី៣៖ សារៈប្រយោជន៍ និងបញ្ហាប្រឈមការអនុវត្តមុខងារសារការីនៅក្នុងសន្តតិកម្ម** ........ ៤០
**កថាខណ្ឌទី១៖ ផលប្រយោជន៍នៃតួនាទីសារការីនៅក្នុងសន្តតិកម្ម** ........ ៤០
១. ផលប្រយោជន៍ដែលមាននៅក្នុងមតកសាសន៍ដែលបង្កើតដោយសារការី ........ ៤០
១.១. ការទទួលបានភាពជឿជាក់យ៉ាងរឹងមាំ ........ ៤០
១.២. រក្សាបាននូវប្រសិទ្ធិភាព ........ ៤១
២. ផលប្រយោជន៍ចំពោះប្រព័ន្ធសន្តតិកម្ម ........ ៤២
២.១. ចំណេញពេលវេលាដល់ភាគីក្នុងសន្តតិកម្ម ........ ៤២
២.២. ការពារជនពាក់ព័ន្ធក្នុងមត៌ក ........ ៤២
២.៣. កាត់បន្ថយនូវជម្លោះមត៌កក្នុងប្រព័ន្ធតុលាការ ........ ៤៣
**កថាខណ្ឌទី២៖ បញ្ហាប្រឈមនៃការអនុវត្តមុខងាររបស់សារការីនៅកម្ពុជា** ........ ៤៤
១. បញ្ហាប្រជាជន ........ ៤៤
២. បញ្ហាកង្វះខាតសារការី ........ ៤៥
**សេចក្តីសន្និដ្ឋាន** ........ ៤៦
**អនុសាសន៍** ........ ៤៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នៅបណ្តាប្រទេសលើសកលលោក ពោរពេញទៅដោយរឿងរ៉ាវ ដែលបានកើតឡើងសុទ្ធតែមានបែបផែនខុសៗគ្នា តែអ្វីដែលពិសេសនោះគឺត្រូវតែមានដំណោះស្រាយដែលឈរនៅលើគោលការណ៍ច្បាប់ជាធំ និងអាចអនុវត្តបានដើម្បីជាទំនុកចិត្តដល់ប្រជាពលរដ្ឋដែលបានគោរពទៅលើសុក្រឹតភាពនៃគតិច្បាប់។ ក្នុងនោះជម្លោះនៅក្នុងគ្រួសារដែលបង្កឡើងពីបញ្ហានៃការបែងចែកមត៌កតែងតែកើតមានជាញឹកញាប់នៅក្នុងសង្គមខ្មែរ ដែលពេលខ្លះបានធ្វើឱ្យបងប្អូនបង្កើតបានលើកដៃកាប់សម្លាប់គ្នាដោយសារការបែងចែកទ្រព្យរបស់ឪពុកម្តាយ ដែលបានស្លាប់ទៅ។ សកម្មភាពនៃជម្លោះនេះមិនមែនទើបតែកើតមានឡើងនោះទេ ប៉ុន្តែវាបានកើតឡើងជាយូរណាស់មកហើយ។ ដោយសារតែមានបាតុភាពបែបនេះនៅក្នុងសង្គម ទើបគេបង្កើតឱ្យមានច្បាប់ផ្សេងៗ ជាមធ្យោបាយក្នុងការជួយធ្វើយ៉ាងណា កុំឱ្យបញ្ហាដែលកើតមានកន្លងមកកើតមាននៅពេលដែលការបែងចែក មត៌ករបស់ជនដែលបានស្លាប់កើតមានម្តងហើយម្តងទៀត នៅក្នុងសង្គមដែលជាហេតុផលដែលធ្វើឱ្យមានភាពអសន្តិសុខក្នុងការរស់នៅ។ នៅក្នុងការបង្កើតឱ្យមានច្បាប់ទាក់ទងនឹងបញ្ញត្តិសន្តតិកម្មនេះទៀតសោត ត្រូវបានផ្លាស់ប្តូរទៅតាមសម័យកាលនីមួយៗ គឺស្របពេលដែលកម្ពុជាផ្លាស់ប្តូររបបគ្រប់គ្រង។ តាមរយៈការផ្លាស់ប្តូរនេះធ្វើឱ្យបញ្ញត្តិស្តីពីសន្តតិកម្មមានការប្រែប្រួល ហើយវត្តមាននៃមន្ត្រីដែលមានសមត្ថកិច្ចក្នុងការចូលរួមជួយសម្រួលនៅក្នុងបញ្ហាសន្តតិកម្មនេះក៏បានផ្លាស់ប្តូរផងដែរ។ បច្ចុប្បន្នកម្ពុជាផ្តល់តួនាទីឱ្យសារការីនៅក្នុងការជួយសម្រួលនៅក្នុងរបបសន្តតិកម្ម តាមរយៈបទបញ្ញត្តិដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ដោយសាររយៈកាលកន្លងមកសារការីពុំទាន់មានតួនាទីទេនៅក្នុងសន្តតិកម្ម ហើយស្របពេលដែលសារការីពុំមានតួនាទីនៅក្នុងសន្តតិកម្មនោះទៀតសោត គឺមានបញ្ហាជាច្រើនតែងតែបង្កជាជម្លោះនៅក្នុងរង្វង់គ្រួសារ ប៉ុន្តែបន្ទាប់ពីបានឃើញបទបញ្ញត្តិនៃច្បាប់ដែលឱ្យសារការីចូលរួមអន្តរាគមន៍នៅក្នុងសន្តតិកម្ម វាហាក់ដូចជាគន្លឹះមួយនៅក្នុងការស្វែងរកដំណោះស្រាយជូនដល់បុគ្គលទាំងឡាយដែលជាប់ពាក់ព័ន្ធនឹងសន្តតិកម្ម។ ដោយសារតែការមើលឃើញពីគន្លឹះ ដែលអាចឱ្យសន្តតិកម្មប្រព្រឹត្តទៅដោយរលូន និងគ្មានបញ្ហានេះហើយ ទើបមានប្រធានបទមួយខាងលើនេះដែលសិក្សាអំពី«**សារៈប្រយោជន៍សារការីក្នុងបញ្ហាសន្តតិកម្មកម្ពុជា**»។ ទាំងនេះសបញ្ជាក់ឱ្យឃើញថា ប្រធានបទនេះមានវត្ថុបំណងដោះស្រាយបញ្ហាដែលកើតឡើងដោយសារការបែងចែកមត៌កក៏ដូចជា ការបន្តឱ្យមានការអនុវត្តច្បាប់ទាក់ទងនឹងសន្តតិកម្មឱ្យមានភាពសុក្រឹតទៅតាមច្បាប់ជាធរមាន។ លើសពីនេះទៅទៀត ក្នុងប្រធានបទខាងលើក៏បានបង្ហាញអំពីបញ្ហាចោទចំពោះការកកើតនៃសន្តតិកម្មកម្ពុជារហូតទៅដល់មានបញ្ហាប្រឈមមួយចំនួនកើតមានឡើងហើយអ្វី ដែលសំខាន់នោះគឺមានអ្នកច្បាប់ជាសារការីជាអ្នកចូលខ្លួនមកធ្វើការដោះស្រាយប្រកបដោយយុត្តិធម៌។ ហេតុនេះទើបបង្កើតជាចម្ងល់ដល់អ្នកសិក្សាថាតើសារការីមានការអនុវត្តនីតិវិធីទៅតាម

គោលការណ៍ច្បាប់អ្វីខ្លះ ដែលអាចយោងអោយមុខងារមួយនេះមានដំណើរការរលូននៅក្នុងសន្តតិកម្ម និងទាញបាននូវសារៈប្រយោជន៍អ្វីដែលពាក់ព័ន្ធអំពីការអនុវត្តនេះដូចគ្នា?

នាពេលបច្ចុប្បន្ន បញ្ហាសន្តតិកម្មជារឿងរ៉ាវមួយដែលមានភាពស្មុគស្មាញ និងជាអ្វីដែលកំពុងប្រឈមចំពោះការដោះស្រាយ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាបាននឹងលើកឡើងនូវ លក្ខណៈសន្តតិកម្ម ថាតើត្រូវប្រគល់ភារកិច្ចនេះទៅអ្នកច្បាប់រូបណា អ្នកណាជាបុគ្គលពាក់ព័ន្ធ ហើយត្រូវតែមានផលប្រយោជន៍អ្វីខ្លះចំពោះគូភាគីនៃសន្តតិកម្ម ដែលយើងឱ្យឈ្មោះថា សន្តតិជន ជាអ្នកដែលមានជីវិតបន្តរស់នៅ និងមតកជន ជាជនដែលបានបង្ហាញឆន្ទៈចុងក្រោយនៃមតកសាសន៍។ ទាំងនេះហើយជាបញ្ហាដែលមានជាប់ទាក់ទិនគ្នា ប្រសិនបើមិនមានរបបគតិយុត្តមួយចែងច្បាស់លាស់ ក្នុងការបែងចែកឱ្យចំណែកមត៌កនេះទេ នោះវានឹងកាន់តែច្របូកច្របល់ថែមទៀត ក្នុងនោះហើយទើបប្រធានបទមួយនេះបានលើកយកនូវអ្វីដែលជាស្ថានភាពពិតៗជាក់ស្តែង និងបង្ហាញពីគោលការណ៍ច្បាប់រួមមាន ព្រះរាជក្រឹត្យលេខ ៩១០ នស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ ដែលជាបញ្ញត្តមួយកំណត់ពីមុខងារសារការី អនុក្រឹត្យមួយចំនួនដែលមានភាពពាក់ព័ន្ធក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ ដែលជាច្បាប់ក្នុងការធានាឱ្យមានការអនុវត្តក្រមប្រកបដោយភាពត្រឹមត្រូវ ប្រសិនបើមិនមានច្បាប់ទាំងនេះទេ នោះការអនុវត្តនូវគោលការណ៍ច្បាប់ពិសេសក្នុងការធ្វើសន្តតិកម្មនេះនឹងមិនមានភាពគួរឱ្យជឿជាក់បានទេ ដែលនាំឱ្យមានភាពអន់ថយជាមិនខាន។ បញ្ហាបន្តបន្ទាប់នៃ ការធ្វើសន្តតិកម្មយើងជាអ្នកសិក្សាគួរតែមានការកត់សម្គាល់ផងដែរថា ក្នុងការធ្វើសន្តតិកម្មពិតណាស់ត្រូវតែស្របទៅតាមគោលការណ៍ច្បាប់ជាធរមាន មានផលប្រយោជន៍ដល់ភាគីបែបណា ការដោះស្រាយនីតិវិធីដោយមន្ត្រីជំនាញ ទន្ទឹមនឹងនោះថាតើមានអ្វីដែលជាបញ្ហាចោទ។ ដោយសង្កេតឃើញនូវផលប្រយោជន៍នៃការអនុវត្តច្បាប់នេះ ក៏ដូចជាការលើកឡើងថានរណាជាមន្ត្រីអនុវត្តច្បាប់នេះ ហើយថាតើការធ្វើការប្រតិបត្តិនៃការងារសារការីក្នុងសន្តតិកម្មនេះមានភាពគួរឱ្យកត់សម្គាល់ និងទាញបានសារៈសំខាន់អ្វីខ្លះ? ដូច្នេះនៅក្នុងខ្លឹមសារនៃការបកស្រាយន័យនៃប្រធានបទ នឹងធ្វើការបង្ហាញដោយលើកយកនូវចំណុចសំខាន់នីមួយៗ និងដំណើរការពីមួយដំណាក់ទៅមួយដំណាក់ ដល់អ្នកសិក្សាទាំងឡាយក្នុងការងាយស្វែងយល់បន្ថែមអំពីទទ្រឹស្តីករណ៍សំខាន់ៗ និងស្របតាមវិធានច្បាប់ដែលបានអនុវត្តឱ្យកាន់តែច្បាស់លើប្រធានបទទាំងមូល។

អ្វីដែលមានភាពគួរតែមានការកត់សម្គាល់ទៅលើប្រធានបទមួយផ្នែកទៀតនោះគឺការបង្ហាញអំពីសារៈប្រយោជន៍នៃសារការីក្នុងសន្តតិកម្ម គឺមានគោលបំណងដែលត្រូវបង្ហាញដូចជា រាល់បញ្ញាត្តិដែលសារការីធ្វើក្នុងសន្តតិកម្ម គឺជាការគោរពទៅតាមគោលការណ៍នៃច្បាប់ជាធរមាន ដែលជាប្រសិទ្ធភាពនៃវប្បធម៌នៃការធ្វើបណ្តាំក៏ដូចជាការធ្វើសន្តតិកម្មតាមន័យច្បាប់នេះឯង តើមានបែបផែនយ៉ាងណាឱ្យមានភាពជឿជាក់ដល់ភាគី។ ប៉ុន្តែទាំងនេះនៅមិនទាន់គ្រប់ជ្រុងជ្រោយដែលត្រូវបកស្រាយឱ្យអស់នោះទេ ប្រសិនបើគ្មានការបញ្ជាក់នូវលិខិត

យថាភូតដោយសារការី ដែលជាលិខិតបញ្ជាក់ភាពស្របច្បាប់គន្លឹះក្នុងការរក្សាបានភាពស្ថិតស្ថេរនៃលិខិតទាំងនោះក្រោយចាត់ចែងមតកសាសន៍ដោយសារការី។ ហេតុនេះប្រធានបទនេះក៏បានបង្ហាញពីការកាត់បន្ថយនូវវិវាទក្តីក្តាំងនៅតុលាការដោយសារលិខិតដែលធ្វើឡើងដោយសារការី ក៏ព្រោះតែសារៈសំខាន់នេះហើយបានជាការពន្យល់អំពីប្រធានបទដូចខាងក្រោមនេះពិតជាសំខាន់គ្រប់បុព្វហេតុដែលលើកឡើង។ ដូច្នេះអ្នកសិក្សាក៏ដូចជាអ្នកច្បាប់ដែលកំពុងកាន់សារណានេះនៅនឹងដៃ ប្រាកដជាទទួលបានចំណេះដឹងថ្មីៗ ពីសំណេរសារណាដ៏មានសារៈសំខាន់មួយនេះ និងទទួលយកមកអនុវត្តផ្ទាល់ក្នុងសង្គម ដើម្បីប្រតិបត្តិការជាក់ស្តែងឱ្យមានប្រសិទ្ធិភាពចំពោះអ្នកវិជ្ជាជីវៈប្រកបដោយមនសិការក្នុងកិច្ចការជំរុញឱ្យមានវឌ្ឍនភាពនៃប្រទេសកម្ពុជា។គ្រប់ការបង្កើតអ្វីមួយវាតែងតែមានភាពផ្សេងៗគ្នាដើម្បីជាគន្លឹះក្នុងការបង្ហាញ រីឯការកកើតនៃសារណាមួយនេះ គឺជាសមិទ្ធផលមួយដែលផ្តើមចេញពីការស្រាវជ្រាវក្នុងប្រព័ន្ធបច្ចេកវិទ្យាដែលស្របតាមបរិបទសង្គម ក៏ដូចជាទំនើបកម្មនៃច្បាប់សព្វថ្ងៃ និងឯកសារជាផ្លូវការមួយចំនួនរបស់កម្ពុជា ក៏ដូចជាបរទេស ពិសេសនោះគឺគេហទំព័រល្បីៗនៃចំណេះដឹងផ្នែកច្បាប់ជាអាទិ៍។ នៅក្នុងការបកស្រាយអត្ថន័យនៃប្រធានបទ ក៏បានបង្ហាញពីកម្រិតនៃការវិភាគដល់អ្នកសិក្សាផងដែរ។ ដើម្បីឱ្យកាន់តែច្បាស់យើងនឹងលើកយកនូវរចនាសម្ព័ន្ធប្រធានបទដែលក្នុងនោះមានខ្លឹមសារនៃ**ជំពូកទី១៖ សារការីនៅក្នុងសន្តតិកម្មកម្ពុជា ជំពូកទី២៖ សារៈប្រយោជន៍សារការីនៅក្នុងបញ្ហាសន្តតិកម្ម**។

# ជំពូកទី១

# សារការីនៅក្នុងសន្តតិកម្មកម្ពុជា

# ជំពូកទី១
# សារការីនៅក្នុងសន្តតិកម្មកម្ពុជា

នៅក្នុងសន្តតិកម្មសារការី ទើបតែមានវត្តមាននៅពេលដែលក្រមរដ្ឋប្បវេណី២០០៧ ត្រូវបានបង្កើតឡើងប៉ុណ្ណោះ។ សារការីមានវត្តមានយូរណាស់មកហើយនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែនៅក្នុងបញ្ហាសន្តតិកម្មសារការីពុំទាន់មានមុខងារក្នុងការជួយសម្របសម្រួលបញ្ហានេះនៅឡើយទេ។ កាលដើមឡើយកម្ពុជាមិនទាន់បានចងក្រងសន្តតិកម្មជាបញ្ញត្តិច្បាប់នោះទេ។ លុះដល់ឆ្នាំ ១៩២០ បញ្ញត្តិស្តីពីសន្តតិកម្មត្រូវបានចែងជាបញ្ញត្តិច្បាប់ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនេះ។ ការកកើតជាបទបញ្ញត្តិដែលមានចែងនៅក្នុងក្រមនេះសារការីនៅពុំទាន់មានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជានៅឡើយនោះទេ ទើបតែឆ្នាំ ១៩៥៤ ទើបវិជ្ជាជីវៈមួយនេះបានកកើតឡើងនៅក្នុងប្រទេសកម្ពុជា។ តាមរយៈការបង្កើតឱ្យមានវត្តមានសារការីជាលើកដំបូងនៅក្នុងប្រទេសកម្ពុជា បានបង្ហាញអោយឃើញថាសារការីចាប់ផ្តើមមានតួនាទីនៅក្នុងការធ្វើលិខិតផ្សេងៗនៅក្នុងបទដ្ឋានគតិយុត្តរបស់ខ្មែរជាពិសេស គឺទាក់ទងនឹងលិខិតបញ្ជាក់ផ្សេងៗដែលតម្រូវឱ្យសារការីជាអ្នកបញ្ជាក់ ប៉ុន្តែចំពោះបញ្ហាសន្តតិកម្មសារការីពុំទាន់មានតួនាទីក្នុងការប្រតិបត្តិមុខងារនៅឡើយទេ ដែលកាលសម័យនោះមេឃុំដើរតួនាទីជាអ្នកអន្តរាគមន៍នៅក្នុងបញ្ហាសន្តតិកម្ម។ តាមរយៈកាលកន្លងផុតទៅទោះបីជានៅក្នុងសង្គមចាស់ និងសម័យបច្ចុប្បន្នក្តីសន្តតិកម្ម នៅតែជាបញ្ហាមួយដែលមានលក្ខណៈស្មុគស្មាញក្នុងការដោះស្រាយ ព្រោះវាជាការចាត់ចែងទ្រព្យរបស់បុគ្គលដែលបានបាត់បង់ជីវិត។ ចាប់ពីការកកើតឡើងនៃបញ្ញត្តិស្តីពីសន្តតិកម្មនៅក្នុងច្បាប់ចាស់ដំបូង និងក្រមរដ្ឋប្បវេណីថ្មី ២០០៧ ពួកយើងសង្កេតឃើញថាប្រភេទនៃសន្តតិកម្មត្រូវបានបែងចែកជាពីរប្រភេទដូចគ្នា ប៉ុន្តែអ្វីដែលមានលក្ខណៈខុសគ្នានោះវត្តមានអ្នកដែលចូលរួមអន្តរាគមន៍នៅក្នុងរបបសន្តតិកម្មបន្ថែមលើសពីនេះពួកយើងក៏សង្កេតឃើញថា បញ្ញត្តិស្តីពីសន្តតិកម្មនៅក្នុងក្រមរដ្ឋប្បវេណីថ្មី មានខ្លឹមសារជាក់លាក់ជាងក្រមរដ្ឋប្បវេណីចាស់ឆ្នាំ ១៩២០។ តាមរយៈការសិក្សាទៅលើការវិវត្តនៃច្បាប់សន្តតិកម្ម និងការវិវត្ត នៃតួនាទីសារការីតាំងពីកកើតឡើងនៅកម្ពុជារហូតមកដល់សម័យបច្ចុប្បន្ន ធ្វើឱ្យស្តែងពីសារៈប្រយោជន៍សារការីកាន់តែច្រើននៅពេលដែលមានវត្តមានសារការីជួយអន្តរាគមន៍នៅក្នុងបញ្ហាសន្តតិកម្ម ហើយការអន្តរាគមន៍របស់សារការីប្រព្រឹត្តទៅប្រកបដោយទំនួលខុសត្រូវខ្ពស់។ ដើម្បីឆ្លើយតបនឹងប្រធានបទមួយនេះ នៅក្នុងជំពូកទី ១ នេះ ពួកយើងខ្ញុំសូមធ្វើការបង្ហាញនូវបីផ្នែក ដែលផ្នែកទាំងនោះរួមមាន៖ **ផ្នែកទី១៖ សញ្ញាណទូទៅនៃវិជ្ជាជីវៈសារការីក្នុងសន្តតិកម្ម ផ្នែកទី២៖ ការវិវត្តនៃតួនាទីសារការីក្នុងសន្តតិកម្ម និង ផ្នែកទី៣៖ ទំនួលខុសត្រូវរបស់សារការី។**

# ផ្នែកទី១៖ សញ្ញាណទូទៅនៃវិជ្ជាជីវៈសារការីក្នុងសន្តតិកម្ម

## កថាខណ្ឌទី១៖ អត្ថន័យនៃសារការីចំពោះសន្តតិកម្ម

### ១. និយមន័យ

សារការី ជាអ្នកវិជ្ជាជីវៈច្បាប់ដែលអនុវត្តមុខងារក្នុងក្របខណ្ឌវិជ្ជាជីវៈសេរីនៅតាមមន្ទីរសារការីរបស់ខ្លួន ហើយសារការីជាមន្ត្រីសាធារណៈ ដែលត្រូវបានតែងតាំងឡើងដោយរដ្ឋាភិបាលកម្ពុជា និងទទួលបានសិទ្ធិអំណាចក្នុងការតាក់តែងលិខិតយថាភូត ធានាកាលបរិច្ឆេទ តម្កល់ រក្សាទុក ក៏ដូចជាការចេញសេចក្តីចម្លងយថាភូតនៃលិខិតជាអាទិ៍។ សារការី ជាអ្នកធានាសុវត្ថិភាពគតិយុត្តតាមរយៈប្រសិទ្ធិភាពនៃលិខិត និងការទទួលខុសត្រូវខ្ពស់ផ្នែកវិជ្ជាជីវៈ[1]។ ដោយសារសារការីបានទទួលប្រតិភូកម្មអំណាចសាធារណៈពីរាជរដ្ឋាភិបាលមានន័យថាលិខិតដែលធ្វើឡើងដោយសារការី គឺមានតម្លៃក្នុងការធានានូវនីត្យានុកូលភាព និងយថាភូតភាពដោយហេតុថាសារការីត្រូវបានគេចាត់ទុកជាចៅក្រមស្ម័គ្រចិត្ត ក៏ដូចជាអ្នកដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការព្រមទាំងដើរតួនាទីជាសាក្សី ប្រកបដោយសុក្រឹតភាពចំពោះកាលបរិច្ឆេទ និងអត្តសញ្ញាណរបស់បុគ្គលដែលចុះហត្ថលេខាលើកិច្ចសន្យា ម្យ៉ាងវិញទៀតផ្អែកតាមវិជ្ជាជីវៈនៅក្នុងវិស័យច្បាប់ សារការីមានជំនាញផ្នែកច្បាប់ លើវិស័យអចលនវត្ថុ ការគ្រប់គ្រងទ្រព្យសម្បត្តិ សន្តតិកម្ម គ្រួសារ និងពាណិជ្ជកម្ម។ នៅក្នុងសន្តតិកម្ម សារការី ជាអ្នកដែលមានវិជ្ជាជីវៈច្បាប់ ដែលទទួលបានអំណាចនៅក្នុងការប្រឹក្សាយោបល់ជុំវិញបញ្ហាសន្តតិកម្ម ការតាក់តែងលិខិតបណ្តាំ ការបញ្ជាក់លិខិតផ្សេងៗទៀត ដែលជាតម្រូវការនៅក្នុងសន្តតិកម្ម និង ជាអ្នកទទួលថែរក្សាតម្កល់មតកសាសន៍។ តាមរយៈតួនាទីរបស់សារការីនៅក្នុងសន្តតិកម្ម បានជួយសម្រួលបញ្ហាជាច្រើនដែលអាចកើតមានចំពោះមតកជន សន្តតិជន និងជនដទៃទៀតដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងមត៌ក។

### ២. ប្រតិបត្តិការរបស់សារការីចំពោះសន្តតិកម្ម

សន្តតិកម្មនៅក្នុងន័យនេះសំដៅទៅលើ ការចាប់ផ្តើមដោយសារមរណភាពរបស់មតកជន ហើយសន្តតិកម្មត្រូវធ្វើឡើងដោយផ្អែកលើការកំណត់របស់ច្បាប់ជាធរមានឬក៏ផ្អែកទៅលើឆន្ទៈរបស់មតកជន។ សន្តតិកម្មដែលយោងតាមឆន្ទៈរបស់មតកជន គឺជាសន្តតិកម្មតាមបណ្តាំ ចំណែកឯសន្តតិកម្មដែលផ្អែកតាមបញ្ញត្តិនៃច្បាប់ ជាសន្តតិកម្មតាមច្បាប់។ ចំពោះចំណុចនេះ ការប្រតិបត្តិការរបស់សារការី បើនិយាយឱ្យងាយយល់ សារការីអាចធ្វើបានតែចំពោះលិខិតយថាភូតដែលធ្វើឡើងដោយម្ចាស់បណ្តាំប៉ុណ្ណោះ។ ដោយហេតុថា សារការីគឺជាមន្ត្រីជំនាញផ្នែកច្បាប់ ពិសេសការធ្វើនូវរាល់លិខិតស្នាមផ្សេងៗដែលត្រូវការការអនុវត្តនូវគោលការណ៍ ក៏ដូចជា

[1] បទបង្ហាញស្តីពី វិជ្ជាជីវៈសារការី រៀបចំដោយ កញ្ញា ជឹង ស្រីតូច សិស្សសារការីជំនាន់ទី១ ធ្វើនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៦

ការបំពេញមុខងារក្នុងសន្តតិកម្មផងដែរ សារការីត្រូវប្រាប់ដល់ភាគីពាក់ព័ន្ធនូវសិទ្ធិរបស់ពួកគេ និងលំហូរនៃនីតិវិធីណាខ្លះដែលភាគីពាក់ព័ន្ធត្រូវបានដឹងអំពីបញ្ហាដែលកើតមាននៅក្នុងសន្តតិកម្មរបស់ខ្លួន។ ម្យ៉ាងវិញទៀត នៅក្នុងការប្រតិបត្តិនូវតួនាទីជាសារការីក្នុងសន្តតិកម្ម គឺមិនមានភាពខុសគ្នាប៉ុន្មានទេពីមុខងារផ្សេងៗ ក្នុងលិខិតដទៃ អ្វីដែលខុសគ្នានោះ គឺលិខិតនោះមានអានុភាពស្មើនឹងសាលក្រម ឬសាលដីកានៃសេចក្តីសម្រេចរបស់តុលាការដែលចូលជាស្ថាពរ ដោយមិនបាច់ឱ្យគូភាគីមានភាពមមាញឹកក្នុងនីតិវិធីដែលធ្វើឡើង ដោយអ្នកវិជ្ជាជីវៈដទៃនៅតុលាការ។

## កថាខណ្ឌទី២៖ បច្ចុប្បន្នភាពនៃសារការីនៅកម្ពុជា

### ១. ការបណ្តុះបណ្តាលសារការី

ដើម្បីក្លាយខ្លួនជាសារការី បេក្ខជនត្រូវបំពេញលក្ខខណ្ឌមួយចំនួនដែលត្រូវតម្រង់ខ្លួនក្លាយជាសារការីសម្រាប់អ្នកដែលចង់ក្លាយជាមន្ត្រីសារការីនៅថ្ងៃខាងមុខ ត្រូវធ្វើការស្វែងយល់បន្ថែមអំពីការណ៍ដែលក្លាយខ្លួនជាសិស្សសារការី។ ក្នុងនោះយើងឃើញថាមានការជ្រើសរើសដោយពីរវិធី៖ វិធីទីមួយ តាមរយៈកាជ្រើសរើស ឬការប្រឡងប្រជែង និងវិធីទីពីរ តាមរយៈការតែងតាំង។ តាមស្ថានភាពមួយនៃការប្រឡងប្រជែងនោះទៀតសោតតាមដែលអាចអនុវត្តបានកន្លងមកត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួនដូចជា៖ **លក្ខខណ្ឌនៃការប្រឡងប្រជែង** សាលាភូមិន្ទសារការីនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវបានបង្កើតឡើងតាមអនុក្រឹត្យ ១១៧ អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ ដែលមានតួនាទីបន្តក្នុងការបណ្តុះបណ្តាលដល់អ្នកវិជ្ជាជីវៈសារការីនេះផ្ទាល់តែម្តង។ បេក្ខជនទាំងអស់ត្រូវតែមានលក្ខណៈសម្បត្តិដូចដែលមានចែងនៅក្នុងអនុក្រឹត្យនេះ ដែលលក្ខណៈសម្បត្តិទាំងនោះរួមមាន៖ បេក្ខជនទាំងពីរភេទត្រូវមានសញ្ជាតិខ្មែរ ចំពោះបេក្ខជនជានិស្សិតត្រូវមានអាយុមិនលើសពី ៣៥ឆ្នាំ រីឯបេក្ខជនជាមន្ត្រីរាជការត្រូវមានអាយុ មិនលើសពី ៤០ឆ្នាំគិតមកត្រឹមថ្ងៃប្រឡង ត្រូវមានបរិញ្ញាបត្រនីតិសាស្ត្រឡើងទៅ ត្រូវមានលិខិតថ្កោលទោសបញ្ជាក់ថាមិនធ្លាប់មានទោសពីបទមជ្ឈឹម ឬឧក្រិដ្ឋ និងត្រូវមានកាយសម្បទាគ្រប់គ្រាន់។ ចំពោះការប្រឡងប្រជែងជ្រើសរើសសិស្សសារការីនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវបានចែកជាពីរដំណាក់កាលៈ **ដំណាក់កាលសរសេរ (វិញ្ញាសាបង្ខំ)** ដែលមានមុខវិជ្ជានីតិកាតព្វកិច្ច នីតិកិច្ចសន្យា នីតិអចលនទ្រព្យ នីតិជំនួញ និងភាសាបារាំង។ ចំណែកឯ**ដំណាក់កាលសួរផ្ទាល់មាត់ (វិញ្ញាសាជ្រើសរើស)** រួមមានមុខវិជ្ជានីតិគ្រួសារ នីតិពាណិជ្ជកម្ម នីតិអចលនទ្រព្យ និង នីតិរដ្ឋបាល។ ក្នុងនោះគេសង្កេតឃើញថា បេក្ខជនត្រូវរើសបានតែមុខវិជ្ជាមួយប៉ុណ្ណោះក្នុងការឆ្លើយទៅឱ្យគណៈមេប្រយោគ លើសពីនេះមេប្រយោគអាចមានសិទ្ធិក្នុងការសួរសំណួរបន្ថែមទៅលើបេក្ខជនផងដែរ ប្រសិនបើយល់ឃើញថាមានការចាំបាច់។ មិនត្រឹមតែប៉ុណ្ណោះ នៅក្នុងដំណាក់កាលបន្ទាប់នោះ គឺចំពោះបេក្ខជនណាដែលបានជាប់ចំ

ណាត់ថ្នាក់ក្នុងការប្រឡងប្រជែងមួយនេះ សិស្សសារការីនៃសាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការត្រូវតែឆ្លងនូវការបណ្ដុះបណ្ដាលចំនួន៣០ខែដោយមានការសិក្សាទៅលើមុខវិជ្ជាផ្សេងៗ។

**២. មន្ទីរសារការី**

មន្ទីរសារការី[2] ជាស្ថាប័នសាធារណៈ ដែលទទួលអំណាចសាធារណៈពីរាជរដ្ឋាភិបាលក្នុងការធ្វើនីត្យានុកូលកម្ម លេខាចារិក ប្រថាប់ត្រាដើម្បីកាត់បន្ថយវិវាទក្នុងរឿងក្ដីក្ដាំងទៅតុលាការដូចជា បញ្ហាដី កិច្ចសន្យាលក់ទិញ បញ្ចាំ ផ្ទេរកម្មសិទ្ធិ និងកិច្ចសន្យាជំនួញផ្សេងៗ។ បច្ចុប្បន្ននៅក្នុងព្រះរាជាណាចក្រកម្ពុជាសារការីសរុបមានចំនួន ៦១ រូប និងមានមន្ទីរសារការីមានចំនួន ១៧ ដែលមន្ទីរសារការីទាំងនោះរួមមាន៖

- ការផ្ដល់សមត្ថកិច្ចបន្ថែមជាមេធាវីសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបង្កើតឡើងនៅក្នុងឆ្នាំ២០០១
- មន្ទីរសារការី អេច.ប៊ី.អេស ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៨
- មន្ទីរសារការី សេដ្ឋាវិទូ ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១៤
- មន្ទីរសារការី វាណិជ្ជ និងសហភាតា ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៤
- មន្ទីរសារការី ខេមរា ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៥
- មន្ទីរសារការី នីតិនិវន្តន៍ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៥
- មន្ទីរសារការី ភ្នំពេញ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៥
- មន្ទីរសារការី សុក ស៊ីផាន់ណា ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៥
- មន្ទីរសារការី លុច ស៊ីអេចឌី ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៦
- មន្ទីរសារការី អេស.ខេ.វ៉ាយ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៦
- មន្ទីរសារការី សាកល ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៦
- មន្ទីរសារការី អង្គរ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៦
- មន្ទីរសារការី មេគង្គ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៧
- មន្ទីរសារការី វ៉ាយ.អ៊ែម.វី ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៧
- មន្ទីរសារការី ចតុមុខ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៧
- មន្ទីរសារការី ពាណិជ្ជ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៧
- មន្ទីរសារការី ប៊ី.អេន.អេ ដែលត្រូវបង្កើតឡើងឆ្នាំ២០១៧។

[2] សារណាបញ្ចប់ការសិក្សា សារការីនៃព្រះរាជាណាចក្រកម្ពុជា

## ផ្នែកទី២៖ ការវិវត្តន៍នៃតួនាទីសារការីនៅក្នុងសន្តតិកម្ម

### កថាខណ្ឌទី១៖ ប្រវត្តិនៃតួនាទីសារការីនៅក្នុងសន្តតិកម្ម

នៅក្នុងប្រទេសកម្ពុជាប្រវត្តិនៃសារការី និងសន្តតិកម្មមានការប្រែប្រួលខុសគ្នា រហូតទាល់តែក្រមរដ្ឋប្បវេណី២០០៧ ត្រូវបានបង្កើតឡើងទើបសារការីមានតួនាទីប្រតិបត្តិមុខងារនៅក្នុងរបបស្តីពីសន្តតិកម្ម។ ដូច្នេះដើម្បីជាភាពងាយស្រួលក្នុងការសិក្សាអំពីប្រវត្តិនៃតួនាទីសារការីនៅក្នុងសន្តតិកម្ម ជាដំបូងពួកយើងសូមធ្វើការរៀបរាប់ពីប្រវត្តិសារការី និងការវិវត្តសន្តតិកម្ម រហូតដល់ពេលដែលសារការីមានវត្តមានក្នុងការបំពេញមុខងារក្នុងសន្តតិកម្មកម្ពុជា។ បន្ទាប់មកពួកខ្ញុំក៏សូមធ្វើការបង្ហាញអំពីផលវិបាក និងសារៈប្រយោជន៍មួយចំនួនដែលកើតមាននៅក្នុងកំឡុងពេលនៃការវិវត្តនៃវត្តមានសារការីក្នុងបញ្ហាសន្តតិកម្មនេះផងដែរ។

#### ១. សម័យអាណានិគមនិយមបារាំង ដល់ការចាប់ផ្តើមរបបកម្ពុជាប្រជាធិបតេយ្យ

នៅក្នុងសតវត្សទី ៣នៃគ.ស នៅក្រោមចក្រភពរ៉ូម៉ាំង ទាហានមានតួនាទីស្រដៀងនឹងសារការីរបស់ប្រទេសបារាំង ដែលមានសមត្ថកិច្ចធ្វើកិច្ចសន្យាក្នុងនាមជារដ្ឋ។ អាណានិគមបានបញ្ចូលនូវគំនិតនេះចូលទៅក្នុងប្រទេសបារាំង។ សារការីប្រទេសបារាំង (Gaulish notaries) ចាប់ផ្តើមតាក់តែងជាឯកសារ ជាពិសេសការរៀបចំបញ្ជីដីធ្លីសម្រាប់បង្កើតមូលដ្ឋានពន្ធលើអចលនវត្ថុ។ ដោយឡែកនៅក្នុងមជ្ឈឹមសម័យ ចន្លោះពីសតវត្សទី ៥ ដល់សតវត្សទី១៥ ប្រទេសនៅមជ្ឈឹមសម័យមានការរីកចម្រើនផ្នែកពាណិជ្ជកម្ម ដែលបង្ហាញឱ្យឃើញថាវិស័យគតិយុត្ត គឺកំពុងមានភាពចាំបាច់ក៏ដូចជាបង្ហាញពីសារៈសំខាន់នៃការអនុវត្តច្បាប់យ៉ាងជាក់ច្បាស់ ហេតុនេះហើយបានជាសារការីដែលជាអ្នកប្រកបវិជ្ជាជីវៈច្បាប់ម្នាក់ៗមានសកម្មភាពយ៉ាងក្លៀវក្លាក្នុងសង្គម។ ក្នុងឆ្នាំ **១៥៣៩** ស្តេចហ្វ្រង់ស្វ័រ បានប្រកាសឱ្យប្រើបញ្ញត្តិមួយជាភាសាបារាំងដោយប្រើជាផ្លូវការនូវរាល់លិខិតទាំងអស់ ហេតុនេះហើយទើបលិខិតដែលបង្កើតឡើងដោយសារការីមានតម្លៃជាគតិយុត្ត ឬអាចនិយាយម្យ៉ាងទៀតថាជាការកកើតនៃវិជ្ជាជីវៈនេះក្នុងប្រទេសបារាំងតែម្តង ដែលរាល់លិខិតដែលធ្វើឡើងដោយសារការីមានតម្លៃស្មើនឹងសាលក្រមឬសាលដីកាដែលសម្រេចដោយតុលាការ ម្យ៉ាងរាល់លិខិតទាំងអស់នឹងមានតម្លៃលុះណាតែមានសាក្សី ហើយធ្វើនៅចំពោះមុខសារការី ដែលតម្រូវឱ្យមានហត្ថលេខាទើបអនុវត្តបានត្រឹមត្រូវតាមគតិច្បាប់ ព្រមទាំងស្ថិតនៅលើគោលការណ៍ឯករាជ្យ ស្មោះត្រង់ មិនលំអៀង និងគោរពច្បាប់ និងអ្វីដែលមិនអាចខ្វះបានទៀតនោះ គឺការប្រកបវិជ្ជាជីវៈដែលមានក្រមសីលធម៌ខ្ពស់។ លុះពេលដែលបារាំងបានដាក់អាណានិគមមកលើប្រទេសកម្ពុជា បារាំងបានបង្កើតអោយកម្ពុជាមានប្រព័ន្ធច្បាប់មួយ ដែលយកលំនាំតាមប្រទេសរបស់ខ្លួន។ ការវិវត្តនៃវត្តមានសារការីនៅកម្ពុជាត្រូវបានបែងចែកជាពីរដំណាក់កាល ដោយសារប្រទេសកម្ពុជាមានសង្គ្រាមរ៉ាំរ៉ៃ ការវិវត្តនៃសារការីត្រូវបានកាត់ផ្តាច់សញ្ញាណនៅក្នុងសម័យសង្គ្រាម (សម័យកម្ពុជាប្រជាធិបតេយ្យ) លុះដល់ពេលដែលកម្ពុជារួចផុតពីសង្គ្រាមទើបវត្តមានសារការីបានលេចឡើងម្តងទៀត និងបន្តមានរហូតមកដល់

បច្ចុប្បន្ននេះ។ ការដែលសារការីមានវត្តមានដំបូងនៅក្នុងព្រះរាជាណាចក្រកម្ពុជាដំបូង សារការីពុំមានមុខងារក្នុងសន្តតិកម្មទេ ការអនុវត្តមុខងារនៅក្នុងបញ្ញត្តិស្តីពីសន្តតិកម្មនៅក្នុងសម័យនោះ ត្រូវបានបំពេញដោយមេឃុំដោយអនុលោមតាមក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ នេះ។

ក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ ជាច្បាប់ដែលត្រូវបានបង្កើតឡើងដោយបារាំងសម្រាប់អនុវត្តនៅក្នុងប្រទេសកម្ពុជា។ មុនសម័យអាណានិគមនិយមបារាំង ប្រទេសកម្ពុជាត្រូវបានគ្រប់គ្រងដោយរបបរាជានិយម រាល់ច្បាប់សំខាន់ៗត្រូវបានបង្កើតឡើងក្រោមអំណាចរបស់ព្រះមហាក្សត្រ។ បន្ទាប់ពីប្រទេសកម្ពុជា ក្លាយជាប្រទេសដែលស្ថិតក្រោមអាណាព្យាបាលបារាំងនៅក្នុងឆ្នាំ១៨៦៣ ឥទ្ធិពលរបស់ព្រះមហាក្សត្រសោយរាជ្យក្នុងប្រទេសបានធ្លាក់ចុះបន្តិចម្តងៗ ការផ្លាស់ប្តូរក្នុងប្រព័ន្ធច្បាប់កម្ពុជាបានកើតឡើង។ រដ្ឋាភិបាលបារាំងបាននាំយកនូវប្រព័ន្ធច្បាប់ **Romano-Germanique** ចូលមកប្រទេសកម្ពុជា។ ក្រមរដ្ឋប្បវេណីប្រទេសកម្ពុជាដំបូង ផ្អែកលើច្បាប់ **Napoleon** ដែលបានប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ ១៧ ដោយព្រះមហាក្សត្រស៊ីសុវត្ថិនៅថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ១៩២០។ បន្ទាប់ពីបានចូលជាធរមានអស់រយៈពេលបួនទសវត្សរ៍ ក្រមចាស់នេះត្រូវបានកែប្រែនៅឆ្នាំ១៩៦៧[3]។ នៅពេលដែលមានវត្តមានសារការីដំបូង គឺជាពេលដែលព្រះរាជាណាចក្រកម្ពុជាស្ថិតនៅក្រោមអាណានិគមបារាំង។ ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ជាសមិទ្ធផលដែលបារាំងបានចងក្រងឡើងសម្រាប់អនុវត្តនៅកម្ពុជា។ បន្ទាប់ពីបានបង្កើតឱ្យមាននូវព្រះរាជក្រមលេខ ៩១០ នស. បទបញ្ញត្តិមួយចំនួននៅក្នុងក្រមរដ្ឋប្បវេណីបានធ្វើវិសោធនកម្មដោយព្រះរាជក្រមនេះ។ បទបញ្ញត្តិថ្មីបានបញ្ចូលនូវវត្តមានសារការីដើម្បីបំពេញកិច្ចគតិយុត្តមួយចំនួន។ មាត្រា ៩៦១ចំណុចទី២ នៃក្រមរដ្ឋប្បវេណីកម្ពុជាដែលបាននិរាករណ៍ដោយព្រះរាជក្រមនេះ បានចែងជាបញ្ញត្តិថ្មីថា (ក្រម៩១០ ន.ស.៤.១១.៥៤) ក្រៅពីលិខិតដែលបានសម្តែងហើយនៅក្នុងមាត្រា ៩៤៨និងតទៅនេះ លិខិតទាំងឡាយដូចខាងក្រោមនេះត្រូវចាត់ទុកជាលិខិតបញ្ជាក់ដែរ៖ លិខិតទាំងពួងដែលមន្ត្រីសាធារណៈបានធ្វើតាមរូបមន្តយថាភូត។ មន្ត្រីសាធារណៈ គឺចង់សំដៅលើសារការី ក្រឡាបញ្ជី ដែលរាជការបារាំងបានតែងតាំងឱ្យធ្វើជាសារការីផង ឬដែលរាជការបារាំងបានអនុញ្ញាតឱ្យធ្វើជាបណ្តោះអាសន្នក្រោយពីការផ្ទេរសមត្ថកិច្ចមកជូនរដ្ឋាភិបាលខ្មែរពេញផ្ទៃ នៃព្រះរាជាណាចក្រទំរាំមានសេចក្តីសម្រេចអំពីរឿងនេះជាថ្មីម្តងទៀត។ មុខតំណែងសារការីត្រូវបានតែងតាំង ដោយយោងតាមព្រះរាជក្រមលេខ ៩១០ នស. នេះមុនពេលដែលបានចូលបំពេញតួនាទីជាសារការី បេក្ខជននៃមុខតំណែងសារការីទាំងអស់ត្រូវមានសញ្ជាតិខ្មែរ អាយុ៣០ ឆ្នាំយ៉ាងតិច ជាពិសេសនោះបេក្ខជនត្រូវមានសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមានសញ្ញាបត្រ។ ចំពោះកម្មសិក្សាបឋមនៅក្នុងមន្ទីរសារការីសម្រាប់រយៈពេល ២ ឆ្នាំ ត្រូវបំពេញដោយបេក្ខជនដែលមានសញ្ញាបត្រ

[3] សេចក្តីផ្តើមក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជា អ្នកនិពន្ធ៖ លោកសាស្ត្រាចារ្យ Peter Backer

បរិញ្ញាបត្រ និងបណ្ឌិតទាំងអស់ដែលអាចធ្វើកម្មសិក្សានៅកម្ពុជា ឬជួនកាលអាចធ្វើនៅបារាំង[4]។ រីឯថិរវេលានៃកម្មសិក្សាប្រព្រឹត្តទៅរយៈពេល៥ ឆ្នាំចំពោះបេក្ខជនដែលមានសមត្ថភាពផ្នែកច្បាប់ ឬសញ្ញាបត្រច្បាប់សមមូល ក៏ដូចជាបេក្ខជន ដែលមានសញ្ញាបត្រពីវិទ្យាស្ថានជាតិបណ្តុះបណ្តាលច្បាប់ នយោបាយ និង សេដ្ឋកិច្ច។ ចំពោះបញ្ញត្តិជាអន្តរកាលនៃច្បាប់នេះវិញ ប្រសិនបើសម្រាប់រយៈពេលដែលមិនលើសពី ៣ ឆ្នាំគិតចាប់ពីកាលបរិច្ឆេទនៃការប្រកាសឱ្យប្រើព្រះរាជក្រមនេះ រាជរដ្ឋាភិបាលអាចតែងតាំងតំណែងសារការីមួយជីវិតដោយមិនចាំបាច់បំពេញលក្ខខណ្ឌនៃការធ្វើកម្មសិក្សា ចំពោះរាល់បេក្ខជនទាំងឡាយដែលឆ្លើយតបទៅនឹងលក្ខខណ្ឌនៃអាយុ សញ្ជាតិ និងសីលធម៌ ដែលមានចែងនៅក្នុងមាត្រា ៧នៃព្រះរាជក្រមនេះ ប្រសិនបើគាត់មាន សញ្ញាបត្រច្បាប់។ ចំណែកឯបេក្ខជន ដែលគ្រាន់តែមានសញ្ញាបត្របញ្ជាក់សមត្ថភាពច្បាប់ ឬសញ្ញាបត្រសមមូល អាចត្រូវបានតែងតាំងនូវមុខដំណែងជាសារការីសម្រាប់រយៈពេល ៥ ឆ្នាំ ប្រសិនបើគាត់បានបំពេញនូវលក្ខខណ្ឌនៃអាយុ សញ្ជាតិ និងសីលធម៌។ នៅក្រោយរយៈពេល ៥ ឆ្នាំសារការីនឹងត្រូវចាត់ទុកថាបានបំពេញនូវកាតព្វកិច្ចចុះកម្មសិក្សា ហើយអាចនឹងត្រូវតែងតាំងសម្រាប់រយៈពេលមួយជីវិតតែម្តង។ ចំពោះបេក្ខជនណា ដែលមិនមានសញ្ញាបត្រ តែបានទទួលការវាយតម្លៃថាបានបំពេញវិជ្ជាជីវៈ៥ ឆ្នាំ នៅក្នុងក្របខណ្ឌជាន់ខ្ពស់នៃរដ្ឋបាលរបស់ព្រះរាជាណាចក្រកម្ពុជា អាចត្រូវបានតែងតាំងមុខតំណែងជាសារការីសម្រាប់រយៈពេល ៥ ឆ្នាំ ដែលអាចផ្លាស់ ប្តូរជាថ្មី ប្រសិនបើគាត់បំពេញបាននូវលក្ខខណ្ឌធម្មតានៃអាយុ សញ្ជាតិ និងសីលធម៌ថែមទៀត។ សារការី អាចនឹងត្រូវបានតែងតាំងសម្រាប់រយៈពេលមួយជីវិត ប្រសិនបើគាត់មានសញ្ញាបត្រសមត្ថភាពច្បាប់ ឬសញ្ញាបត្រសមមូល ក្នុងកំឡុងពេល ៥ ឆ្នាំ នៃការតែងតាំងជាលក្ខណៈបណ្តោះអាសន្ននេះ។ ការតែងតាំងមួយជីវិត មិនអាចប្រព្រឹត្តឡើងនៅមុនពេលដែលសារការីទទួលបានការវាយតម្លៃអំពីរយៈពេល៥ឆ្នាំ ពីនាយកនៅក្នុងមន្ទីររបស់ខ្លួនឡើយ[5]។ តាមរយៈការតែងតាំងសារការីនៅសម័យនោះ បញ្ជាក់អោយឃើញថាមុនឈានទៅដល់ការទទួលតំណែងជាសារការី បេក្ខជនទាំងអស់សុទ្ធតែមានជំនាញ និងចំណេះដឹងលើវិស័យច្បាប់ក្នុងការអនុវត្ត មុខងារតាមការកំណត់របស់ច្បាប់។ បន្ទាប់ពីបានបង្កើតឱ្យមានច្បាប់ស្តីពីសារការីហើយ គេបានបង្កើតឱ្យមានលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដើម្បីឱ្យការអនុវត្តមុខងាររបស់សារការីកាន់តែមានភាពទូលំទូលាយ ក្នុងនោះគេបានបង្កើតអោយមានមន្ទីរសារការីនៅតាមបណ្តាខេត្តមួយចំនួននៅក្នុងប្រទេស ដើម្បីជាការសម្រួលតម្រូវការអោយប្រជាជននៅតាមបណ្តាលខេត្ត។ **ព្រះរាជក្រឹត្យលេខ ១២៩.ប.វ. ចុះថ្ងៃទី១៨ មីនា គ.ស.១៩៦៥** ឆ្នាំ ១៩៦៥ សម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជ ជាប្រមុខរដ្ឋ បានឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យលេខ ១២៩.ប.វ. ចុះថ្ងៃទី១៨ មីនា គ.ស.១៩៦៥ នៅក្នុងព្រះរាជក្រឹត្យនេះកំណត់អំពីចំនួនមន្ទីរសារការី និងព្រំដែនអនុវត្តរបស់មន្ទីរសារ

[4] មាត្រា ៧ នៃព្រះរាជក្រមលេខ ៩១០ នស. ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤

[5] មាត្រា ៨ នៃព្រះរាជក្រមលេខ ៩១០ នស. ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤

ការិនីមួយៗ។ តាមរយៈប្រការមួយ នៃព្រះរាជក្រឹត្យដដែលនេះមន្ទីរសារការីទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវកម្រិតឱ្យមានប្រាំកន្លែង។ បណ្ដាមន្ទីរសារការីទាំងប្រាំកន្លែងនេះ មន្ទីរសារការី ២ ត្រូវមានទីស្នាក់ការនៅទីក្រុងភ្នំពេញ ឯមន្ទីរសារការី៣ ដទៃទៀតបង្កើតនៅខេត្តបាត់ដំបង កំពត និងកំពង់ចាម។ សារការីទាំងឡាយនឹងអាចសារជាលិខិតសាធារណៈបានតែក្នុងនាទីព្រំដែននៃដែនដីដែលបានបញ្ជាក់នៅក្នុងប្រការ២ នៃព្រះរាជក្រឹត្យនេះ[6]។ ការកំណត់ព្រំដែនអនុវត្តរបស់មន្ទីរសារការីមានចែងនៅក្នុងប្រការ២ នៃអនុក្រឹត្យមានខ្លឹមសារដូចតទៅ៖

- មន្ទីរសារការី២ ដែលមានទីស្នាក់ការនៅទីក្រុងភ្នំពេញ មានសម្រាប់ព្រំដែននៃដែនដីក្នុងព្រះរាជាណាចក្រកម្ពុជា រាជធានីភ្នំពេញ ហើយនិងខេត្តកណ្ដាល។
- មន្ទីរសារការីដែលបង្កើតនៅខេត្តបាត់ដំបង១ មានព្រំដែនសម្រាប់ដែនដី ខេត្តបាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ព្រះវិហារ ពោធិ៍សាត់ និងសៀមរាប។
- មន្ទីរសារការី ដែលមានទីតាំងនៅខេត្តកំពត មានព្រំដែនសម្រាប់ដែនខេត្ត កំពត កោះកុង កំពង់ស្ពឺ តាកែវ ព្រមទាំងមណ្ឌលស្វ័យភាពនៃ ក្រុងកែប បូកគោ គិរីរម្យ ហើយនិងក្រុងព្រះសីហនុ។
- មន្ទីរសារការី ដែលកំណត់នៅខេត្តកំពង់ចាមទទួលសមត្ថកិច្ចសម្រាប់ខេត្ត កំពង់ចាម ក្រចេះ មណ្ឌលគិរី ព្រៃវែង រតនគិរី ស្ទឹងត្រែង និងស្វាយរៀង។

ចំណែកឯនៅក្នុងសន្តតិកម្មវិញ ប្រវត្តិនៃការផ្ទេរទ្រព្យសម្បត្តិរបស់បុគ្គលដែលស្លាប់ ទៅឱ្យបុគ្គលដែលមានជីវិតគឺបានកកើតមានឡើងតាំងពីយូរយារណាស់មកហើយពោលគឺមានតាំងពីសម័យហ្វូណនមកម្ល៉េះប៉ុន្តែគ្រាន់តែសញ្ញាណនៃសន្តតិកម្មនេះពុំត្រូវបានតាក់តែងឡើង ឬលើកនៅក្នុងបញ្ញត្តិនៃច្បាប់តែប៉ុណ្ណោះ។ ដោយឡែកមុនពេលសម័យអាណានិគមនិយមបារាំង ស្ដេចខ្មែរជាអ្នកគ្រប់គ្រងដីធ្លីដោយព្រះអង្គឯងពោលគឺសិទ្ធិអំណាចក្នុងការក្ដោបក្ដាប់ ដូច្នេះប្រជាពលរដ្ឋគ្មានសិទ្ធិកាន់កាប់ដីធ្លីជាកម្មសិទ្ធិផ្ទាល់ខ្លួននោះទេ ស្ដេចឱ្យអ្វីក៏ចេះតែយកទៅហើយ ស្ដេចយកអ្វីទៅវិញក៏មិនតវ៉ាអ្វីដែរ។ ដីស្រែដែលស្ដេចប្រទានឱ្យ មិនអាចយកទៅលក់ដូរបានទេ គឺត្រូវប្រគល់ឱ្យស្ដេចវិញបើមិនព្រមយកទៅបង្កបង្កើនផលទេនោះ។ ម្យ៉ាងវិញទៀតចំពោះម្ចាស់ដីស្រែ ស្លាប់ ប្រពន្ធ កូន ដែលជាអ្នកទទួលមត៌កទាំងអស់ ពោលគឺគ្មានអ្នកទទួលមត៌កទេនោះស្ដេចយកដីនោះវិញ[7]។ លុះមកដល់សម័យអាណានិគមនិយមបារាំង ប្រព័ន្ធច្បាប់បានធ្វើការផ្លាស់ប្ដូរដោយអនុវត្តតាមប្រព័ន្ធច្បាប់ប្រទេសបារាំងវិញម្ដង។ តាមរយៈ**ក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០** ជាការបង្កើតក្រមរដ្ឋប្បវេណីដំបូងរបស់ប្រទេសកម្ពុជាសញ្ញាណនៃសន្តតិកម្មត្រូវបានបញ្ចូលទៅក្នុងក្រមនេះ វាជាសញ្ញាណដំបូងនៃការចងក្រងជាច្បាប់នៃរបបសន្តតិកម្មកម្ពុជា។ គួរបញ្ជាក់ផងដែរថា តាមរយៈការចងក្រងជាច្បាប់នូវបទបញ្ញត្តិស្ដីពីសន្តតិកម្មនេះឡើង គឺក្នុងកំឡុង

[6] ប្រការ ៣ នៃព្រះរាជក្រិត្យលេខ ១២៩ .ប.រ ចុះថ្ងៃទី១៨ មីនា គ.ស.១៩៦៥

[7] សៀវភៅ សុបិន និងការពិតភាគ១ របស់លោក វ៉ាន់ឌី កាអុន ទំព័រ១៤៤

ពេលមួយដែលពុំទាន់មានវត្តមានសារការីនៅក្នុងប្រព័ន្ធច្បាប់របស់សង្គមខ្មែរនៅឡើយទេ[8]។ សារការីទើបតែមានមុខងារបំពេញតួនាទីក្នុងសន្តតិកម្មចាប់ពីពេលដែលច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីត្រូវបានដាក់ឱ្យអនុវត្តប៉ុណ្ណោះ។ នៅក្នុងកំឡុងពេលដែលពុំមានវត្តមានសារការីនៅក្នុងការបំពេញតួនាទីសន្តតិកម្ម តាមរយៈក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ ក្នុងនោះគេសង្កេតឃើញមានមន្ត្រីសាធារណៈផ្សេងទៀតដែល ជាអ្នកដែលមានសមត្ថកិច្ចក្នុងការជួយសម្របសម្រួលនៅក្នុងបញ្ហាសន្តតិកម្ម។ ក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ របបសន្តតិកម្មកម្ពុជាត្រូវបានចងក្រងទុកនៅក្នុងបញ្ញត្តិច្បាប់ ដូច្នេះការប្រព្រឹត្តទៅនៃសន្តតិកម្មត្រូវអនុលោមទៅតាមច្បាប់ថ្មីនេះ។ សន្តតិកម្មគឺជាការផ្ទេរនូវបេតិកភណ្ឌនៃបុគ្គលដែលបានស្លាប់ទៅឱ្យជនទាំងឡាយដែលនៅមានជីវិតម្នាក់ ឬច្រើននាក់ដែលជាទាយាទរបស់មតកជន។ បេតិកភណ្ឌដែលជាមត៌កចុងក្រោយរបស់មតកជន នឹងត្រូវផ្ទេរទៅឱ្យទាយាទរបស់ខ្លួនតាមពីររបៀបគឺ របៀបទីមួយជាការផ្ទេរតាមច្បាប់ និងរបៀបទីពីរសំដៅទៅលើការផ្ទេរតាមឆន្ទៈរបស់បុគ្គលដែលបានស្លាប់ទៅ។ នៅក្នុងចំណោមរបៀបផ្ទេរសន្តតិកម្មទាំងពីរនេះ មតកជនអាចធ្វើការសម្រេចដោយជ្រើសរើសរបៀបផ្ទេរណាមួយដែលខ្លួនពេញចិត្ត និងមានភាពងាយស្រួលចំពោះការផ្តល់ឱ្យទៅសន្តតិជន នៅពេលដែលខ្លួនទទួលមរណភាពទៅនោះ។ មតកជន ដែលមិនបានបង្ហាញឆន្ទៈក្នុងការផ្ទេរមត៌កនៅពេលដែលមានជីវិតទៅតាមទម្រង់នៃមតកសាសន៍ ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនោះទេ នៅពេលចាប់ផ្តើមសន្តតិកម្ម មត៌ករបស់មតកជននោះនឹងត្រូវធ្វើការចាត់ចែងផ្ទេរទៅតាមច្បាប់ ដោយអនុលោមទៅតាមបញ្ញត្តិស្តីពីសន្តតិកម្មឥតបណ្តាំ មានន័យថាម្ចាស់មត៌កមិនបានធ្វើបណ្តាំក្នុងការបង្ហាញឆន្ទៈចុងក្រោយថា ត្រូវប្រគល់មត៌កទៅឱ្យបុគ្គលណាមួយនោះទេ។ ប្រសិនបើសន្តតិកម្មមួយបានចាប់ផ្តើម ហើយជាប្រភេទសន្តតិកម្មឥតបណ្តាំ ការបែងចែកចំណែកមត៌កទាយាទម្នាក់ៗនឹងទទួលបានចំណែកតាមការកំណត់របស់ច្បាប់ ដែលមានចែងនៅក្នុងជំពូកស្តីពីសន្តតិកម្មឥតបណ្តាំ ដែលបានរៀបរាប់អំពីលំដាប់ និងចំណែកដែលទាយាទម្នាក់ៗត្រូវទទួលបាន។ ម្យ៉ាងវិញទៀតនៅក្នុងកំឡុងពេលដែលមតកជននៅមានជីវិត ប្រសិនបើមតកជនមិនពេញចិត្តចំពោះទាយាទណាមួយទេនោះ មតកជនអាចដាក់ពាក្យសុំទៅតុលាការឱ្យកាត់ផ្តាច់ទាយាទនោះចេញពីមត៌កបាននៅក្នុងការទទួលចំណែកមត៌កមានតែទាយាទ ដែលមិនត្រូវបានតុលាការកាត់សេចក្តីឱ្យទាយាទនោះក្លាយជាអភ័ព្វបុគ្គលប៉ុណ្ណោះដែលមានសិទ្ធិទទួលបានចំណែកមត៌ក[9]។ ចំណែកឯសន្តតិកម្មតាមបណ្តាំវិញ ជាការផ្ទេរចំណែកមត៌កតាមឆន្ទៈរបស់មតកជន ដូច្នេះហើយប្រសិនបើមតកជនចង់ធ្វើការបែងចែកមត៌កដោយគោរពទៅតាមឆន្ទៈផ្ទាល់របស់ខ្លួនមតកជននោះ ត្រូវតែធ្វើសំបុត្របណ្តាំដែលអាចឱ្យទាយាទយកទៅប្រតិបត្តិបាននៅពេលសន្តតិកម្មបានចាប់

[8] វត្តមានដំបូងរបស់សារការីនៅក្នុងព្រះរាជាណាចក្រកម្ពុជា កើតឡើងនៅក្នុងឆ្នាំ ១៩៥៤ តាមរយៈព្រះរាជក្រមលេខ ៩១០ នស. ចុះថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ គឺសារការីលេចវត្តមានក្រោយពេលដែលក្រមរដ្ឋប្បវេណី ១៩២០ ចូលជាធរមាន។

[9] មាត្រា ៤៩០ នៃក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ ១៩២០

ផ្ដើម។ នៅក្នុងសន្តតិកម្មមានបណ្ដាំ រាល់សំបុត្របណ្ដាំទាំងអស់ទាមទារឱ្យធ្វើទៅតាមទម្រង់ដែលច្បាប់បានកំណត់ បើពុំដូច្នោះទេ សំបុត្របណ្ដាំដែលបានបន្សល់ទុកនោះនឹងមិនត្រូវបានយកទៅអនុវត្តបានឡើយ ក្នុងពេលដែលសន្តតិកម្មចាប់ផ្ដើម។ បណ្ដាំ ឬមតកសាសន៍គឺជាសេចក្ដីដែលម្ចាស់បណ្ដាំសំដែងនូវឆន្ទៈណាមួយរបស់ខ្លួន ដើម្បីឱ្យគេយកទៅប្រតិបត្តិក្រោយពេលដែលខ្លួនស្លាប់ទៅ ហើយរាល់បណ្ដាំទាំងអស់អាចត្រូវបានបដិសេធជាដរាប[10]។ ចាប់ពីក្រមរដ្ឋប្បវេណីកម្ពុជាដំបូង បានដាក់ឱ្យអនុវត្តម្ចាស់បណ្ដាំអាចធ្វើសំបុត្របណ្ដាំបានដើម្បីទុកជាភស្តុតាងបញ្ជាក់អំពីឆន្ទៈពិតប្រាកដរបស់ខ្លួនជាមួយអាជ្ញាធរដែលមានសមត្ថកិច្ច។ សំបុត្របណ្ដាំដែលអាចឱ្យទាយាទយកទៅអនុវត្តបាន លុះត្រាតែសេចក្ដីនៅក្នុងបណ្ដាំបានធ្វើឡើងត្រឹមត្រូវតាមច្បាប់កំណត់។ សេចក្ដីបណ្ដាំ ដែលបានធ្វើឡើងដោយត្រឹមត្រូវតាមការកំណត់របស់ច្បាប់ត្រូវបានទុកជាច្បាប់ ដែលតម្រូវឱ្យមាជិកគ្រួសារទាំងអស់គោរពតាម[11]។ បណ្ដាំ អាចធ្វើជាសំបុត្របញ្ជាក់ ឬអាចធ្វើជាសំបុត្រឯកជនបាន។ បណ្ដាំដែលបានធ្វើឡើងជាសំបុត្របញ្ជាក់ មានន័យថា ម្ចាស់បណ្ដាំត្រូវប្រាប់អំពីឆន្ទៈរបស់ខ្លួនដោយផ្ទាល់មាត់ឱ្យស្មៀនសរសេរនៅចំពោះមុខមេឃុំដែលស្ថិតនៅក្នុងឃុំរបស់ខ្លួន និងសាក្សីពីរនាក់ជានីតិជន។ ចំពោះសាក្សីដែលបានចូលរួម នៅក្នុងការធ្វើលិខិតបញ្ជាក់ត្រូវតែយកបុគ្គលដែលមិនមែនជាអច្ច័យលាភី ឬទាយាទ[12]។ នៅក្នុងដំណាក់កាលនៃការតាក់តែងសំបុត្របញ្ជាក់ ម្ចាស់បណ្ដាំត្រូវប្រាប់ដោយផ្ទាល់មាត់នូវខ្លឹមសារដែលជាឆន្ទៈពិតរបស់ខ្លួន ឱ្យស្មៀនឃុំសរសេរដោយមិនមានការប្រាសចាកពីស្មារតីពិតដែលជាឆន្ទៈនៅចំពោះមុខមេឃុំ និងសាក្សីចំនួនពីររូបទៀត។ បន្ទាប់ពីបានសរសេរលិខិតបណ្ដាំហើយ មេឃុំត្រូវសូត្រខ្លឹមសារនៃលិខិតដែលស្មៀនបានសរសេរនោះឱ្យខ្លាំងៗ និងច្បាស់ៗ។ ក្រោយពីបានស្ដាប់នូវការសូត្ររបស់មេឃុំហើយម្ចាស់បណ្ដាំ និងសាក្សីត្រូវចុះហត្ថលេខាទាំងអស់គ្នានៅលើលិខិតបណ្ដាំនោះ។ ប្រសិនបើម្ចាស់បណ្ដាំ និងសាក្សីជាមនុស្សដែលមិនចេះអក្សរទេនោះ មេឃុំត្រូវចារលើសំបុត្របណ្ដាំអំពីរឿងមិនចេះអក្សរនេះផងដើម្បីឱ្យមានភាពច្បាស់លាស់ មិនត្រឹមតែប៉ុណ្ណោះ សំបុត្របណ្ដាំត្រូវចុះថ្ងៃខែឆ្នាំ ចុះនាមត្រកូល នាមកំណើត អាយុ និងលំនៅឋានរបស់សាក្សី[13]។

### ២. ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ

ក្រោយពេលដែលកម្ពុជាជួបនឹងសង្គ្រាមក្នុងប្រទេស ប្រជាជនពុំមានសិទ្ធិលើទ្រព្យសម្បត្តិឯកជននោះទេ ទ្រព្យសម្បត្តិស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកកាន់កាប់អំណាចទាំងអស់ ដូច្នេះហើយបុគ្គលដែលបានទទួលមរណកាលទៅនោះ ពុំមានទ្រព្យសម្បត្តិឯណាទុកសម្រាប់ចែកអ្នកជំនាន់ក្រោយនោះទេ។ លុះដល់ការបិទ

[10] មាត្រា ៥២៤ នៃក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ ១៩២០

[11] មាត្រា ៥២៦ នៃក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ ១៩២០

[12] មាត្រា ៥៥៦ នៃក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ ១៩២០

[13] មាត្រា ៥៥៧ នៃក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ ១៩២០

បញ្ចប់នៃសម័យកម្ពុជាប្រជាធិបតេយ្យ សញ្ញាណនៃការគ្រប់គ្រងកម្មសិទ្ធិជាលក្ខណៈឯកជនបានចាប់ផ្តើមវិវត្តឡើងបន្តិចម្តងៗ។ បន្ទាប់មកសន្តតិកម្ម ក៏ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជាម្តងទៀត ចាប់ពីពេលនោះមកសន្តតិកម្មត្រូវបានបញ្ចូលក្នុងបទដ្ឋានគតិយុត្តដែលរដ្ឋនឹងត្រូវចូលរួមជួយដោះស្រាយប្រសិនបើមានការប្រព្រឹត្តទៅនៃការផ្ទេរទ្រព្យនៅក្នុងគ្រួសារមួយជួបភាពលំបាក ដែលជាហេតុបង្កអោយមានទំនាស់ផ្សេងៗនៅក្នុងរង្វង់គ្រួសារ។ **ច្បាប់ភូមិបាលឆ្នាំ១៩៩២** ជាបទបញ្ញត្តិថ្មីស្តីពីសន្តតិកម្មដែលត្រូវបានចងក្រងឡើងម្តងទៀតបន្ទាប់ពីការការបាត់បង់នៃសញ្ញាណសន្តតិកម្មក្នុងសម័យសង្គ្រាម ប៉ុន្តែការចែងជាបទបញ្ញត្តិច្បាប់នៅក្នុងច្បាប់ភូមិបាលឆ្នាំ ១៩៩២ នេះមិនមានលក្ខណៈច្បាស់លាស់ដូចក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ ឡើយ ដោយហេតុថានៅក្នុងច្បាប់ភូមិបាលនេះបញ្ញត្តិច្រើនទាក់ទងទៅនឹងសមត្ថភាពរបស់ជន ដែលមានលក្ខណៈសម្បត្តិនៅក្នុងការទទួលបានសន្តតិកម្មប៉ុណ្ណោះ។ នៅក្នុងបញ្ញត្តិស្តីពីសន្តតិកម្មក្នុងច្បាប់ភូមិបាលឆ្នាំ ១៩៩២ សន្តតិកម្មអាចធ្វើឡើងតាមពីររបៀបគឺ សន្តតិមកម្មតាមច្បាប់ និងសន្តតិកម្មតាមឆន្ទៈរបស់ខ្មោច[14]។ សន្តតិកម្ម ត្រូវចាប់ចែកក្រោយថ្ងៃដែលខ្មោចនោះស្លាប់ និងនៅទីដែលជាលំនៅក្រោយបង្អស់របស់ខ្មោច[15]។ ចំពោះលក្ខខណ្ឌដែលសន្តតិកម្មតាមបណ្តាំប្រព្រឹត្តទៅដោយវិធីណា ឬមន្ត្រីសាធារណៈមួយណាដែលមានតួនាទីក្នុងការអន្តរាគមន៍ចំពោះសន្តតិកម្មប្រភេទនេះពុំមានចែងជាក់លាក់នោះទេ។

បន្ទាប់ពីប្រទេសកម្ពុជាបានរួចផុតពីសង្គ្រាម វត្តមានសារការីក៏ចាប់ផ្តើមមានវត្តមានម្តងទៀតតាមរយៈ **អនុក្រឹត្យលេខ ៥០៥ អនក្រ.តត. ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០១** ប៉ុន្តែចំពោះវត្តមានសារការីនេះដដែលសញ្ញាណនៃតួនាទីសារការី និងសន្តតិកម្មនៅតែដាច់ដោយឡែកពីគ្នា ព្រោះសារការីពុំទាន់មានតួនាទីនៅឡើយនៅក្នុងករណីសន្តតិកម្ម។ នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០០១ រដ្ឋាភិបាលនៃប្រទេសកម្ពុជាបានបង្កើតឱ្យមានវត្តមានសារការីឡើងវិញ តាមរយៈ អនុក្រឹត្យលេខ ៥០៥ អនក្រ.តត. ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០១ ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរបស់អ្នកវិនិយោគទុន និងប្រជាពលរដ្ឋទូទាំងប្រទេស។ នៅក្នុងការសម្រេចនៃអនុក្រឹត្យនេះ តាមរយៈមាត្រា១ បានធ្វើការតែងតាំងលោក **ប៉ែនសុន សម័យ** សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាមានអត្តលេខ៥៤ បន្ថែមលើមុខងារបច្ចុប្បន្នជា សារការី ដែលហៅកាត់ថា មេធាវីសារការី។ មេធាវីសារការី មានសមត្ថកិច្ចការងារទូទៅក្នុងវិស័យគ្រួសារ ចលនវត្ថុ និងអចលនវត្ថុ ជាអាទិ៍មានៈ ទទួល និងធ្វើ ឬ ចារឹកបញ្ជាក់ និងប្រថាប់ត្រា នូវលិខិតស្នាមគតិយុត្ត ឬ កិច្ចសន្យាទាំងឡាយដើម្បីជាបន្ទាល់ពេញលក្ខណៈតាមផ្លូវច្បាប់ ដែលតែងតែមានលិខិតរបស់រាជការអំណាចសាធារណៈ ធ្វើការបញ្ជាក់លើការិយបរិច្ឆេទ ទទួលតំកល់ទុកឯកសារ និងចេញឱ្យនូវសេចក្តីដើម

[14] មាត្រា ១៧០ នៃច្បាប់ភូមិបាលឆ្នាំ ១៩៩២

[15] មាត្រា ១៧១ នៃច្បាប់ភូមិបាលឆ្នាំ ១៩៩២

ឬសេចក្ដីចម្លងនៃលិខិត ឬ កិច្ចសន្យាទាំងឡាយនោះតាមមុខការ កិច្ចការនេះត្រូវពិនិត្យ អានឱ្យអស់សេចក្ដី និង ចុះហត្ថលេខានៃគូភាគីនៅចំពោះមុខ ទើបមេធាវីសារការី ចុះហត្ថលេខា ប្រថាប់ត្រា ចារឹកនាពេលនោះជាចុង ក្រោយ[16]។ បន្ទាប់មក**ច្បាប់ភូមិបាល ២០០១** នៅក្នុងច្បាប់ភូមិបាលមិនបានចែងជាក់លាក់អំពីមុខងារសារការី នៅក្នុងការបំពេញកិច្ចនៅតាមបញ្ញត្តិច្បាប់នោះទេ។ ប៉ុន្តែអ្វីដែលបានបញ្ញត្តិ និងបង្ហាញអំពីសញ្ញាណនៃតួនាទី សារការីនោះគឺទាក់ទិនទៅនឹងលិខិតយថាភូតដែលបានបញ្ជាក់អំពីកាតព្វកិច្ចសារការី។ នៅក្នុងមាត្រា ៨១ នៃ ច្បាប់ភូមិបាលនេះតែម្ដងក៏បានចែងថា ប្រទានកម្មអចលនវត្ថុមិនអាចត្រូវបានជំទាស់ពីតតិយជន លុះត្រាតែ ប្រទានកម្មនោះត្រូវបានធ្វើជាលាយលក្ខណ៍អក្សរតាមទម្រង់លិខិតយថាភូត ហើយត្រូវចុះបញ្ជីនៅអង្គភាព សុរិយោដី។ ចំណែកឯលិខិតយថាភូត ដែលមាននៅក្នុងសន្ទានុក្រមនៃច្បាប់ភូមិបាលនេះបានឱ្យនិយមន័យ ដូច្នេះថា លិខិតយថាភូតជាលិខិតធ្វើតាមរូបមន្តនៃច្បាប់ដូចជាលិខិតបញ្ជាក់ដែរ។ ហេតុនេះទើបមានជាសំណួរ ចោទសួរថា អ្វីជាលិខិតបញ្ជាក់? លិខិតបញ្ជាក់ជាសញ្ញាណមួយនៃពាក្យដែលបានមកពីក្រមរដ្ឋប្បវេណីចាស់ មានចែងនៅក្នុងមាត្រា ៩៤៤។ លិខិតបញ្ជាក់ គឺសំបុត្រដែលគូភាគីបានចុះហត្ថលេខាក្រោយពេលដែលគេបាន អានសេចក្ដីក្នុងសំបុត្រទាំងអស់យ៉ាងខ្លាំងៗ ដោយក្បោះក្បាយ ឱ្យមន្ត្រីរាជការសាធារណៈនេះក្រោយពីបាន ពិនិត្យអត្តសញ្ញាណនៃគូភាគី ក៏ដូចជាការចូលខ្លួនអំពីគូភាគី ព្រមទាំងអានលិខិតនោះឱ្យគូភាគីស្ដាប់ ក្រោយ ពិនិត្យឃើញថាហត្ថលេខាដែលភាគីបានចុះនោះឃើញពិតជាមានភាពត្រឹមត្រូវហើយ ទើបចុះហត្ថលេខាខ្លួនឯង ក្បែរហត្ថលេខានៃគូភាគីព្រមទាំងបោះត្រាបញ្ជាក់ផងដែរ[17]។ មន្ត្រីរាជសាធារណៈដែលបានរៀបរាប់នៅក្នុងក្រម រដ្ឋប្បវេណីចាស់ដែលមានសមត្ថភាពដើម្បីបញ្ជាក់លិខិត ត្រូវបានកម្រិតនៃចំនួនទឹកប្រាក់ និងដែនដីរបស់ខ្លួន មានន័យថាត្រូវទទួលសេវារបស់អតិថិជនផ្ដល់ឱ្យក្នុងកម្រិតដែលសមរម្យដោយមិនបំពានទៅលើករណីយកិច្ចនៃ មន្ត្រីសាធារណៈដទៃបានឡើយ។ តាមរយៈមាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណីចាស់បានចែងថា លិខិតទាំងឡាយ គ្រប់ប្រភេទ ដែលមានដាក់តម្លៃត្រឹម ឬលើស ២០០.០០០ រៀល ឡើងទៅត្រូវតែឱ្យសារការីបញ្ជាក់តាមទម្រង់ នៃ អាជីវកម្មរបស់ពួកគេ។ ចំណែកឯលិខិតដែលមានតម្លៃពី ៥០.០០០ រៀល ចៅហ្វាយស្រុកនៃអាណាខែត្រដែល ជាទីតាំងនៃអចលនវត្ថុ ឬចៅហ្វាយស្រុកនៃអាណាខែត្រខាងលំនៅនៃភាគីម្នាក់បញ្ជាក់។ ប្រសិនបើលិខិតមាន តម្លៃត្រឹម ៥០.០០០ រៀល ចុះមក ភាគីចង់យកទៅឱ្យមេឃុំ ឬចៅហ្វាយស្រុក ឬសារការីជាអ្នកបញ្ជាក់ក៏បានតាម ចិត្តរបស់ខ្លួន។ ចំពោះតួនាទីក្នុងសមត្ថកិច្ចរបស់មេឃុំ ចៅហ្វាយស្រុក មានកម្រិតតែព្រំឃុំ ព្រំស្រុកដែលខ្លួន

[16] មាត្រា ៣ នៃអនុក្រឹត្យលេខ ៥០៥ អនក្រ.តត. ស្ដីពីការផ្ដល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រ កម្ពុជា ដែលចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០១

[17] មាត្រា ៩៤៤ នៃក្រមរដ្ឋប្បវេណីកម្ពុជាចាស់

ត្រួតត្រាប៉ុណ្ណោះ[18]។ ដូច្នេះតាមរយៈនិយមន័យនៃលិខិតយថាភូតដែលមាននៅក្នុងសន្ធានុក្រមនៃច្បាប់ភូមិបាល ពុំមានបញ្ជាក់ឱ្យច្បាស់ថាលិខិតយថាភូតធ្វើដោយមន្ត្រីណាម្នាក់នោះទេ ប៉ុន្តែបើទាញតាមសញ្ញាណចេញពីក្រម រដ្ឋប្បវេណីចាស់នៃពាក្យថា លិខិតបញ្ជាក់គឺជាលិខិត ដែលបានធ្វើឡើងដោយសារការីសរុបន័យមកលិខិត យថាភូតជាលិខិតដែលធ្វើឡើងដោយសារការីផងដែរ។ ក្រោយពី **ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ចូលជាធរមាន** សារការីបានចូលរួមក្នុងការបំពេញភារកិច្ចនៅក្នុងសន្តតិកម្ម វាជាសញ្ញាណមួយថ្មីសម្រាប់បរិបទនៃសន្តតិកម្ម កម្ពុជា ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដោយព្រះរាជក្រមលេខ នស/រកម/ ១២០៧/០៣០ ត្រូវបានប្រកាសឱ្យប្រើដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី សញ្ញាណនៃមុខងារសារការី មានភាពច្បាស់លាស់ជាងពីមុន។នៅក្នុងសន្តតិកម្មការចូលរួមចំណែករបស់សារការីបានផ្តល់នូវផលប្រយោជន៍ ជាច្រើនចំពោះជនដែលពាក់ព័ន្ធនៅក្នុងសន្តតិកម្ម។ ជនដែលពាក់ព័ន្ធទាំងនោះរួមមាន ម្ចាស់បណ្តាំ និង សន្តតិជនជាអាទិ៍។ ច្បាប់មានភាពតឹងរឹងចំពោះនីតិវិធីចំពោះកាតព្វកិច្ចដែលម្ចាស់បណ្តាំត្រូវបំពេញនៅក្នុងការ តាក់តែងមតកសាសន៍។ នៅក្នុងរបបសន្តតិកម្ម មតកជនអាចបន្សល់នូវឆន្ទៈចុងក្រោយរបស់ខ្លួន ក្នុងការបែង ចែកទ្រព្យសម្បត្តិរបស់ខ្លួននៅពេលដែលមតកជននៅមានជីវិត ឱ្យទៅសន្តតិជន។ ឆន្ទៈរបស់មតកជន អាចត្រូវ ប្រតិបត្តិបាននៅពេលដែលម្ចាស់បណ្តាំបានស្លាប់ ហើយខ្លឹមសារនៃបណ្តាំ ដែលមានអានុភាពយកមកអនុវត្ត បានលុះត្រាតែ បណ្តាំនោះបំពេញបានត្រឹមត្រូវតាមទម្រង់ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីព្រះរាជាណា ចក្រកម្ពុជា២០០៧។ ក្នុងនាមជាម្ចាស់ទ្រព្យ នៅពេលមានជីវិតម្ចាស់បណ្តាំអាចធ្វើការចាត់ចែងទ្រព្យដែលខ្លួន មានឱ្យទៅជនគ្រប់រូបដែលខ្លួនគិតថាពេញចិត្ត។ ដូច្នេះម្ចាស់បណ្តាំអាចធ្វើការបែងចែកមត៌កនោះទៅឱ្យជនណា ម្នាក់ក៏បានតាមរយៈ ការធ្វើជាអំណោយ ប្រទានកម្ម នៅកំឡុងពេលដែលខ្លួននៅមានជីវិត ម្យ៉ាងវិញទៀតម្ចាស់ បណ្តាំក៏អាចកំណត់ជាស្រេចអំពីចំណែកមត៌ក និងវិធីបែងចែកចំណែកមត៌ក ទុកឱ្យសន្តតិជន ឬអច្ច័យលាភី ធ្វើ ការបែងចែកនៅពេលដែលខ្លួនទទួលមរណភាពទៅហើយក៏បាន នេះជាសិទ្ធិសម្រេចរបស់ម្ចាស់បណ្តាំ។ នៅក្នុង សន្តតិកម្ម ប្រសិនបើម្ចាស់បណ្តាំសម្រេចចិត្តថា សន្តតិកម្មដែលបានបន្សល់ទុកត្រូវប្រព្រឹត្តទៅតាមមតកសាសន៍ នោះម្ចាស់បណ្តាំត្រូវរៀបចំជាស្រេចនូវលិខិតបណ្តាំដែលមានខ្លឹមសារដែលមានអានុភាព អាចឱ្យសន្តតិជន ឬ អច្ច័យលាភីអាចជឿជាក់ថាជាបណ្តាំដែលចេញពីឆន្ទៈពិតរបស់ម្ចាស់បណ្តាំពិតប្រាកដ។ ដើម្បីកំណត់ថាលិខិត បណ្តាំមួយជាលិខិតដែលចេញពីឆន្ទៈរបស់ម្ចាស់បណ្តាំពិតប្រាកដ ច្បាប់បានបញ្ញត្តិអំពីទម្រង់ដែលម្ចាស់បណ្តាំ ត្រូវតែអនុវត្តជាដាច់ខាត មិនឱ្យខ្វះចំណុចណាមួយនោះទេ ព្រោះការខ្វះខាតនូវល័ក្ខខ័ណ្ឌណាមួយនាំឱ្យខ្លឹមសារ

[18] មាត្រា ៩៤៦ នៃក្រមរដ្ឋប្បវេណីកម្ពុជាចាស់

នៃបណ្តាំនោះ ទទួលរងនូវមោឃភាព ដូច្នេះរាល់ទម្រង់នីមួយៗមិនអាចខុសពីល័ក្ខខ័ណ្ឌដែលច្បាប់បានកំណត់ឡើយ។ នៅក្នុងបញ្ញត្តិស្តីពីសន្តតិកម្ម ទម្រង់នៃមតកសាសន៍ដែលសារការីត្រូវតែគោរពមានដូចតទៅ:

**លិខិតយថាភូតៈ** មតកសាសន៍ជាលិខិតយថាភូត ជាលិខិតបណ្តាំដែលជាឆន្ទៈចុងក្រោយរបស់មតកជនដែលបានបង្កើតឡើងដោយសារការី។ នៅក្នុងតួនាទីជាអ្នកបង្កើតលិខិតយថាភូត សារការីជាអ្នកពិនិត្យពិច័យសមត្ថភាពក្នុងការធ្វើបណ្តាំ និងឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ ព្រមទាំងអនុលោមទៅតាមច្បាប់នូវល័ក្ខខ័ណ្ឌទម្រង់ និងខ្លឹមសារនៃមត៌ក។ នៅក្នុងដំណាក់កាលនៃការតាក់តែងលិខិតយថាភូត ជាដំណាក់កាលមួយដែលតម្រូវឱ្យម្ចាស់បណ្តាំត្រូវប្រាប់ដោយផ្ទាល់មាត់នូវខ្លឹមសារបណ្តាំនៅចំពោះមុខសារការីនិងសាក្សីចំនួនពីរនាក់[19]។ កាលដែលម្ចាស់បណ្តាំបានសូត្រខ្លឹមសារនៃបណ្តាំ សារការីត្រូវសរសេរខ្លឹមសារដែលថ្លែងការណ៍ជាលាយល័ក្ខអក្សរបញ្ចូលក្នុងលិខិតយថាភូតឱ្យមានអត្ថន័យតាមផ្លូវច្បាប់។ បន្ទាប់មកសារការីត្រូវបញ្ជាក់ពីខ្លឹមសារនៃបណ្តាំនោះ ដោយ សារការីត្រូវសូត្រឱ្យម្ចាស់បណ្តាំស្តាប់នូវខ្លឹមសារដែលខ្លួនបានសរសេរនោះនៅចំពោះមុខសាក្សី។ ក្នុងកំឡុងពេលនៃការតាក់តែងមតកសាសន៍ សារការីត្រូវគិតពីចំណុចដែលមាននៅក្នុងមតកសាសន៍ ដើម្បីជួយម្ចាស់បណ្តាំធ្វើយ៉ាងណាឱ្យខ្លឹមសារបណ្តាំមានមានភាពច្បាស់លាស់ និងសម្រេចនូវបណ្តាំមួយដែលមានប្រសិទ្ធិភាពខ្ពស់នៅក្នុងដំណាក់កាលចាប់ផ្តើមសន្តតិកម្ម។ នៅក្នុងដំណាក់កាលនៃការតាក់តែងមតកសាសន៍ចំណុចដែលត្រូវគិតដល់មានដូចជា ការកំណត់ចំណែកមត៌ក ការកំណត់នូវវិធីបែងចែក សន្តតិជន និងអច្ច័យទាន។ ការកំណត់ចំណែកមត៌ក អាស្រ័យតាមឆន្ទៈរបស់ម្ចាស់បណ្តាំ ប៉ុន្តែប្រសិនបើមានការបំពានភាគបម្រុងនោះនឹងនាំឱ្យមានការទាមទារភាគបម្រុងនៅពេលសន្តតិកម្មចាប់ផ្តើម ដូច្នេះសារការីនឹងពិនិត្យ និងធ្វើយ៉ាងណាដើម្បីកុំឱ្យ ឆន្ទៈមតកជនបំពានភាគបម្រុង។ ចំណែកឯការកំណត់វិធីបែងចែកសារការី ត្រូវប្រាប់អំពីវិធីបែងចែកដោយមតកសាសន៍ដែលមានចែងនៅក្នុងមាត្រា ១១៨៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧។ ក្រៅពីនេះប្រសិនបើមានសន្តតិជនណាម្នាក់ត្រូវបានកាត់ផ្តាច់ចេញពីមត៌ក ឬអភ័ព្វបុគ្គលនោះត្រូវសរសេរនៅក្នុងមតកសាសន៍ផងដែរ។ បន្ទាប់ពីបានស្តាប់សារការីបានសូត្រពីខ្លឹមសារ ដែលសារការីបានសរសេរហើយ ហើយម្ចាស់បណ្តាំក៏ទទួលស្គាល់ថា មតកសាសន៍ដែលសារការីបានតាក់តែងមានភាពត្រឹមត្រូវហើយនោះម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើមតកសាសន៍ត្រូវចុះហត្ថលេខាលើមតកសាសន៍នោះ[20]។ នៅមុនពេលការចុះហត្ថលេខានេះ ដើម្បីឱ្យមានភាពច្បាស់លាស់ថែមទៀតមតកជន ដែលចេះអានអក្សរគួរពិនិត្យមើលខ្លឹមសារនៅពេលដែលខ្លួនបានសរសេរនោះទើបជាការប្រសើរ ហើយម្ចាស់បណ្តាំត្រូវតែមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និងលំនៅឋាន។ ការចុះហត្ថលេខាពិតជាមានសារៈសំខាន់ណាស់ ព្រោះវាបញ្ជាក់អំពីភាព

[19] មាត្រា ១១៧៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧ កថាខណ្ឌទីទី១

[20] មាត្រា ១១៧៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧ កថាខណ្ឌទី២ ចំណុច ឃ

ត្រឹមត្រូវនៃខ្លឹមសារមតកសាសន៍ដែលសារការីបានសរសេរ ក៏ដូចជាការផ្តល់នូវជំនឿជាក់ទៅលើការអនុវត្តច្បាប់ក្នុងសន្តតិកម្មនេះផងដែរ។ ប៉ុន្តែនៅក្នុងករណី ដែលម្ចាស់បណ្តាំមិនអាចសរសេរ ឬមិនអាចចុះហត្ថលេខាបានទេនោះ សារការីអាចជំនួសការសរសេរ និងហត្ថលេខារបស់ម្ចាស់បណ្តាំបាន ដោយសរសេរឈ្មោះអាយុ និងលំនៅឋានរបស់ម្ចាស់បណ្តាំ ហើយនៅត្រង់ចំណុចនេះសារការីត្រូវសរសេរហេតុនោះផង[21]។ សាក្សី ជាបុគ្គលសំខាន់នៅក្នុងកំឡុងពេលបង្កើតលិខិតយថាភូតដើម្បីបញ្ជាក់ពីភាពពិតត្រឹមត្រូវនៃឆន្ទៈរបស់មតកជន។ សាក្សីត្រូវមានវត្តមាននៅពេលតាក់តែងលិខិតយថាភូត ព្រោះសាក្សីជាអ្នកចូលរួមស្តាប់ពីខ្លឹមសារដែលម្ចាស់បណ្តាំបានសូត្រឱ្យសារការីសរសេរ និងខ្លឹមសារដែលសារការីសូត្រនៅពេលតាក់តែងលិខិតជាលាយល័ក្ខអក្សរ។ បន្ទាប់ពីបានស្តាប់នូវខ្លឹមសារដែលសារការីបានសរសេរនោះហើយ ប្រសិនជាម្ចាស់បណ្តាំ និងសាក្សីទទួលស្គាល់ថាកំណត់ជាលាយល័ក្ខអក្សរនោះត្រឹមត្រូវ សាក្សីត្រូវចុះហត្ថលេខាលើមតកសាសន៍ដែលសារការីបានសូត្ររួច។ សាក្សី ជាបុគ្គលសំខាន់។ សាក្សី ត្រូវចុះហត្ថលេខាលើបណ្តាំដែលសារការីបានសរសេរជាលាយល័ក្ខអក្សរ និងសូត្រឱ្យស្តាប់នោះនៅពេលដែលខ្លឹមសារនៃការសរសេរនោះត្រឹមត្រូវដូចឆន្ទៈរបស់ម្ចាស់បណ្តាំដែលបានសូត្រឱ្យសារការីសរសេរតាមនៅក្នុងមតកសាសន៍នោះ។ នៅមុនពេលចុះហត្ថលេខាសាក្សីត្រូវពិនិត្យឱ្យច្បាស់ និងប្រាកដថាឈ្មោះ អាយុ ដែលបានបង្ហាញចំពោះមុខសារការី និងលំនៅឋានខ្លួនពិតជាត្រឹមត្រូវ។ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ក៏ដូចជាក្រមរដ្ឋប្បវេណីចាស់ដែរ គឺមិនបានហាមឃាត់អនក្ខរជនមិនឱ្យធ្វើជាសាក្សីនោះទេ (មាត្រា ៥៥៧ នៃក្រមរដ្ឋប្បវេណីចាស់)។ នៅក្នុងន័យនេះ គឺច្បាប់អនុញ្ញាតឱ្យពួកគាត់ដែលមិនចេះអក្សរមានលក្ខណៈសម្បត្តិអាចធ្វើជាសាក្សី ហើយ វិធីចុះហត្ថលេខានៅក្នុងមតកសាសន៍មានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នក្នុងមាត្រា ១១៨០ ដោយការសរសេរតែនាមត្រកូល និងនាមខ្លួន និងផ្តិតស្រាមដៃជំនួសឱ្យការចុះហត្ថលេខា។ សាក្សីអាចពិនិត្យខ្លឹមសារនៅក្នុងមតកសាសន៍ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវឱ្យកាន់តែច្បាស់។ ដូច្នេះក្នុងការជ្រើសរើសបុគ្គលណាម្នាក់មកធ្វើជាសាក្សី ប្រសិនបើសាក្សីជាបុគ្គលដែលអាចចេះអាន និងយល់ពីខ្លឹមសារនៃសារការីបានសរសេរជាសារៈសំខាន់បន្ថែមទៀតនៅក្នុងការបង្កើតលិខិតយថាភូត។ បន្ទាប់ពីម្ចាស់បណ្តាំ និងសាក្សីបានចុះហត្ថលេខាក្នុងលិខិតជាលាយល័ក្ខអក្សរ ដែលសារការីបានសរសេររួចរាល់ហើយនោះ ជាចុងក្រោយជាតួនាទីរបស់សារការីក្នុងការចុះហត្ថលេខា។ ការចុះហត្ថលេខារបស់សារការីត្រូវមានសរសេរថ្ងៃ ខែ និងឆ្នាំផងដែរ[22]។

**លិខិតសម្ងាត់៖** មតកសាសន៍ដោយលិខិតសម្ងាត់គឺជា វិធីមតកសាសន៍មួយដែលអនុញ្ញាតឱ្យអ្នកចេះអក្សរធ្វើមតកសាសន៍ដោយរក្សាខ្លឹមសារផ្ញើរួចនោះជាសម្ងាត់ទាំងស្រុងដើម្បីរក្សាការសម្ងាត់របស់ខ្លួន។ មតក

[21] មាត្រា ១១៧៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧កថាខណ្ឌទី២ វាក្យខណ្ឌ២ ចំណុច ឃ

[22] មាត្រា ១១៧៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧ កថាខណ្ឌទីទី២ ចំណុច ង

សាសន៍ដោយលិខិតសម្ងាត់ អាចរក្សាការសម្ងាត់នៃខ្លឹមសារ មត៌កពីសំណាក់សន្តតិជន អច្ច័យលាភី និងជនដែលត្រូវបានផ្តាច់ចេញពីមត៌កបាន។ មតកសាសន៍ជាលិខិតសម្ងាត់ត្រូវបានរក្សាទុកការសម្ងាត់រហូតដល់ពេលបើកមតកសាសន៍។ នៅក្នុងការធ្វើមតកសាន៍ជាលិខិតសម្ងាត់ សារការីមានតួនាទីជាអ្នករក្សាទុកនូវខ្លឹមសារដែលមាននៅក្នុងមតកសាសន៍នោះរហូតដល់សន្តតិកម្មចាប់ផ្តើម។ មតកសាសន៍ដោយលិខិតសម្ងាត់ ជាប្រភេទមតកសាសន៍ ដែលម្ចាស់បណ្តាំក្នុងគោលបំណងបង្ហាញពីឆន្ទៈដែលមតកជនមានបំណងចង់ប្រគល់ទ្រព្យទៅឱ្យសន្តតិជន ឬអច្ច័យលាភីណាម្នាក់នៅពេលដែលមតកជនស្លាប់ទៅនោះ។ នៅពេលដែលសរសេរលិខិត ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតនោះ ម្ចាស់បណ្តាំត្រូវដាក់លិខិតនៅក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬសញ្ញាសម្គាល់ ឬមធ្យោបាយផ្សេងទៀតនៅមាត់ស្រោមសំបុត្រនោះ ដើម្បីអាចវិនិច្ឆ័យបានអំពីការបើក ឬមិនបានបើកស្រោមលិខិតនោះ[23]។ បន្ទាប់មកលិខិតដែលបិទជិតនោះត្រូវបានដាក់ដោយម្ចាស់បណ្តាំនៅចំពោះមុខសារការីម្នាក់ និងសាក្សីពីរនាក់ ហើយម្ចាស់បណ្តាំត្រូវធ្វើសេចក្តីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន។ នៅក្នុងការដែលម្ចាស់បណ្តាំត្រូវដាក់លិខិតនៅចំពោះមុខសារការី និងសាក្សី ព្រមទាំងថ្លែងអំពីលិខិតនោះ គឺដើម្បីបញ្ជាក់ថាខ្លឹមសារទាំងឡាយដែលស្ថិតនៅក្នុងស្រោមសំបុត្របិទជិតនោះពិតជាចេញពីឆន្ទៈរបស់ខ្លួនក្នុងការប្រគល់ទ្រព្យតាមរយៈសន្តតិកម្មពិតមែន។ នៅក្នុងករណីដែលម្ចាស់បណ្តាំ បានឱ្យអ្នកដទៃសរសេរជំនួសនូវលិខិតនោះ ម្ចាស់បណ្តាំត្រូវធ្វើសេចក្តីថ្លែងអំពីឈ្មោះ និងលំនៅឋានរបស់ជនដែលបានសរសេរនោះ[24]។ មតកសាសន៍ជាលិខិតសម្ងាត់ ត្រូវតែរក្សាទុកដោយសារការី ការរក្សាដើម្បីធានាពីភាពច្បាស់លាស់ និងពិតប្រាកដថាមតកសាសន៍នោះមិនត្រូវបានកែប្រែលើចំណុចណាមួយ។ នៅក្នុងមតកសាសន៍ជាលិខិតសម្ងាត់ ត្រូវឱ្យមានសាក្សីចូលរួមផងដែរ។ សារការីត្រូវពិនិត្យមើលសមត្ថភាពរបស់ជនដែលជាសាក្សីនោះ។ សមត្ថភាពសាក្សីដែលអាចចូលរួមក្នុងលិខិតសម្ងាត់ដូចគ្នានឹងសមត្ថភាពរបស់សាក្សី ដែលមានចែងនៅក្នុងលិខិតយថាភូតចំណុចលក្ខណៈសម្បត្តិសាក្សី ប៉ុន្តែ ចំពោះតួនាទីរបស់សាក្សីនៅក្នុងមតកសាសន៍ដោយលិខិតសម្ងាត់ គឺខុសគ្នាពីការបំពេញនៅក្នុងលិខិតយថាភូត។ ភាពខុសគ្នានេះនៅត្រង់ថា សាក្សីដែលបានចូលរួមក្នុងការបង្កើតលិខិតយថាភូតបានដឹងអំពីខ្លឹមសារនៃបណ្តាំតាមការអានរបស់សារការីនិងការថ្លែងរបស់ម្ចាស់បណ្តាំ លើសពីនេះទៅទៀត មុនចុះហត្ថលេខាបញ្ជាក់ពីភាពត្រឹមត្រូវសាក្សីអាចពិនិត្យខ្លឹមសារនៃបណ្តាំតាមរយៈការអានខ្លឹមសារដែលសារការីបានសរសេរនោះ។ ចំណែកឯសាក្សីនៅក្នុងការបង្កើតលិខិតសម្ងាត់វិញ ការចូលរួមត្រឹមតែជាបុគ្គលសាក្សីដើម្បីបញ្ជាក់ថាម្ចាស់បណ្តាំបានយកមតកសាសន៍ដាក់នៅក្នុងស្រោមបិទជិត និងធ្វើការ

[23] មាត្រា ១១៧៥ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧

[24] មាត្រា ១១៧៥ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧ ចំណុច គ

ចុះហត្ថលេខាលើស្រោមសំបុត្រនោះប៉ុណ្ណោះ[25]។ សាក្សីនៅក្នុងការបង្កើតលិខិតសម្ងាត់មិនអាចដឹងអំពីអត្ថន័យដែលមានសរសេរនៅក្នុងមតកសាសន៍ឡើយ។ មតកសាសន៍ដោយលិខិតសម្ងាត់ ជាវិធីមតកសាសន៍មួយដែលអនុញ្ញាតឱ្យអ្នកដែលចេះអក្សរធ្វើមតកសាសន៍ដោយរក្សាខ្លឹមសារនោះជាការសម្ងាត់ទាំងស្រុង ហើយដែលអាចការពារកុំឱ្យមានការលុបចោល ឬ ការលួចកែប្រែដោយតតិយជន[26]។ ការរក្សាទុកនូវលិខិតសម្ងាត់ ច្បាប់បានប្រគល់តួនាទីនៅក្នុងការថែរក្សានេះឱ្យទៅសារការី។ បន្ទាប់ពីម្ចាស់បណ្តាំបានដាក់លិខិតដែលខ្លួនសរសេរនៅក្នុងស្រោមសំបុត្របិទជិត និងបន្ទាប់ពីសារការីត្រួតពិនិត្យមើលភាពត្រឹមត្រូវ ដែលជាល័ក្ខខ័ណ្ឌដែលបានកំណត់ដោយច្បាប់ដូចដែលបានជម្រាបជូនខាងលើហើយនោះ ជាចុងបញ្ចប់សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និង សរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំនៅលើលិខិតដែលបានបិទជិតនោះ ហើយត្រូវចុះហត្ថលេខាលើលិខិតនោះជាមួយនឹងសាក្សី និងម្ចាស់ បណ្តាំ[27]។

**មតកសាសន៍ចំពោះជនដែលមិនអាចនិយាយបាន៖** នៅក្នុងដំណាក់កាលនៃការតាក់តែងលិខិតយថាភូត គឺទាមទារឱ្យម្ចាស់បណ្តាំប្រាប់ដោយផ្ទាល់មាត់នូវខ្លឹមសារនៃបណ្តាំនៅចំពោះមុខសារការី និងសាក្សី។ ឬប្រសិនបើមតកសាសន៍ជាលិខិតសម្ងាត់វិញ តម្រូវឱ្យមតកជនថ្លែងការណ៍បញ្ជាក់ថា លិខិតបានដាក់នៅក្នុងស្រោមសំបុត្របិទជិតជាលិខិតរបស់ខ្លួននៅចំពោះមុខសារការី និងសាក្សី ដើម្បីបញ្ជាក់ថាខ្លឹមសារនៃបណ្តាំដែលខ្លួនបានធ្វើនោះពិតជាចេញពីឆន្ទៈពិតប្រាកដរបស់ខ្លួនពិតមែន។ ដោយឡែកនៅក្នុងករណីមួយចំនួនមតកជនមិនអាចប្រាប់ដោយផ្ទាល់មាត់នូវខ្លឹមសារនៃបណ្តាំ និងមិនអាចស្តាប់សូត្រនូវខ្លឹមសារនៃបណ្តាំរបស់សារការីបានឡើយ។ នៅក្នុងករណីនេះក្រមរដ្ឋប្បវេណី បានចែងបញ្ញត្តិសម្របសម្រួលមួយដែលមានចែងនៅក្នុងមាត្រា ១១៧៩ ដែលឱ្យមានអ្នកបកប្រែដើម្បីបកប្រែជំនួសម្ចាស់បណ្តាំ។ ក្នុងករណីដែលមតកជនមិនអាចនិយាយបានម្ចាស់បណ្តាំនោះអាចជំនួសការប្រាប់បានដោយធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ ឬ សេចក្តីថ្លែងការណ៍ថាលិខិតនោះជាលិខិតមតកសាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬសរសេរដោយដៃខ្លួនផ្ទាល់នៅចំពោះមុខសារការី[28]។ បន្ទាប់ពីសារការី បានសរសេរជាលាយល័ក្ខណ៍អក្សរនូវខ្លឹមសារនៃមតកសាសន៍នោះ ហើយសារការីត្រូវអានឱ្យម្ចាស់បណ្តាំ ឬសាក្សីស្តាប់នូវអត្ថន័យនៃមតកសាសន៍។ ប៉ុន្តែនៅក្នុងករណីប្រសិនបើម្ចាស់បណ្តាំ និងសាក្សីជាមនុស្សថ្លង់មិនអាចស្តាប់បាន នោះសារការីអាចជំនួសការអានឱ្យស្តាប់បាន ដោយ

[25] មាត្រា ១១៧៥ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧

[26] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី មាត្រា ១១៧៥

[27] មាត្រា ១១៧៥ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧ ចំណុច ឃ

[28] មាត្រា ១១៧៩ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧ កថាខណ្ឌទី ១

ប្រាប់ពីអត្ថន័យដែលខ្លួនបានសរសេរនោះតាមការបកប្រែរបស់អ្នកបកប្រែទៅម្ចាស់បណ្តាំ ឬសាក្សីនោះ ហើយនៅក្នុងករណីនេះសារការីត្រូវសរសេរអំពីហេតុនេះចូលក្នុងលិខិតនោះ[29]។

ដើម្បីឱ្យបណ្តាំមួយមានប្រសិទ្ធភាពខ្ពស់ នៅពេលចាប់ផ្តើមសន្តតិកម្ម សារការីជាអ្នកដែលមានវិជ្ជាជីវៈច្បាប់នឹងបំពេញភារកិច្ចតាមច្បាប់ ដើម្បីជួយម្ចាស់បណ្តាំឱ្យបញ្ចៀសសពីបញ្ហាទាំងឡាយដែលអាចកើតមាននៅក្នុងមតកសាសន៍។ ការចូលរួមរបស់សារការី គឺធ្វើយ៉ាងណាដើម្បីធានាភាពត្រឹមត្រូវចំពោះខ្លឹមសារដែលមាននៅក្នុងមតកសាសន៍ពិតជាចេញពីឆន្ទៈរបស់បណ្តាំពិតប្រាកដមែន។ នៅពេលដែលម្ចាស់បណ្តាំនៅមានជីវិត សារការីអាចធ្វើឱ្យបណ្តាំមួយទទួលបានការគោរពយ៉ាងមានប្រសិទ្ធិភាពតាមរយៈ ការប្រឹក្សាផ្នែកច្បាប់ពាក់ព័ន្ធនឹងច្បាប់សន្តតិកម្ម ការតាក់មតកសាសន៍ និង ទទួលតម្កល់លិខិតបណ្តាំដែលម្ចាស់បណ្តាំបានតាក់តែងឡើងផងដែរ។ ចំពោះសន្តតិជនវិញ សំដៅទៅលើជនដែលនឹងត្រូវស្នងមត៌ក ដែលម្ចាស់បណ្តាំបានបន្សល់ទុកនៅពេលសន្តតិកម្មចាប់ផ្តើម។ នៅក្នុងករណីដែលសន្តតិកម្មធ្វើឡើងដោយមតកសាសន៍ នោះសន្តតិជននឹងត្រូវទទួលមត៌កតាមចំណែកតាមខ្លឹមសារដែលមតកជនបានបន្សល់ទុកនោះ។ នៅក្នុងដំណាក់កាលដែលសន្តតិកម្ម ចាប់ផ្តើម ប្រសិនបើសារការីជាអ្នកតាក់តែង ឬតម្កល់ទុកនូវមតកសាសន៍នោះរួចហើយ សារការីមានតួនាទីក្នុងការបើកបណ្តាំមត៌កនោះតាមនីតិវិធីដែលច្បាប់បានកំណត់។ ផ្ទុយមកវិញប្រសិនបើសន្តតិកម្មដែលបានធ្វើឡើង ជាសន្តតិកម្មតាមមតកសាសន៍ដោយលិខិតឯកជនវិញនោះ ហើយមិនមានវត្តមានសារការីចូលរួមក្នុងការបង្កើតនោះ សន្តតិជនក៏អាចស្វែងរកសារការីដើម្បីជាជំនួយផ្នែកច្បាប់បានផងដែរ។ សារការី អាចជួយសន្តតិជនប្រឹក្សាយោបល់ផ្នែកច្បាប់ជុំវិញបញ្ហាសន្តតិកម្មមុននឹងសន្តតិជនទទួលយក ឬបោះបង់សន្តតិកម្ម ព្រោះប្រសិនបើសន្តតិជនទទួលយកមត៌កដែលមានបំណុលជាអាទិ៍ដែលលើសពីទំហំមត៌ក នោះនឹងនាំឱ្យសន្តតិជនខាតបង់ទ្រព្យផ្ទាល់ខ្លួនទៀតក៏មាន។ ក្រៅពីនេះ សារការីមានតួនាទីក្នុងការបំពេញមុខងារជាអ្នកតាក់តែងលិខិតយថាភូតទាក់ទងនឹងនីតិមត៌កទៅតាមតម្រូវការរបស់ច្បាប់ និងសន្តតិជនដូចជាៈ សេចក្តីថ្លែងការណ៍ទាក់ទងនឹងការយល់ព្រម ឬបោះចោលមត៌ក កិច្ចព្រមព្រៀងបែងចែកចំណែក និងការបោះបង់ចោលសន្តតិកម្ម ជាអាទិ៍។

**កថាខណ្ឌទី២៖ ផលប្រយោជន៍នៃការវិវត្តវត្តមានសារការីក្នុងសន្តតិកម្ម**

នៅក្នុងបញ្ហាសន្តតិកម្ម មានបញ្ហាជាច្រើនដែលតែងតែបង្កើតឱ្យមានជម្លោះជាញឹកញាប់នៅក្នុងសង្គមកម្ពុជា។ ដូច្នេះតាមរយៈការវិវត្តនៃសារការី និងសន្តតិកម្មតាំងពីដំបូងរហូតមកដល់បច្ចុប្បន្ននេះ ធ្វើឱ្យពួកខ្ញុំសង្កេតឃើញអំពីអត្ថប្រយោជន៍មួយចំនួនចំពោះការផ្លាស់ប្តូរមន្ត្រីដែលមានមុខងារនៅក្នុងសង្គមចាស់ មកជាសារការីក្នុងសម័យពេលបច្ចុប្បន្ន ប៉ុន្តែមុននឹងឈានដល់ការបកស្រាយចំណុចនេះពួកយើងខ្ញុំសុមធ្វើការបង្ហាញ

[29] មាត្រា ១១៧៩ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧ កថាខណ្ឌទី ២,៣

ត្រួសៗពីបញ្ហាដែលតែងតែកើតមានឡើងនៅក្នុងជាញឹកញាប់នៅក្នុងសង្គម ការបង្ហាញនេះនឹងនាំឱ្យឃើញកាន់តែច្បាស់អំពីការផ្លាស់ប្តូរមន្ត្រីពីសង្គមចាស់ មកជាសារការីនេះ។

### ១. បញ្ហាដែលកើតឡើងជាញឹកញាប់នៅក្នុងសន្តតិកម្ម

**បណ្តាំផ្ទាល់មាត់** នៅក្នុងសង្គមខ្មែរ ភាគច្រើននៃប្រជាជនដែលជាមតកជនតែងតែបន្សល់ទុកនូវទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ខ្លួនអោយទៅសន្តតិជន ដោយការប្រាប់ដោយផ្ទាល់មាត់ចំពោះទ្រព្យសម្បត្តិដែលនៅសល់ចុងក្រោយរបស់ខ្លួននោះ។ បណ្តាំដែលធ្វើឡើងដោយផ្ទាល់មាត់ មិនមែនជាទម្រង់ដែលច្បាប់បានកំណត់នោះទេ ប៉ុន្តែជាគោលការណ៍ច្បាប់គឺគោរពតាមឆន្ទៈរបស់បុគ្គលមិនថាបុគ្គលនៅរស់ ឬបុគ្គលដែលបានស្លាប់ទៅហើយក្តី ឆន្ទៈរបស់មតកជននៅតែត្រូវគោរពអោយតែឆន្ទៈនោះមិនប៉ះពាល់ដល់សិទ្ធិរបស់អ្នកដទៃ។ នៅក្នុងករណីដែលមតជនបានធ្វើបណ្តាំដោយផ្ទាល់មាត់សម្រាប់សន្តតិជនទៀតសោត ទោះបីតាមផ្លូវច្បាប់មិនមានអានុភាពក៏ដោយ នៅពេលដែលមតកជនស្លាប់ទៅ មត៌កដែលបានផ្តែផ្តាំនឹងត្រូវធ្លាក់ទៅលើសន្តតិជនតាមឆន្ទៈមតកជនបើគ្មានការជំទាស់ពីសហសន្តតិជនផ្សេងទៀត នោះមានន័យថាសន្តតិជននោះអាចទទួលមត៌កបាន។ ប៉ុន្តែប្រសិនបើ នៅពេលដែលសន្តតិកម្មចាប់ផ្តើមមានសហសន្តតិជនផ្សេងទៀតបានតវ៉ាចំពោះការអះអាងរបស់សន្តតិជនដែលមតកជនបានធ្វើបណ្តាំ(ផ្ទាល់មាត់) នោះសន្តតិកម្មតាមការនិយាយដោយផ្ទាល់មាត់របស់មតកជននឹងត្រូវបានលើកចោល ព្រោះវាមិនមែនជាទម្រង់ដែលច្បាប់កំណត់ ជាពិសេសគឺពុំមានភ័ស្តុតាងបញ្ជាក់ពីភាពត្រឹមត្រូវនៃបណ្តាំ ចំណុចនេះហើយសន្តតិកម្មធ្វើឡើងតាមការផ្តែផ្តាំដោយផ្ទាល់មាត់នេះគ្មានអានុភាពតាមផ្លូវច្បាប់ដូចគ្នា។ ដូច្នេះឆន្ទៈរបស់មតកជននឹងគ្មានអានុភាពនោះទេ ចំពោះការបែងចែកនឹងអនុវត្តតាមច្បាប់វិញម្តង។ ប្រសិនបើសន្តតិកម្មប្រែមកជាការបែងចែកតាមផ្លូវច្បាប់នោះ មានន័យថាគោលបំណងរបស់មតកជនមិនបានសម្រេចនោះទេ ដូច្នេះទ្រព្យដែលសន្តតិជនដែលនឹងត្រូវទទួលនោះមិនបានគ្រប់តាមការចង់ផ្តល់អោយរបស់មតកជននោះទេព្រោះ សន្តតិកម្មតាមច្បាប់ត្រូវបែងចែកទៅតាមសមាមាត្រដែលមានចែងនៅក្នុងច្បាប់ជាធរមាន។

**បណ្តាំដែលមតកជនបានសរសេរដោយមិនត្រូវតាមទម្រង់នៃច្បាប់** នៅក្នុងករណីដែលម្ចាស់បណ្តាំបានសរសេរលិខិតបណ្តាំរបស់ខ្លួន ដើម្បីជាសាក្សីភាពបង្ហាញពីឆន្ទៈរបស់ខ្លួន។ នៅក្នុងចំណុចនេះ ក្រមរដ្ឋប្បវេណីបានអនុញ្ញាតអោយមតកជនអាចសរសេរនូវលិខិតបណ្តាំរបស់ខ្លួនបាន ប៉ុន្តែអត្ថន័យនៃបណ្តាំនេះអាចមានអានុភាពទៅបានលុះត្រាតែ គោរពតាមល័ក្ខខ័ណ្ឌទម្រង់ដែលមានចែងនៅក្នុងច្បាប់ត្រង់មាត្រា ១១៧៤ (មតកសាសន៍ដោយលិខិតឯកជន) នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧។ ការសរសេរមតកសាសន៍ប្រភេទនេះ ម្ចាស់បណ្តាំត្រូវតែសរសេរខ្លឹមសារនៃពាក្យពេជន៍បណ្តាំទាំងអស់ និងចុះថ្ងៃខែឆ្នាំ ដោយខ្លួនឯង ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ។ ផ្ទុយទៅវិញមតកសាសន៍ដោយលិខិតឯកជនដែលត្រូវបាន

សរសេរជំនួសដោយអ្នកដទៃ ឬ ដែលត្រូវបានសរសេរដោយប្រើម៉ាស៊ីនដូចជាអង្គុលីលេខ កុំព្យូទ័រជាអាទិ៍នឹងត្រូវចាត់ទុកជាមោឃៈ។ ការបន្ថែម ការលុប ឬ ការកែប្រែផ្សេងទៀត នៅក្នុងមតកសាសន៍ដោយលិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំមិនបានបង្ហាញនូវទីកន្លែង ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះ ជាពិសេសបើមិនបានចុះហត្ថលេខាទេ[30]។ ប្រសិនបើមតកជនមិនបានគោរពតាមល័ក្ខខ័ណ្ឌនេះទេ សន្តតិកម្មមិនមានអានុភាពនោះទេដូច្នេះសន្តតិកម្មនឹងបែងចែកតាមច្បាប់វិញ។

**ដំណាក់កាលនៃការបែងចែកមត៌ក** ក្នុងរបបសន្តតិកម្មសន្តតិជនរបស់មតកជនអាចទទួលបានទ្រព្យពីសន្តតិកម្មបានតាមពីររបៀបគឺសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍។ នៅក្នុងការរបៀបនៃការផ្ទេរនេះ មតកជននៅពេលដែលមានជីវិតអាចជ្រើសរើសរបៀបនៃការផ្ទេរទ្រព្យសម្បត្តិតាមឆន្ទៈរបស់ខ្លួនបាន(សន្តតិកម្មតាមមតកសាសន៍)។ នៅក្នុងករណីដែលមតកជនមានសន្តតិជនណាម្នាក់ដែលខ្លួនស្រលាញ់និងពេញចិត្តជាងគេគាត់អាចធ្វើបណ្តាំសម្រាប់សន្តតិជននោះបានដោយមតកជនអាចជ្រើសរើសប្រភេទបណ្តាំណាមួយដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ២០០៧ ដើម្បីអោយឆន្ទៈរបស់ខ្លួនមានអានុភាពអនុវត្តនៅពេលដែលខ្លួនបានទទួលមរណភាពទៅនោះ ប៉ុន្តែនៅក្នុងករណីដែលមតកជនមិនបានអើពើនៅក្នុងការធ្វើបណ្តាំទេ ឬបានធ្វើបណ្តាំហើយប៉ុន្តែបណ្តាំនោះមិនមានអានុភាពតាមផ្លូវច្បាប់នោះសន្តតិកម្មនឹងអនុវត្តតាមច្បាប់។ នៅក្នុងសន្តតិកម្ម បញ្ហាវិវាទអាចកើតមានឡើងនៅពេលដែលមតកជនមិនមានលិខិតបណ្តាំមួយដែលអាចទុកចិត្តបានសម្រាប់ធ្វើការបែងចែកមត៌ក។ បញ្ហាវិវាទរវាងបងប្អូនកើតមានជាញឹកញាប់នៅក្នុងសង្គមកម្ពុជា វិវាទមត៌កបានធ្វើអោយគ្រួសារមួយចំនួនបានប្រព្រឹត្តអំពើហិង្សាលើគ្នាទៅវិញទៅមក មានករណីខ្លះបានធ្វើអោយពួកគេប្រព្រឹត្តអំពើមនុស្សឃាតលើគ្រួសារខ្លួនឯងនៅក្នុងដំណាក់កាលនៃការពិភាក្សាបែងចែកមត៌ក។ យោងតាមក្រមរដ្ឋប្បវេណីនៅក្នុងដំណាក់កាលនៃការពិភាក្សាបែងចែកមត៌ក ជាដំណាក់កាលមួយដែលច្បាប់អនុញ្ញាតអោយសហសន្តតិជនទាំងអស់ពិភាក្សាគ្នាលើចំណែកមត៌ករបស់មតកជនដែលមាន និងចែកគ្នាតាមការព្រមព្រៀងបន្ទាប់ពីអំឡុងពេល ១ (មួយ) ខែ បានកន្លងផុតក្រោយពីចាប់ផ្តើមសន្តតិកម្ម[31]។ បន្ទាប់ពីបានធ្វើការពិភាក្សាបែងចែកមត៌កហើយ ប្រសិនបើការពិភាក្សារវាងសហសន្តតិជនពុំបានសម្រេចលទ្ធផលទេនោះសន្តតិជនណាម្នាក់ក៏បានអាចដាក់ពាក្យសុំទៅតុលាការអោយធ្វើការបែងចែកមត៌កនោះបាន[32]។ ទោះបីជាមានបទបញ្ញត្តិដូចនេះក៏ដោយនៅក្នុងការពិភាក្សាបែងចែកមត៌កនៅក្នុងសង្គមកម្ពុជានៅតែមានវិវាទដែលបង្កជាជម្លោះផ្សេងៗនៅក្នុងគ្រួសារ។ នៅត្រង់ចំណុចនេះបញ្ជាក់ថា ការដោះស្រាយបញ្ហាសន្តតិកម្មរបស់ប្រជាជនកម្ពុជា ជាការដោះស្រាយនៅក្នុង

[30] មាត្រា ១១៧៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧

[31] មាត្រា ១២៦៦ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧ កថាខណ្ឌទី១

[32] មាត្រា ១២៧០ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧ កថាខណ្ឌទី១

វង្វេងគ្រួសារនៅឡើយ ដោយមិនមានអាជ្ញាធរមានសមត្ថកិច្ចចូលរួមនៅក្នុងវិវាទរបស់ពួកគេទេ ដូច្នេះហើយបានជាពួកគេអាចឈានទៅការប្រើប្រាស់អំពើហិង្សា។ មូលហេតុនេះបានធ្វើអោយសង្គមគ្មានសន្តិសុខ និងសណ្តាប់ធ្នាប់។

**ដំណាក់កាលនៃការទទួលបានទ្រព្យពីសន្តតិកម្ម** ក្នុងកំឡុងពេលនៃការពិភាក្សាបែងចែកមត៌កប្រសិនបើសហសន្តតិជនទាំងអស់បានព្រមព្រៀងគ្នាក្នុងការចែកចំណែកតាមការពិភាក្សានោះបញ្ហាជម្លោះក្នុងគ្រួសារនឹងមិនអាចកើតមាននោះទេតាមរយៈសន្តតិកម្មតាមច្បាប់ និងប្រសិនបើមានមកតសាសន៍។ ប៉ុន្តែនៅក្នុងមត៌ករបស់មតកជន ដែលផ្តល់អោយសន្តតិជនមិនមែនសុទ្ធតែជាទ្រព្យដែលអាចផ្តល់ប្រយោជន៍អោយសន្តតិជនទាំងអស់នោះទេ ព្រោះប្រសិននៅពេលដែលនៅមានជីវិតមតកជនមានជាប់កាតព្វកិច្ចនោះនៅពេលដែលបន្តមត៌កនោះហើយ កាតព្វកិច្ចនឹងត្រូវបន្តដោយសន្តតិជនដែលបានទទួលបន្តនូវបំណុលរបស់មតកជន។ នៅក្នុងករណីខ្លះទ្រព្យសម្បត្តិដែលបានមកពីមតកជននោះ មិនទាន់នឹងបានប្រើប្រាស់ដោយសន្តតិជនផងក៏ត្រូវម្ចាស់បំណុលធ្វើការទាមទារ ឬក្នុងករណីខ្លះទៀតម្ចាស់បំណុលអាចនឹងទាមទារទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិផ្ទាល់របស់សន្តតិជនក៏មាន។ នៅក្នុងប្រព័ន្ធសន្តតិកម្មនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិដោយយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិមកធ្វើមូលដ្ឋាន។ គោលការណ៍ទទួលដោយបន្តស្វ័យប្រវត្តិ គឺជាគោលការណ៍ដែលសន្តតិជនត្រូវទទួលទាំងស្រុងនូវសិទ្ធិ និងករណីយកិច្ចទាំងអស់របស់មតកជន។ តាមរយៈគោលការណ៍នេះសន្តតិជនបានទទួលបន្តនូវឋានៈរបស់មតកជនតែម្តង។ នៅក្នុងករណីដែលមតកជនបានបន្សល់ទុកនូវកាតព្វកិច្ចច្រើនពេកនោះសន្តតិជនដែលទទួលកាតព្វកិច្ចនឹងត្រូវខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងរ ដូច្នេះហើយបានជានៅក្នុងប្រព័ន្ធសន្តតិកម្មបង្កើតអោយមានរបបបោះបង់នូវសន្តតិកម្ម ឬការយល់ព្រមទាំងស្រុង ឬការយល់ព្រមដោយកម្រិត។ ដូច្នេះប្រសិនបើសន្តតិជនមិនអាចដឹងថា ទ្រព្យរបស់មតកជនជាទ្រព្យមានកាតព្វកិច្ច ឬអត់នោះវាជាបញ្ហាមួយដែលនាំអោយសន្តតិជននោះនឹងទទួលរ៉ាប់រងបំណុលរបស់មតកជន ដូច្នេះមុនទទួលយកមត៌កតាមរយៈសន្តតិកម្មសន្តតិជនគួរតែកំណត់ពីទ្រព្យរបស់មតកជនមានទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម។

**២. ផលប្រយោជន៍នៃការផ្លាស់ប្តូរមន្ត្រីពីសង្គមចាស់ ទៅជាសារការីនៅក្នុងសន្តតិកម្ម**

នៅក្នុងសម័យបារាំង និងសង្គមរាស្ត្រនិយមដូចដែលបានរៀបរាប់រួចមកតាំងពីដើមមក ក្នុងរបបសន្តតិកម្មមេឃុំជាអ្នកដែលមានសមត្ថកិច្ចនៅក្នុងការជួយសម្រួលបញ្ហាសន្តតិកម្មជាពិសេសនោះគឺ មុខងារនៅក្នុងការសរសេរលិខិតបណ្តាំ ព្រមទាំងលិខិតមួយចំនួនទៀតដែលជាតម្រូវការនៅក្នុងសន្តតិកម្ម។ ប៉ុន្តែនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ននេះ សមត្ថកិច្ចមន្ត្រីដែលចូលរួមនៅក្នុងសន្តតិកម្មត្រូវបានផ្លាស់ប្តូរពីមេឃុំ មកជាសារការីវិញ។ តាមរយៈការផ្លាស់ប្តូរនៅមន្ត្រីទទួលបន្ទុកនៅក្នុងបញ្ហាសន្តតិកម្មនេះ ពិតជាបាននាំមកនូវផលប្រយោជន៍ជាច្រើនចំពោះរបបសន្តតិកម្ម។ ហេតុអ្វី? ដោយហេតុថាយោងតាមបញ្ញត្តិស្តីពីសន្តតិកម្មដែលមានចែងនៅក្នុងក្រម

រដ្ឋប្បវេណីឆ្នាំ១៩២០ក្តី និងសន្តតិកម្មដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីបច្ចុប្បន្នក្តី មន្ត្រីដែលចូលរួមនៅក្នុងប្រតិបត្តិការសន្តតិកកម្ម គឺមានតួនាទីធ្វើយ៉ាងណាដើម្បីអោយការផ្ទេរទ្រព្យរបស់បុគ្គលដែលបានទទួលមរណភាព ទៅសន្តតិជនរបស់ខ្លួនដោយមានភាពស្រុះស្រួល និងគ្មានវិវាទនឹងគ្នាទៅវិញទៅមក។ ជាពិសេសធានាឱ្យបានថា ឆន្ទៈរបស់មតកជនក្នុងការចាត់ចែងទ្រព្យក្នុងកំឡុងពេលដែលខ្លួននៅមានជីវិតនឹងត្រូវបានគោរពនៅពេលដែលខ្លួនបានស្លាប់ទៅ។ ដូច្នេះការដាក់មុខងារអោយសារការី ប្រតិបត្តិនៅក្នុងសន្តតិកម្មពិតជាមានសារៈសំខាន់ណាស់ ព្រោះសារការីជាអ្នកដែលមានវិជ្ជាជីវៈផ្នែកច្បាប់មួយរូបដែលមានចំណេះដឹងគ្រប់គ្រាន់។ បើយើងធ្វើការប្រៀបធៀបវិជ្ជាជីវៈសារការី និងមេឃុំនៅក្នុងសម័យមុន យើងក៏អាចទាញបានថាសារការីអាចមានសមត្ថភាពផ្នែកច្បាប់ជាងមេឃុំ។ ដូចដែលបានរៀបរាប់ពីខាងដើមមកហើយ ទោះបីជានៅក្នុងសម័យបារាំងក្តីមុននឹងបុគ្គលម្នាក់អាចក្លាយបេក្ខជនសារការីបានត្រូវបំពេញតាមទម្រង់ដែលច្បាប់បានកំណត់ (កថាខណ្ឌទី១ ស្តីពីប្រវត្តិនៃតួនាទីសារការី និងសន្តតិកម្ម) ដោយសារមានជំនាញផ្នែកច្បាប់ច្បាស់លាស់ធ្វើអោយសារការីអាចអនុវត្តមុខងារនៅក្នុងសន្តតិកម្មបានយ៉ាងងាយស្រួលដល់អតិថិជនរបស់ខ្លួន ជាពិសេសនោះគឺរាល់មូលដ្ឋានច្បាប់ដែលមានចែងនៅក្នុងច្បាប់សន្តតិកម្ម ដែលធ្វើអោយបណ្តាំដែលជាឆន្ទៈចុងក្រោយរបស់មតកជនទទួលបាននូវការគោរពយ៉ាងមានប្រសិទ្ធិភាពខ្ពស់។ ចំពោះមេឃុំដែលជាអ្នកមានសម្ថភាពក្នុងប្រតិបត្តិការសន្តតិកម្មពីមុននោះ ពួកយើងយល់ឃើញថា គាត់មិនទាន់មានសមត្ថភាពគ្រប់គ្រាន់ចំពោះការអនុវត្តមុខងារនៅក្នុងរបបសន្តតិកម្មនោះទេ។ តួយ៉ាងដូចជានៅក្នុងតួនាទីចំពោះការបង្កើតលិខិតបណ្តាំជាអាទិ៍ គឺតម្រូវឱ្យមានការប្រឹក្សាផ្នែកច្បាប់ និងត្រួតពិនិត្យល័ក្ខខ័ណ្ឌជាច្រើនទៀតដែលច្បាប់បានកំណត់ជាមុនសិនទើបអាចឈានទៅដល់ការបង្កើតលិខិតបណ្តាំមួយដែលមានភាពត្រឹមត្រូចអាចយកទៅអនុវត្តបាន ដូច្នេះទាមទារឱ្យមានចមនេះផ្នែកច្បាប់ខ្ពស់ក្នុងការជួយសម្រួលបញ្ហាសនតតិកម្មនេះ។ ការបញ្ចូលវត្តមានសារការីនៅក្នុងសន្តតិកម្មដូច្នេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ព្រោះកាលណាមានមន្ត្រីដែលមានជំនាញពិតប្រាកដនៅក្នុងសន្តតិកម្ម អាចធ្វើអោយមានសារៈប្រយោជន៍ជាខ្លាំងចំពោះមតកជន និងជនដទៃទៀតដែលត្រូវមកទទួលសន្តតិកម្មបន្ត។ ចំពោះសារការីសារការីនៅក្នុងបញ្ហាសន្តតិកម្មពួកខ្ញុំសូមធ្វើការលម្អិតខ្លឹមសារនៅក្នុងជំពូកទី២ជាបន្តបន្ទាប់ទៀត ។

## ផ្នែកទី៣៖ ទំនួលខុសត្រូវរបស់សារការី

### កថាខណ្ឌទី១៖ ភាតព្វកិច្ចសារការី

#### ១. ភាតព្វកិច្ចផ្តល់យោបល់

សារការី មានករណីយកិច្ចក្នុងការបំភ្លឺ ឱ្យដំណឹង និងដំបូន្មានដល់គូភាគីនៃលិខិតអំពីកាតព្វកិច្ចនីមួយៗដែលមានចែងនៅក្នុងកិច្ចសន្យា ឬលិខិតផ្សេងៗរបស់ពួកគេ ព្រមទាំងផលវិបាក ឬអានុភាពគតិយុត្តិនៃលិខិត ឬកិច្ចសន្យាទាំងនោះ មុននឹងពួកគេសម្រេចចិត្តចុះហត្ថលេខាទៅលើលិខិតនោះ ដូច្នេះហើយសារការីក៏ត្រូវមានករណីយកិច្ចកត់ចុះក្នុងលិខិត ឬកិច្ចសន្យា នូវភាពត្រឹមត្រូវតាមការពិត និងផ្ទៀងផ្ទាត់មើលភាពត្រឹមត្រូវស្រប

ច្បាប់នៃឆន្ទៈរបស់គូភាគីនៃលិខិត ឬកិច្ចសន្យានោះផងដែរ មុននឹងធ្វើការផ្តល់យថាភូតភាពលើលិខិតនោះទាំងឡាយរបស់អតិថិជន។

**២. ភាតព្វកិច្ចគោរពការសម្ងាត់វិជ្ជាជីវៈ**

នៅក្នុងការគោរពនូវការសម្ងាត់នេះជាបញ្ហាដែលសំខាន់ទាំងសារការី និងភាគីក្នុងបណ្តាំ ព្រោះជាការរក្សាបាននូវភាពមានសណ្តាប់ធ្នាប់ របៀបរៀបរយ ក្នុងន័យនេះសារការីមានកាតព្វកិច្ច រក្សាការសម្ងាត់វិជ្ជាជីវៈ[33]ដូចគ្នានឹងវិជ្ជាជីវៈមេធាវីផងដែរ។ បានន័យថាសារការីត្រូវអនុប្បវាទក្នុងការផ្តល់ព័ត៌មានទៅបុគ្គលដទៃ ក្រៅពីគូភាគីនៃលិខិត សន្តតិជន សិទ្ធិវ័ន្ត អាណត្តិគាហក របស់ពួកគេ ឬបុគ្គលដែលបានអនុញ្ញាតដោយច្បាប់ ឬតាមសេចក្តីសម្រេចរបស់តុលាការ។

**កថាខណ្ឌទី២៖ ទំនួលខុសត្រូវចំពោះកំហុសវិជ្ជាជីវៈ**

**១. ផ្នែករដ្ឋប្បវេណី**

ស្ថិតក្នុងដំណាក់កាលនេះ ការធានារ៉ាប់រងផ្នែកហិរញ្ញវត្ថុចំពោះកំហុសវិជ្ជាជីវៈសារការីដល់អតិថិជន រាល់មន្ទីរសារការី និងសារការី ដែលត្រូវបង្កើតឡើង និងតែងតាំងត្រូវតម្កល់ប្រាក់ នៅធនាគារជាតិនៃកម្ពុជា ដើម្បីធានានូវការប្រកបវិជ្ជាជីវៈរបស់ខ្លួនឱ្យបានល្អប្រសើរ ដូចទៅតាមគោលការណ៍ទាំងឡាយដែលមានចែងនៅក្នុងអនុក្រិត្យស្តីពីការបង្កើតមន្ទីរសារការីនីមួយៗ។ តួយ៉ាងនាពេលបច្ចុប្បន្ននៅក្នុងកម្ពុជា ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីរបស់សារការីអាចធ្វើឡើងតាមរយៈទឹកប្រាក់ ដែលមន្ទីរសារការីនីមួយៗដាក់តម្កល់នៅក្នុងកំឡុងពេលដែលមន្ទីរសារការីនោះបំពេញដំណើរការលើកិច្ចគតិយុត្ត។ នៅពេលចាប់ផ្តើមប្រតិបត្តិការសកម្មភាពរបស់ខ្លួន មន្ទីរសារការី ត្រូវតម្កល់ទឹកប្រាក់ចំនួន ៦០០.០០០.០០០រ (ប្រាំមួយរយលាន) រៀល នៅធនាគារជាតិនៃកម្ពុជា សម្រាប់ទំនួលខុសត្រូវក្នុងការបំពេញមុងងាររបស់ខ្លួន ចំនួននៃប្រាក់តម្កល់នេះមានចែងនៅគ្រប់អនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីទាំងអស់នៅកម្ពុជា។ ចំនួនទឹកប្រាក់នៃការតម្កល់នេះ ចាំបាច់ណាស់សម្រាប់ការធានានិរន្តរភាពនៃការការពារផលប្រយោជន៍របស់អតិថិជនរបស់ខ្លួន នៅក្នុងករណីដែលការបំពេញកិច្ចរបស់សារការីធ្វើឱ្យសន្តតិជនបាត់បង់នូវផលប្រយោជន៍ដែលកើតចេញពីកំហុសរបស់សារការី។

**២. ផ្នែកព្រហ្មទណ្ឌ**

សារការី មិនអាចទទួលបានអភ័យឯកសិទ្ធចំពោះបទល្មើសព្រហ្មទណ្ឌបានឡើយ។ បន្ថែមពីនេះសារការីទទួលបន្ទុកជាអ្នករាយការណ៍[34] នូវរាល់ប្រតិបត្តិការណ៍ដែលមានការជាប់សង្ស័យទាក់ទង នឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ បើមិនដូច្នេះទេ សារការីត្រូវទទួលខុសត្រូវចំពោះទណ្ឌកម្មវិន័យ និងទណ្ឌកម្មព្រហ្មទណ្ឌជាមិនខាន។ ចំពោះទណ្ឌកម្មវិន័យ ស្ថាប័នត្រួតពិនិត្យអាចដាក់ទណ្ឌកម្មទៅលើសារការីដែលមិនបានរាយការណ៍ដោយធ្វើការព្រមាន ការស្តីបន្ទោស ការហាមឃាត់ ការដាក់កំហិតមិនឱ្យធ្វើប្រតិបត្តិការ ការដកអាជ្ញា

[33] មាត្រា ១៣ នៃព្រះរាជក្រម ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ ស្តីពីលក្ខន្តិកៈសារការីនៅក្នុងព្រះរាជាណាចក្រកម្ពុជា

[34] មាត្រា ៤ ចំណុច ដ នៃច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧

ប័ណ្ណអាជីវកម្ម មុខតំណែង ផាកពិន័យ ដូចជាការប្តឹងទៅតុលាការនៅពេលដែលមានការរំលោភទៅលើបទប្បញ្ញត្តិនៃច្បាប់នេះដែលនាំឱ្យមានការប៉ះពាល់ដល់សាធារណៈជន និងសន្តិសុខជាតិ[35]។ មិនតែប៉ុណ្ណោះនៅក្នុងទណ្ឌកម្មព្រហ្មទណ្ឌ ដោយពុំទាន់គិតពីបទល្មើសទាំងឡាយដែលមានបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌផ្សេងទៀតៈ

- បុគ្គលដែលបដិសេធការផ្តល់ពត៌មានដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ និងស្ថាប័នត្រួតពិនិត្យដូចមានចែងនៅក្នុងមាត្រា ៦ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ថ្ងៃ ដល់ ១ ខែ និងផ្តន្ទាទោសពិន័យជាប្រាក់ពីមួយសែនរៀល (១០០.០០០ រៀល) ដល់ មួយលានរៀល (១.០០០.០០០រៀល) ឬ ទោសណាមួយនៃទោសទាំងពីរ។
- បុគ្គលណាដែលមិនបានធ្វើរបាយការណ៍អំពីប្រតិបត្តិការណ៍សាច់ប្រាក់ ឬប្រតិបត្តិការណ៍សង្ស័យទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុដូចមានចែងនៅក្នុងមាត្រា ១២ ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ១ ខែ ដល់ ១ ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល(១.០០០.០០០រៀល) ដល់ ប្រាំលានរៀល (៥.០០០.០០០រៀល) ឬទោសណាមួយនៃទោសទាំងពីរ។
- បុគ្គលណាដែលមានកាតព្វកិច្ចផ្តល់ពត៌មាន ឬរបាយការណ៍ដូចមានចែងក្នុងមាត្រា ១៣ ឬបុគ្គលដែលបានដឹងរឿង ហើយផ្តល់ពត៌មាន ឬរបាយការណ៍ល្មើសនឹងបទបញ្ញត្តិនៃការហាមឃាត់ការផ្តល់ព័ត៌មានដូចមានចែងក្នុងមាត្រា ១៥ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ដល់ ១ ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល(១.០០០.០០០រៀល) ដល់ ប្រាំលានរៀល(៥.០០០.០០០រៀល) ឬទោសណាមួយនៃទោសទាំងពីរ។
- បុគ្គលណាដែលបានរំលោភកាតព្វកិច្ចរក្សាការសម្ងាត់ដូចមានចែងនៅក្នុងមាត្រា ២៣ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ដល់ ១ ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល(១.០០០.០០០ រៀល) ដល់ ប្រាំលានរៀល(៥.០០០.០០០រៀល) ឬទោសណាមួយនៃទោសទាំងពីរ។

ទាំងនេះមានន័យថា សារការីជាមន្ត្រីសាធារណៈដែលត្រូវបានផ្តន្ទាទោសពិន័យ និងទោសដាក់ពន្ធនាគារដូចទៅនឹងមន្ត្រីសាធារណៈដទៃទៀតដែរ កាលណាខ្លួនបានប្រព្រឹត្តខុសក្នុងការប្រតិបត្តិតួនាទីចំពោះអតិថិជនឬមួយមានប្រការណាមួយដែលបានអនុវត្តខុសឆ្គងនៅក្នុងនីតិវិធី ហើយម្យ៉ាងទៀតការចាត់ចែងក្នុងកិច្ចផ្តន្ទាទោសទៅលើសារការីនេះក៏ត្រូវបានដោយបំពេញកិច្ចដោយប្រធានមន្ទីរសារការីផងដែរ មានន័យថាប្រធានមន្ទីរសារការីអាចចាត់វិធានការណ៍ដល់សារការីដែលមានកំហុសនោះទៅតាមមន្ទីរនីមួយៗ។

[35] មាត្រា ២៨ នៃច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧

# ជំពូកទី២

# សារៈប្រយោជន៍សារការីចំពោះសន្តតិកម្ម

# ជំពូកទី២

# សារៈប្រយោជន៍សារការីចំពោះសន្តតិកម្ម

តាមរយៈការអនុវត្តមុខងាររបស់សារការីនៅក្នុងសន្តតិកម្មដែលបានផ្តល់ផលប្រយោជន៍ដល់សន្តតិកម្មជាខ្លាំង។ នៅក្នុងបញ្ញត្តិស្តីពីសន្តតិកម្ម គោលបំណងធ្វើយ៉ាងណាឱ្យសន្តតិជនម្នាក់ៗ ឬជនដែលទាក់ទងនឹងផលប្រយោជន៍ផ្សេងទៀតទទួលបាននូវផលប្រយោជន៍ដែលខ្លួនគួរទទួលបានតាមចំនួនសមាមាត្រ ដោយគ្មានការគ្មានការបំពានសិទ្ធិ។ ជាពិសេសប្រសិនកាលបើមតកជននៅមានជីវិត បានបង្ហាញឆន្ទៈចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន នោះសារការីក៏បានចូលរួមចំណែកឱ្យឆន្ទៈដែលបានបានបង្ហាញនោះត្រូវបានគោរពនៅពេលដែលមតកជនលាចាកលោកទៅ។ នៅក្នុងសន្តតិកម្ម ប្រតិបត្តិការដែលសារការីត្រូវបំពេញ បានផ្តល់ផលប្រយោជន៍គ្រប់ដំណាក់កាលនៃមុខងាររបស់ខ្លួន តាំងពីពេលមុនចាប់ផ្តើមសន្តតិកម្ម រហូតដល់ការបែងចែកចំណែកមត៌ករួចរាល់។ ទោះបីជាសារការីបានផ្តល់ឱ្យនូវប្រយោជន៍ជាច្រើននៅក្នុងសន្តតិកម្មប៉ុន្តែនៅក្នុងប្រតិបត្តិការរបស់សាការី នៅក្នុងសន្តតិកម្មកំពុងជួបនឹងបញ្ហាមួយចំនួនផងដែរ។ ដូច្នេះហើយដើម្បីឱ្យកាន់តែមានលក្ខណៈច្បាស់លាស់ពីសារៈប្រយោជន៍សារការីនៅក្នុងសន្តតិកម្មតាមដំណាក់កាលនៃមុខងារនីមួយៗនៅក្នុងជំពូកទី២នេះ ពួកយើងសូមបង្ហាញនូវ៣ ផ្នែកគឺ៖ **ផ្នែកទី១៖ មុខងាររបស់សារការីមុនចាប់ផ្តើមសន្តតិកម្ម ផ្នែកទី២៖ មុខងារសារការីនៅពេលសន្តតិកម្មចាប់ផ្តើម**និ ងដោយសារតែការអនុវត្តមុខងារបច្ចុប្បន្នរបស់សារការីកំពុងមានបញ្ហាប្រឈមមួយចំនួនដូច្នេះហើយ **ផ្នែកទី៣៖ សារៈប្រយោជន៍ និងបញ្ហាប្រឈមការអនុវត្តមុខងារសារការីនៅក្នុងសន្តតិកម្ម**។

## ផ្នែកទី១៖ មុខងាររបស់សារការីមុនចាប់ផ្តើមសន្តតិកម្ម

### កថាខណ្ឌទី១៖ ការផ្តល់ប្រឹក្សាផ្នែកច្បាប់

#### ១. ការប្រឹក្សាយោបល់

នៅក្នុងការបំពេញមុខងារសារការីមុនតាក់តែងលិខិតយថាភូត សារការីមានតួនាទីក្នុងការបំភ្លឺ ការផ្តល់ព័ត៌មាន និងការផ្តល់ការប្រឹក្សាដល់ភាគីជាមុនសិន។ ដោយហេតុថា នៅក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃ ម្ចាស់បណ្តាំដែលបានទៅរកសារការីឱ្យជួយសុទ្ធតែជាបុគ្គល ដែលមិនមានចំណេះដឹងទូលំទូលាយខាងវិស័យច្បាប់ឱ្យបានច្បាស់លាស់នោះ ដូច្នេះទាមទារឱ្យសារការីធ្វើយ៉ាងណាឱ្យម្ចាស់បណ្តាំយល់ដឹងអំពីទិដ្ឋភាពផ្នែកច្បាប់ដោយសារការីមានកាតព្វកិច្ចពន្យល់ខ្លឹមសារនៃច្បាប់ដល់ម្ចាស់បណ្តាំ។ សារការី ត្រូវតែផ្តល់យោបល់ឱ្យម្ចាស់បណ្តាំ ប្រសិនបើខ្លឹមសារនៃមតកសាសន៍នោះមានលក្ខណៈផ្ទុយនឹងទម្រង់ដែលច្បាប់បានកំណត់ដែលអាចធ្វើឱ្យបណ្តាំទទួលរងនូវមោឃភាព។ គោលដៅនៃបណ្តាំដែលឱ្យមានការចូលរួមពីសារការី គឺជាបណ្តាំមួយដែលមានអានុភាពយកទៅអនុវត្តបានដូច្នេះការប្រឹក្សាយោបល់ជាមួយម្ចាស់បណ្តាំជាកិច្ចការចម្បង។ សារការីបំពេញ

តួនាទីរបស់ខ្លួនដោយឯករាជ្យ មិនលំអៀងទៅរកភាគីណាមួយនោះទេ។ សារការីអនុវត្តមុខងាររបស់ខ្លួនធ្វើយ៉ាងណាឱ្យបាននូវគោលដៅ ៣៖ តុល្យភាព ប្រសិទ្ធភាព និងសុវត្ថិភាពគតិយុត្ត។ គោលដៅនេះគឺជាអ្វីដែលបង្ហាញថា ការប្រឹក្សាយោបល់ជាមួយសារការីជា ជំហានដែលអាចជឿទុកចិត្តបានដល់អតិថិជន ក៏ដូចជាអ្នកពាក់ពន្ធក្នុងមត៌កសាសន៍នោះផងដែរ ការប្រឹក្សាយោបល់ជូនម្ចាស់បណ្តាំក្នុងបញ្ហាសន្តតិកម្ម គឺជាតួនាទីមួយរបស់សារការី ក្នុងការជួយសន្តតិជនជុំវិញបញ្ហាដែលអាចកើតមានឡើងនៅពេលដែលសន្តតិកម្មចាប់ផ្តើមក្នុងកិច្ចការប្រឹក្សានេះ យើងនឹងធ្វើការបង្ហាញពីដំណាក់កាលមួយម្តងៗដែលសារការីបានបំពេញ។ មុនការតាក់តែងលិខិតបណ្តាំសារការីត្រូវពន្យល់ប្រាប់ម្ចាស់បណ្តាំអំពីរបៀបនៃការតាក់តែងមតកសាសន៍ដូចជា ៖ **ការពិភាក្សាលើមូលដ្ឋានច្បាប់ដែលមាននៅក្នុងសន្តតិកម្ម**សារការីអាចធ្វើការពិភាក្សាលើមូលដ្ឋានច្បាប់ដែលមាននៅក្នុងសន្តតិកម្មបានចំពោះជនគ្រប់រូបដែលមានបំណងចង់ធ្វើបណ្តាំ។ ទោះបីជាជនដែលមកពិភាក្សាមិនមានបំណងឱ្យសារការីជាអ្នកតាក់តែងលិខិតបណ្តាំនោះក្តីក៏សារការីអាចប្រឹក្សាយោបល់ជូនផងដែរ ព្រោះនៅតាមមន្ទីរសារការីនីមួយៗមានមុខងារប្រឹក្សាយោបល់ផ្នែកច្បាប់ជូនជនគ្រប់រូប ដែលត្រូវការនូវមូលដ្ឋានរឹងមាំក្នុងផ្លូវច្បាប់។ ជាក់ស្តែងប្រសិនបើម្ចាស់បណ្តាំមិនបានដឹងថា តើគាត់អាចធ្វើបណ្តាំបានតាមរបៀបណាខ្លះដើម្បីឱ្យបណ្តាំនោះជាបណ្តាំមួយដែលត្រឹមត្រូវ និងឱ្យសន្តតិជនអនុវត្តបានដោយគ្មានវិវាទ? នៅក្នុងករណីនេះប្រសិនបើម្ចាស់បណ្តាំជ្រើសយកសារការីជាអ្នកប្រឹក្សាយោបល់ នោះសារការីនឹងប្រាប់ដល់ម្ចាស់បណ្តាំប្រភេទនៃបណ្តាំដែលម្ចាស់បណ្តាំអាចជ្រើសយកប្រភេទបណ្តាំណាមួយដែលម្ចាស់បណ្តាំត្រូវការ។ ឧទាហរណ៍ សារការីអាចប្រាប់ម្ចាស់បណ្តាំពីទម្រង់នៃបណ្តាំ ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីដូចជា បណ្តាំធ្វើឡើងដោយលិខិតឯកជន(មតកសាសន៍ដោយលិខិតឯកជន មាត្រា ១១៧៤) បណ្តាំដែលធ្វើឡើងដោយលិខិតយថាភូត (មតកសាសន៍ដោយលិខិតយថាភូត មាត្រា ១១៧៣) ឬបណ្តាំដែលធ្វើឡើងដោយលិខិតសម្ងាត់ (មតកសាសន៍ដោយលិខិតសម្ងាត់មាត្រា ១១៧៤) ជាអាទិ៍។ នៅក្នុងទម្រង់នៃមតកសាសន៍នីមួយៗ តែងតែមានល័ក្ខខ័ណ្ឌនៅក្នុងការតាក់តែង។ ប្រសិនបើអ្នកតាក់តែងមិនបានគោរពទេ បណ្តាំដែលបានបន្សល់ទុកនោះមិនមានអានុភាពឡើយ។ ដូច្នេះសារការីត្រូវប្រាប់ម្ចាស់បណ្តាំឱ្យមានការប្រុងប្រយ័ត្នចំពោះល័ក្ខខ័ណ្ឌទាំងនេះ។ តាមការអនុវត្តជាក់ស្តែងបើម្ចាស់បណ្តាំ ប្រគល់មុខងារឱ្យសារការីជាអ្នកតាក់តែងលិខិតបណ្តាំ (មតកសាសន៍ដោយលិខិតយថាភូត)នោះ ល័ក្ខខ័ណ្ឌដែលមាននៅក្នុងច្បាប់ទាំងនេះមិនចោទជាបញ្ហានោះទេ ព្រោះមានសារការីជាអ្នកត្រួតពិនិត្យរាល់ឆន្ទៈមតកជន និងបទបញ្ញត្តិនៃច្បាប់។ ជាគោលការណ៍ល័ក្ខខ័ណ្ឌទាំងនេះបង្កើតឡើងក្នុងគោលបំណងធ្វើយ៉ាងណា ឱ្យមានភាពពិតប្រាកដថាបណ្តាំនោះជាបណ្តាំ ដែលបានធ្វើឡើងដោយឆន្ទៈរបស់ម្ចាស់បណ្តាំពិតប្រាកដមែននៅពេលចាប់ផ្តើមសន្តតិកម្ម។ ផ្ទុយមកវិញប្រសិនបើម្ចាស់បណ្តាំបានជ្រើសរើសបណ្តាំជា បណ្តាំដែលធ្វើឡើងដោយខ្លួនឯង(មតកសាសន៍ដោយលិខិតឯកជន) ឬបណ្តាំតាមលិខិតសម្ងាត់នោះ សារការីត្រូវឱ្យម្ចាស់បណ្តាំយល់ពីរបៀបនៃការ

តាក់តែង ជាពិសេសត្រូវប្រាប់អំពីហានិភ័យដែលអាចកើតមានលើបណ្តាំប្រភេទនេះផង។ ឧទាហរណ៍ មតកសាសន៍ដោយលិខិតឯកជន ចំពោះការតាក់តែងសារការីត្រូវតែប្រាប់ល័ក្ខខ័ណ្ឌនៃទម្រង់ដែលមាននៅក្នុងមតកសាសន៍ប្រភេទនេះដូចជា៖ ម្ចាស់បណ្តាំដាច់ខាតត្រូវតែសរសេរបណ្តាំដោយខ្លួនឯងដោយចុះថ្ងៃខែឆ្នាំ និងចុះហត្ថលេខាលើបណ្តាំ។ ជាមួយគ្នានោះដែរសារការីត្រូវបញ្ជាក់ផងដែរថា ប្រសិនបើម្ចាស់បណ្តាំមិនបានសរសេរបណ្តាំដោយខ្លួនឯងទេបណ្តាំនោះមិនមានអានុភាពនោះទេ បណ្តាំត្រូវតែសរសេរដោយផ្ទាល់ដៃម្ចាស់បណ្តាំដោយមិនអនុញ្ញាតឱ្យមានសរសេរដោយម៉ាស៊ីន ដូចជាអង្គុលីលេខផងដែរទោះបីជាម្ចាស់បណ្តាំសរសេរវាលើម៉ាស៊ីនខ្លួនឯងក៏ដោយ។ រាល់ការបន្ថែម ការលុប ឬការកែប្រែផ្សេងៗនៅក្នុងមតកសាសន៍ដោយលិខិតឯកជន ម្ចាស់បណ្តាំត្រូវបង្ហាញនូវទីកន្លែង ត្រូវសរសេរបន្ថែមនូវមូលហេតុនៃការកែប្រែ និងជាពិសេសត្រូវចុះហត្ថលេខា បើពុំដូច្នេះទេលិខិតដែលបានកែនោះនឹងគ្មានអានុភាពឡើយ។ មួយវិញទៀត **ចំណុចដែលត្រូវសរសេរក្នុងមតកសាសន៍** ជាចំណុចសំខាន់នៅក្នុងលិខិតបណ្តាំ។ ជាគោលការណ៍នៅពេលដែលសន្តតិកម្មចាប់ផ្តើមចំណុចដែលបានសរសេរនឹងត្រូវអនុវត្តតាមផងដែរ។ តាមរយៈវត្តមានសារការីសារការីនឹងធ្វើការផ្តល់យោបល់ទៅលើចំណុចដែលម្ចាស់បណ្តាំអាចសរសេរចូលទៅក្នុងលិខិតបណ្តាំនោះ ដើម្បីធ្វើយ៉ាងណាឱ្យមានភាពងាយស្រួលនៅពេលសន្តតិកម្មចាប់ផ្តើម។ នៅក្នុងមតកសាសន៍ចំណុចដែលម្ចាស់បណ្តាំអាចសរសេរមានដូចជា ឈ្មោះសន្តតិជន ការកំណត់ចំណែកមត៌ក ការកំណត់នូវវិធីបែងចែក អច្ច័យទាន និងការកំណត់អ្នកប្រតិបត្តិមតកសាសន៍។ សារការី ផ្តល់នូវដំបូន្មានតាមផ្លូវច្បាប់នានាដើម្បីតម្រូវទៅតាមស្ថានភាពនីមួយៗរបស់ម្ចាស់បណ្តាំ។ ប្រសិនបើសន្តតិជនរបស់ម្ចាស់បណ្តាំដែលបានធ្វើមតកសាសន៍ នោះជាអនីតិជន សារការីអាចផ្តល់ដំបូន្មានក្នុងការតែងតាំងនរណាម្នាក់ ដែលខ្លួនទុកចិត្តឱ្យធ្វើជាអាណាព្យាបាលគ្រប់គ្រងជំនួស រហូតសន្តតិជនមានសមត្ថភាពក្នុងការគ្រប់គ្រងមត៌កនោះទើបធ្វើការបែងចែក។ ក្រៅពីស្ថានភាពនេះ នៅក្នុងករណីដែលមានសន្តតិជនជាជនដែលមានសញ្ជាតិបរទេសផង និងសញ្ជាតិខ្មែរផង សារការីអាចផ្តល់យោបល់ថា ជនបរទេសដែលពុំមានសញ្ជាតិខ្មែរទេពុំមានសិទ្ធិអាចទទួលមត៌កជាដីធ្លីបានទេ។ បើម្ចាស់បណ្តាំ បានធ្វើបណ្តាំដែលមានខ្លឹមសារប្រគល់ដីនោះឱ្យសន្តតិជនដែលពុំមានសញ្ជាតិខ្មែរនោះ ពុំអាចទទួលដីធ្លីនោះទេតាមសន្តតិកម្មបានទេ[36] ដូច្នេះម្ចាស់បណ្តាំគួរតាក់តែងបណ្តាំដោយគិតដល់ចំណុចនេះ។ ម្យ៉ាងវិញទៀតនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ មានសន្តតិជនមួយចំនួនបានធ្វើសកម្មភាពមួយចំនួនដែលធ្វើឱ្យម្ចាស់បណ្តាំមិនពេញចិត្ត។ កាលដែលមតជននៅរស់ គ្មានបំណងឱ្យសន្តតិជនម្នាក់នោះទទួលស្នងនូវរបស់ខ្លួនឡើយ។ ដូច្នេះកំឡុងពេលនៃការពិភាក្សាយោបល់ជាមួយសារការី សារការីនឹងសួរម្ចាស់បណ្តាំថា មានកូនដែលត្រូវផ្តាច់ចេញពីមត៌កដែរទេ។ ប្រសិនបើមានសារ

[36] មាត្រា ១១៥៥ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ កថាខណ្ឌទី១

ការីនឹងប្រាប់អំពីវិធីនៃការផ្តាច់សន្តតិជននោះចេញពីមត៌ក ដោយសារការីប្រាប់ឱ្យមតកជន ដាក់ពាក្យសុំទៅតុលាការឱ្យផ្តាច់ជនដែលត្រូវសន្មតថាជាសន្តតិជននោះចេញពីមត៌ក។ នៅក្នុងករណីដែលមតកជនមិនបានដាក់ពាក្យសុំទៅកាន់តុលាការទេនោះ សន្តតិជននោះនៅតែអាចទាមទារនូវចំណែកមត៌កខ្លួនបាននៅពេលចាប់ផ្តើមសន្តតិកម្ម ទោះបីជាមតកជនបានធ្វើការបែងចែកចំណែកមត៌កដែលមានឱ្យទៅសន្តតិជនផ្សេងទៀតក៏ដោយ។ សន្តតិជនទាំងអស់ដែលមិនមែនជាអ័ព្វបុគ្គល ឬបុគ្គលដែលមិនបានផ្តាច់ចេញពីមត៌កសុទ្ធតែអាចទទួលបានមត៌កពីមតជន ប្រសិនបើមតកជនបានធ្វើបណ្តាំដោយបានបែងចែកទ្រព្យទាំងអស់ សន្តតិជនដែលមិនទទួលបានមត៌កពីបណ្តាំដែលបានបន្សល់ទុកនោះអាចទាមទារទ្រព្យនោះបានតាមការទាមទារភាគបម្រុងពីសន្តតិជនដែលទទួលបានទ្រព្យតាមបណ្តាំនោះបាន។

### ២. ត្រួតពិនិត្យលក្ខណៈសម្បត្តិជនដែលមានវត្តមានក្នុងការធ្វើមតកសាសន៍

ការត្រួតពិនិត្យលក្ខណៈសម្បត្តិជន ដែលមានវត្តមាននៅក្នុងមតកសាសន៍ពិតជាមានសារៈសំខាន់ណាស់ ប្រសិនបើទម្រង់នៃលិខិតមតកសាសន៍ដែលត្រូវបានបង្កើតឡើងដោយសារការី មានជនណាម្នាក់ដែលច្បាប់បានហាមឃាត់មិនឱ្យចូលរួមក្នុងការធ្វើបណ្តាំ នោះនៅពេលចាប់ផ្តើមសន្តតិកម្មមតកសាសន៍ដែលបានបង្កើតដោយសារការីនឹងត្រូវខុសទម្រង់ដែលនាំឱ្យមានវិការៈនឹងធ្វើឱ្យបណ្តាំនោះយកមកអនុវត្តមិនបាន។ ដូច្នេះសារការីត្រូវពិនិត្យឱ្យបានច្បាស់ ទៅលើជនដែលចូលរួមក្នុងការបង្កើតមតកសាសន៍តាមទម្រង់ដែលច្បាប់បានកំណត់។ ជនដែលសារការីត្រូវពិនិត្យរួមមាន៖ **ម្ចាស់បណ្តាំ**មុនដំណាក់កាលនៃការតាក់តែង សារការីត្រូវធ្វើការពិនិត្យអំពីសមត្ថភាពរបស់ម្ចាស់បណ្តាំ ដើម្បីបញ្ជាក់ពីសមត្ថភាពខាងឆន្ទៈក្នុងការធ្វើបណ្តាំរបស់ម្ចាស់បណ្តាំ។ នៅក្នុងដំណាក់កាលនេះសារការី ចាំបាច់ត្រូវតែបញ្ជាក់ឱ្យបានច្បាស់ថាមតកជន គឺជាជនដែលមានសមត្ថភាពខាងឆន្ទៈជាមុនដើម្បីធ្វើមតកសាសន៍[37]។ សមត្ថភាពខាងឆន្ទៈ ជាសមត្ថភាពដែលមតកជនអាចយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ប្រសិនបើមតកជនខ្វះសមត្ថភាពខាងឆន្ទៈសកម្មភាពក្នុងការធ្វើបណ្តាំនោះអាចនឹងត្រូវលុបចោល[38]។ នៅក្នុងករណីដែលបណ្តាំដែលធ្វើឡើងដោយមតកជនដែលខ្វះសមត្ថភាពឆន្ទៈ ប្រសិនបើមានបុគ្គលដែលអះអាងអំពីការខ្វះសមត្ថភាពនោះ បុគ្គលដែលអះអាងនោះត្រូវបញ្ជាក់ភស្តុតាងអំពីហេតុនោះ លើកលែងតែករណីមតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ(មាត្រា ១១៧៦ នៃក្រមរដ្ឋប្បវេណី)។ បុគ្គលដែលអាចធ្វើមតកសាសន៍បានមានដូចជា បុគ្គលដែលជានីតិជន អនីតិជនដែលបានទទួលអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬអំណាចមេបា[39]។ បុគ្គលដែលជាអ

[37] មាត្រា ១១៦៩ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧ កថាខណ្ឌទីទី១

[38] មាត្រា ១៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧

[39] មាត្រា ១១៦៨ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧

នីតិជន បុគ្គលដែលគ្រប់អាយុ១៨ឆ្នាំ ឡើងទៅ[40]។ អនីតិជនដែលទទួលបានការប្រកាសអត្ថាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬអំណាចមេបា គឺជាអនីតិជនដែលទទួលបានការប្រកាសអត្ថាធីនភាពឱ្យរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន (មាត្រា១០៩៥ កថាខណ្ឌទី១) អនីតិជនដែលទទួលបានការប្រកាសអត្ថាធីនភាពឱ្យរួចផុតពីអ្នកមានសិទ្ធិអំណាចមេបា (មាត្រា ២១ កថាខណ្ឌទី១) និងអនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ (មាត្រា ២១ កថាខណ្ឌទី២ និងមាត្រា ១០៩៥ កថាខណ្ឌទី២)[41]។ ចំណែកឯជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភក៏អាចធ្វើមតកសាសន៍បានដែរ នេះបើយោងតាមមាត្រា១១៦៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។ បន្ទាប់ពីម្ចាស់បណ្ដាំ **សាក្សី** ក៏សារការីត្រូវពិនិត្យផងដែរ នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មិនបានកំណត់ថាបុគ្គលប្រភេទណាអាចធ្វើជាសាក្សីបាននោះទេ ប៉ុន្តែគេបានកំណត់អំពីបុគ្គលដែលមិនអាចក្លាយជាសាក្សី[42]។ ក្នុងនោះផងដែរបុគ្គលដែលមិនអាចក្លាយជាសាក្សីមានដូចជាៈ អនីតិជន ជននៅក្រោមអាណាព្យាបាលធម្មតា ឬជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី សហព័ទ្ធ ញាតិលោហិតខ្សែផ្ទាល់របស់ជនទាំងនោះ។ ហេតុនេះយើងអាចនិយាយបានថាក្រៅពីបុគ្គលដែលបានកំណត់ថាមិនអាចក្លាយជាសាក្សីនោះគឺអាចក្លាយជាសាក្សីបាន។ នៅក្នុងន័យនេះចំពោះអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅមិនអាចក្លាយជាសាក្សីបានទេ នេះក៏ដោយសារ សាក្សីជាអ្នកបញ្ជាក់ពីឆន្ទៈពិតប្រាកដរបស់មតកជនថាមតកជនបានធ្វើមតកសាសន៍ពិតមែនឬទេ ដូច្នេះអនីតិជនព្រមទាំងជននៅក្រោមអាណាព្យាបាលទូទៅខ្វះលក្ខណៈសម្បត្តិជានិច្ច ដោយសារជនទាំងនោះមានបញ្ហាខាងសមត្ថភាពចំពោះការធ្វើការបញ្ជាក់នេះ ។ ចំណែកឯជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី សហព័ទ្ធ ញាតិលោហិតខ្សែផ្ទាល់របស់ជនទាំងនោះវិញ ដោយសារពួកគេនឹងត្រូវទទួលបានផលប្រយោជន៍ពីមត៌កនោះតាមមតកសាសន៍ ជនដែលត្រូវសន្មតជាសន្តតិជនអាចទទួលមត៌កច្រើនជាងចំណែកមត៌ករបស់ខ្លួនដែលកំណត់ដោយច្បាប់ ឬផ្ទុយទៅវិញអាចទទួលបានតិចជាង។ អច្ច័យលាភី អាចក្លាយជាអ្នកទទួលមត៌ក ដូច្នេះដោយសារតែទំនាក់ទំនងផលប្រយោជន៍ទាំងនេះអាចនឹងបង្កឱ្យមានបញ្ហាចំពោះសុក្រឹតភាពនៃចម្លើយសាក្សី ទើបច្បាប់មិនអនុញ្ញាតឱ្យជនទាំងនេះធ្វើជាសាក្សី។ នៅក្នុងករណីសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និយោជិតរបស់សារការីនោះមិនអាចធ្វើជាសាក្សីបានទេ ព្រោះដើម្បីធានាសុក្រឹតភាព ដូច្នេះត្រូវតែមានបុគ្គលផ្សេងដែលជាតតិយជនក្រៅពីជនទាំងនេះ។ នៅក្នុងករណី

[40] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧

[41] ឯកសារស្តីពី ការធ្វើសន្តតិកម្មភាគ២ (សន្តតិកម្មតាមមតកសាសន៍) រៀបចំដោយ SHINODA Yoichiro (Attorney at Law Japan)

[42] មាត្រា ១១៧២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧

ដែលមានការសង្ស័យអំពីលក្ខណៈសម្បត្តិជាសាក្សី សារការីអាចស្នើសុំឱ្យសាក្សីផ្តល់ឯកសារ ឬភស្តុតាងបញ្ជាក់អំពីលក្ខណៈសម្បត្តិតាមរយៈ សៀវភៅគ្រួសារ ឬសំបុត្រកំណើត។

### កថាខណ្ឌទី២៖ ការថែរក្សា និងការតម្កល់មតកសាសន៍

#### ១. ការតម្កល់

បន្ទាប់ពីបានតាក់តែងលិខិតមតកសាសន៍រួចរាល់ សារការីត្រូវតែមានកាតព្វកិច្ចនៅក្នុងការតម្កល់លិខិតមតកសាសន៍នៅក្នុងមន្ទីរសារការីរបស់ខ្លួន។ ការរក្សាទុកនូវលិខិតមតកសាសន៍នេះត្រូវតែទុកដាក់ឯកសារឱ្យបានគង់វង្សល្អ។ ក្នុងការតម្កល់ គឺជាចំណុចមួយនៃការធានាបាននូវភាពស្ថិតស្ថេរ ព្រមទាំងមានភាពជឿជាក់ថារាល់ការធ្វើបណ្តាំរបស់មត៌កជនពិតជាគង់វង្ស និងមិនមានអ្វីជាឧបសគ្គ។ ជាទូទៅការរក្សាទុកបណ្តាំធ្វើឱ្យមានភាពច្បាស់លាស់រវាងការធ្វើសន្តតិកម្មដោយសារការី និងភាគីពាក់ពន្ធក្នុងបណ្តាំនៅពេលក្រោយៗទៀត។ នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ការតម្កល់ទុកមតកសាសន៍នៅមន្ទីរសារការីបានផ្តល់សុវត្ថិភាពដល់មតកសាសន៍ពិតប្រាកដមែន។ ជាគោលការណ៍មតកសាសន៍ដោយលិខិតយថាភូត និងមតកសាសន៍ដោយលិខិតសម្ងាត់ដែលបង្កើតឡើងដោយមានវត្តមានសារការីចូលរួម ពោលគឺត្រូវបានតម្កល់ទុកដោយសារការីនៅក្នុងមន្ទីរសារការីនីមួយៗ។ ចំណែកឯមតកសាសន៍ប្រភេទផ្សេងទៀតដែលពុំមានវត្តមានសារការីចូលរួមបង្កើត ក៏អាចយកមតកសាសន៍នោះទៅតម្កល់ទុកជាមួយបានដែរ។ តួនាទីនៅក្នុងការតម្កល់នេះជាតួនាទី និងភារកិច្ចដែលសារការីដែលទទួលបានពីអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីនីមួយៗ។ ជាក់ស្តែងយោងតាមមាត្រា ៤ ចំណុច៩ នៃអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីភ្នំពេញ មន្ទីរសារការីភ្នំពេញមានតួនាទី និងភារកិច្ច ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃកិច្ចសន្យា លិខិតឯកតោភាគីផ្សេងៗ មតកសាសន៍ និងលិខិតស្នាមផ្សេងៗទៀត។ ចំពោះមធ្យោបាយនៃការតម្កល់នេះ មន្ទីរសារការីនីមួយៗអាចប្រើប្រាស់វិធីសាស្ត្រដែលត្រឹមត្រូវណាមួយដើម្បីរក្សាសុវត្ថិភាព និងរៀបចំតាមលំដាប់ដើម្បីឱ្យងាយស្រួលនៅក្នុងការរកមតកសាសន៍នោះ។ ម៉្យាងទៀតការធ្វើដូចនេះក៏ជាប្រសិទ្ធិភាពមួយដែលរក្សាកុំឱ្យបាត់បង់នូវលិខិតគតិយុត្តរបស់មត៌កជនដែលស្របច្បាប់ផងដែរ វិធីសាស្ត្រនៅក្នុងការតម្កល់នោះមានដូចជា ទុកនៅក្នុងឃ្លាំងតម្កល់ឯកសារដោយដាក់តាមលេខលំដាប់នៃលិខិត ឬទុកនៅក្នុងបន្ទប់រក្សាឯកសាររបស់មន្ទីរសារការី ឬរក្សាទុកក្នុងSoft ជាអាទិ៍។ នៅពេលដែលសន្តតិកម្មចាប់ផ្តើម សារការីមានតួនាទីបើកនូវលិខិតបណ្តាំ និងធ្វើការបែងចែកទ្រព្យសម្បត្តិតាមខ្លឹមសារដែលមាននៅក្នុងលិខិតបណ្តាំដែលបានតម្កល់ទុកនោះ។ ការរក្សាទុកលិខិតបណ្តាំដោយសារការីប្រព្រឹត្តទៅក្រោមច្បាប់ស្តីពីបណ្ណសារ របស់ព្រះរាជាណាចក្រកម្ពុជា។ ការតម្កល់ឯកសារសារការី មិនមែនបញ្ចប់ការតម្កល់លិខិតបណ្តាំត្រឹមពេលដែលខ្លួនបានប្រតិបត្តិមតកសាសន៍នោះទេ សារការីមានកាតព្វកិច្ចត្រូវតម្កល់លិខិតមតកសាសន៍នោះ រយៈពេល ៤០ឆ្នាំ ទៀត

គិតចាប់ពីកាលបរិច្ឆេទនៃឯកសារ ឬថ្ងៃបញ្ចប់សំណុំរឿង[43]។ គោលបំណងនៃការតម្កល់ទុកនេះអាចធានាបាន រាប់សិបឆ្នាំនៃឯកសារផ្លូវច្បាប់នោះ ព្រោះមានទីតាំងដែលបានរក្សាទុកយ៉ាងល្អដែលយើងឃើញជាក់ស្តែងគឺមន្ទីរសារការីនេះឯង សារៈប្រយោជន៍ទីពីរ គឺការតម្កល់ទុកនៅមន្ទីរគឺមានភាពងាយស្រួលដល់សន្តតិជន ឬសារការីក្នុងការរកមើលក៏ដូចជាការកែប្រែករណីមានចំណុចណាមួយដែលខ្វះចន្លោះ ឬបំពេញបន្ថែមតាមការស្នើសុំរបស់ភាគីពាក់ព័ន្ធ អ្វីដែលគួរតែមានការរក្សាទុកនេះគឺព្រោះជាការរក្សានូវសណ្តាប់ធ្នាប់ របៀបរបបនៃការចេះរៀបចំតាមរចនាសម្ព័ន្ធ និង លំដាប់នៃការធ្វើសន្តតិកម្មបន្តបន្ទាប់ទៀត។ ការតម្កល់មតកសាសន៍ សារការីត្រូវចុះបញ្ជី និងរក្សាទុកមតកសាសន៍នោះនៅក្នុងមន្ទីរសារការី។ នៅក្នុងប្រទេសកម្ពុជា តាមការអនុវត្តជាក់ស្តែងនៅពេលដែលសារការីតម្កល់បណ្តាំ បណ្តាំនោះត្រូវរក្សាទុកនៅក្នុងមន្ទីរសារការីនីមួយៗ។ ការតម្កល់មតកសាសន៍នៅក្នុងមន្ទីរសារការី សារការីត្រូវចេញលិខិតបញ្ជាក់ដែលមានខ្លឹមសារថាម្ចាស់បណ្តាំ (បញ្ជាក់អត្តសញ្ញាណរបស់ម្ចាស់បណ្តាំ) បានធ្វើបណ្តាំ ឬបានតម្កល់បណ្តាំរបស់គាត់នៅមន្ទីរសារការី ដោយចុះកាលបរិច្ឆេទ តែមិនបង្ហាញអំពីខ្លឹមសារនៃបណ្តាំទេ។ ប្រទេសកម្ពុជាបច្ចុប្បន្នមិនទាន់មានសេចក្តីណែនាំណាមួយនៅឡើយនោះទេទាក់ទងនឹងនីតិវិធីនៃការតម្កល់មតកសាសន៍ ដូច្នេះនីតិវិធីនៃការតម្កល់មតកសាសន៍ គឺមន្ទីរសារការីនីមួយៗប្រើប្រាស់មធ្យោបាយនៅក្នុងការតម្កល់រៀងៗខ្លួន។

### ២. ការរក្សាទុក

ការរក្សាទុកលិខិតបណ្តាំ ជាការរៀបចំទុកដាក់ឯកសារឱ្យល្អគង់វង្ស ដោយរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព របៀបរៀបរយ និងសណ្តាប់ធ្នាប់ល្អ។ ជាគោលការណ៍ការរក្សាទុកឯកសាររបស់សារការី ធ្វើយ៉ាងណាឱ្យឯកសារនោះធានានូវភាពល្អ សុវត្ថិភាពបំផុត និងអាចធានាបានថាមិនមានការបាត់បង់។ ដោយសារបច្ចុប្បន្នប្រទេសកម្ពុជា មិនទាន់មានបទបញ្ញត្តិណាមួយដែលកំណត់អំពីរបៀបនៃការរក្សាទុកឯកសារនោះទេ ប៉ុន្តែមន្ទីរសារការីនីមួយៗមានយុត្តសាស្ត្ររៀងខ្លួនដើម្បីប្រាកដថាមតកសាសន៍ដែលបានរក្សាទុកនោះមានសុវត្ថិភាព និងរបៀបរៀបរយល្អ ទៅតាមបែបបទនៃការរក្សាទុកក្នុងមន្ទីរសារការីរបស់ខ្លួន។ ដូច្នេះករណីនៃការក្លែងបន្លំ ឬការបាត់បង់នៅមតកសាសន៍នឹងមិនអាចកើតមានឡើយ។ នៅគ្រប់ដំណាក់កាលរបស់សារការីក្នុងការចាប់ផ្តើមដោះស្រាយបញ្ហាមតកសាសន៍ រហូតដល់បញ្ចប់នីតិវិធី គឺសុទ្ធសឹងតែត្រូវធានាបានដោយគោលការណ៍នៃវិធានច្បាប់ មានន័យថាសារការីយកច្បាប់ជាធរមានមកអនុវត្តឱ្យត្រូវតាមគោលដៅ ប៉ុន្តែអ្វីដែលធ្វើឱ្យភាគីពាក់ពន្ធមានភាពជឿទុកចិត្តបន្ថែមទៀតក្រៅពីការដោះស្រាយបានត្រឹមត្រូវហើយនោះ ភាពសំខាន់មួយទៀតគឺសារការីត្រូវធានាដល់ការរក្សាទុកឯកសារបណ្តាំ ឬលិខិតមតកសាសន៍ ។

[43] មាត្រា ១៤ នៃច្បាប់ស្តីពី បណ្ណសារ របស់ព្រះរាជាណាចក្រកម្ពុជា

## ផ្នែកទី២៖ មុខងារសារការីនៅពេលសន្តតិកម្មចាប់ផ្តើម

### កថាខណ្ឌទី១៖ ការរៀបចំចាត់ចែងសន្តតិកម្ម

#### ១. ករណីសារការីជាអ្នកប្រតិបត្តិមតកសាសន៍

នៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានបទបញ្ញត្តិណាមួយដែលបញ្ជាក់ថា អ្នកប្រតិបត្តិមតកសាសន៍ជានរណានោះទេ ប៉ុន្តែអ្វីដែលយើងអាចទាញបាននោះគឺការបញ្ជាក់អំពីបុគ្គលដែលមិនអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍[44]។ ដូច្នេះជាការល្អប្រសើរនៅក្នុងការអនុវត្តតួនាទីជាអ្នកប្រតិបត្តិមតកសាសន៍ ជនដែលមានជំនាញផ្នែកច្បាប់ដូចជាសារការី និងមេធាវី ជាជនដែលអាចធ្វើឱ្យការកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍កាន់តែមានភាពល្អប្រសើរ។ សារការីក៏មានតួនាទី ជាអ្នកប្រតិបត្តិមតកសសន៍ផងដែរនៅពេលដែលសារការីទទួលយកមុខងារជាអ្នកប្រតិបត្តិមតកសាសន៍។ ម្យ៉ាងនៅក្នុងតួនាទីជាអ្នកប្រតិបត្តិមតកសាសន៍ សារការីមានសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក និងធ្វើសកម្មភាពផ្សេងទៀតដែលចាំបាច់ដើម្បីប្រតិបត្តិមតកសាសន៍[45]។ នៅក្នុងមុខងារជាអ្នកប្រតិបត្តិមតកសាសន៍សារការីទទួលបានតួនាទីនេះបានតាមពីររបៀប គឺតាមរយៈការប្រគល់អាណត្តិពីមតកជន និងការជ្រើសរើសដោយតុលាការ។ នៅក្នុងតួនាទីជាអ្នកប្រតិបត្តិមតកសាសន៍ សារការីមានករណីយកិច្ចក្នុងការធ្វើបញ្ជីសារពើភ័ណ្ឌ និងមានសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក ឬធ្វើសកម្មភាពផ្សេងទៀតដែលចាំបាច់ដើម្បីប្រតិបត្តិមតកសាសន៍។

#### ១.១. ការធ្វើបញ្ជីសារពើភ័ណ្ឌ

បញ្ជីសារពើភ័ណ្ឌមត៌ក បង្កើតឡើងដើម្បីឱ្យមានភាពច្បាស់លាស់ អំពីទ្រព្យទាំងអស់របស់មតកជនមាន។ បញ្ជីសារពើភ័ណ្ឌ ចាំបាច់ត្រូវតែមានដើម្បីកំណត់នូវកម្មវត្ថុនៃសិទ្ធិគ្រប់គ្រងចាត់ចែងមត៌ករបស់អ្នកប្រតិបត្តិមតកសាសន៍ ព្រមទាំងដើម្បីបញ្ជាក់អំពីមូលដ្ឋាននៃករណីយកិច្ចប្រគល់ ករណីយកិច្ចរាយការណ៍ ព្រមទាំងករណីយកិច្ចសងសំណងរបស់អ្នកប្រតិបត្តិមតកសាសន៍។ នៅពេលដែលសារការី ព្រមទទួលយកមុខងារជាអ្នកប្រតិបត្តិមតកសាសន៍ពីមតជន សារការីត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិភ្លាម[46] ហើយប្រគល់បញ្ជីសារពើភ័ណ្ឌនោះទៅឱ្យសន្តតិជនដោយគ្មានការយឺតយ៉ាវ[47]។ នៅក្នុងបញ្ជីសារពើភ័ណ្ឌនឹងមានកត់ត្រានូវមត៌កទាំងអស់ដែលមតកជនមាន រួមទាំងទ្រព្យដែលជាប់កាតព្វកិច្ចរបស់មតកជនផងដែរ។ ទ្រព្យសម្បត្តិអាចមានដូចជា អចលនវត្ថុ ការប្រាក់នៅក្នុងកុងធនាគារ និងចលនវត្ថុដូចជារថយន្ត ឬគ្រឿងអលង្ការជាដើម។ នៅពេលដែល

[44] មាត្រា ១២១៧ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧

[45] មាត្រា ១២២០ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧

[46] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ គន្លឹទី៨ - ទី៩ មាត្រា ១២១៩

[47] មាត្រា ១២១៩ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧ កថាខណ្ឌទី១

ទ្រព្យសម្បត្តិត្រូវបានបញ្ចូលក្នុងបញ្ជីសារពើភ័ណ្ឌ ទ្រព្យទាំងនោះនឹងត្រូវបានធ្វើការវាយតម្លៃជាចំនួនទឹកប្រាក់ផងដែរ។ នៅក្នុងបញ្ជីសារពើភ័ណ្ឌ ត្រូវចុះអំពីទីតាំងដែលទ្រព្យស្ថិតនៅ និងលេខប័ណ្ណសម្គាល់។ល។ ការវាយតម្លៃត្រូវបានធ្វើឡើងដោយអ្នកវាយតម្លៃដែលមានជំនាញច្បាស់លាស់ នៅក្នុងករណីដែលអ្នកវាយតម្លៃបានធ្វើការវាយតម្លៃខុសដែលនាំឱ្យមានការខូចខាតនោះ អ្នកវាយតម្លៃត្រូវទទួលខុសត្រូវចំពោះបញ្ហានេះ។

ឧទាហរណ៍ៈ បញ្ជីសារពើភ័ណ្ឌ (មត៌ករបស់មតកជនមាននៅក្នុងបញ្ជីសារពើភ័ណ្ឌ ១ដល់៣)[48]

១. អចលនវត្ថុ

ទីតាំងស្ថិតនៅ ភូមិ.......... ឃុំ......... ស្រុក......... ខេត្ត ......... ទំហំ ..............m$^2$

លេខប័ណ្ណ ................

លេខក្បាលដី .............

(ការវាយតម្លៃ XXXXX$) (ប៉ុន្តែ មត៌កមានតែចំណែកអវិភាគ ១ ភាគ ២)

២. ប្រាក់ក្នុងកុង ធនាគារឈ្មោះ............. សាខា............ កុងសន្សំធម្មតា (គណនីលេខ ......) XXXXX$

៣. រថយន្ត ស្លាកលេខរថយន្ត.......... លេខតួ............ (ការវាយតម្លៃ XXXX$)។

### ១.២. សិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក

ក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍ សារការីត្រូវបានផ្តល់សិទ្ធិ និងករណីយកិច្ចដើម្បីគ្រប់គ្រងមត៌ក និងធ្វើសកម្មភាពមួយចំនួនទៀតដែលលចាំបាច់ដើម្បីប្រតិបត្តិមតកសាសន៍។ តួយ៉ាងនៅពេលដែលមានវត្តមានអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនមិនអាចចាត់ចែងមត៌ក ឬធ្វើសកម្មភាពផ្សេងទៀតដែលនាំឱ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍ឡើយ។ ប្រសិនបើសន្តតិជនបានចាត់ចែងមត៌ក ឬធ្វើសកម្មភាពដែលបានរារាំងដល់ការប្រតិបត្តិមតកសាសន៍សកម្មភាពនោះនឹងត្រូវមោឃៈ[49]។ សារការីអាចសងនៅកាតព្វកិច្ចជាមត៌ក ចំណែកឯម្ចាស់បំណុលរបស់មតកជនវិញក៏អាចទាមទារឱ្យសារការីសងបំណុលនេះបានដែរ។ សារការីដែលមានមុខងារជាអ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើការគ្រប់គ្រងមត៌កពេលចាប់ផ្តើមកាន់កាប់មុខងារនោះឱ្យបានល្អប្រសើរ ប៉ុន្តែប្រសិនបើមតកសាសន៍ទាក់ទងនឹងទ្រព្យសម្បត្តិដែលមានកំណត់ ត្រូវគ្រប់គ្រងតែទ្រព្យសម្បត្តិនោះប៉ុណ្ណោះ[50]។ អ្នកប្រតិបត្តិមតកសាសន៍(សារការី) អាចទទួលបានកម្រៃដែលបានកំណត់នៅក្នុងមតកសាសន៍។ ប្រសិនបើ

[48] ការអនុវត្តជាក់ស្តែងនៃការបែងចែកមត៌ក ( ក្រសួងយុត្តិធម៌ និងវិទ្យាស្ថានស្រាវជ្រាវទូទៅអំពីច្បាប់ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិសាស្ត្រាចារ្យ UMEMOTO Yumi

[49] មាត្រា ១២២១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧

[50] មាត្រា ១២៦៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧

មតកសាសន៍ពុំបានកំណត់កម្រៃទេ តុលាការជាអ្នកកំណត់ចំនួនទឹកប្រាក់នៃកម្រៃនោះ តាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍[51]។ ចំណែកឯសោហ៊ុយនៃការប្រតិបត្តិមតកសាសន៍វិញទៀតសោត ត្រូវជាបន្ទុកនៃមត៌ក[52]។ សោហ៊ុយដើម្បីប្រតិបត្តិមតកសាសន៍មានដូចជា សោហ៊ុយចាំបាច់សម្រាប់នីតិវិធីពិនិត្យបញ្ជាក់លិខិតមតកសាសន៍ សោហ៊ុយធ្វើបញ្ជីសារពើភ័ណ្ឌ សោហ៊ុយគ្រប់គ្រងមត៌ក ឬកម្រៃអ្នកប្រតិបត្តិមតកសាសន៍ជាអាទិ៍។ អ្នកប្រតិបត្តិមតកសាសន៍ អាចកាត់សោហ៊ុយទាំងនេះពីមត៌ក[53]។

### ២. កិច្ចការដែលត្រូវបញ្ជាក់

#### ២.១. មតកសាសន៍

នៅក្នុងសន្តតិកម្មតាមមតកសាសន៍របស់មតកជន ត្រូវបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃមតកសាសន៍ ព្រោះដើម្បីបញ្ជាក់ថាមតកសាសន៍នោះជាមតកសាសន៍ដែលបានបង្កើតឡើងតាមឆន្ទៈរបស់មតកជន ហើយត្រូវបញ្ជាក់អំពីទម្រង់នៃមតកសាសន៍នោះមានលក្ខណៈត្រឹមត្រូវឬទេ។ នៅក្នុងករណីដែលមតកសាសន៍ដែលធ្វើឡើងដោយលិខិតយថាភូត សារការីជាអ្នកបង្កើតនឹងបានរក្សាទុកច្បាប់ដើម ហើយថែមទាំងមានសាក្សីចូលរួមទៀតផង ហេតុនេះការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃមតកសាសន៍មិនមានភាពលំបាកនោះទេ ដូច្នេះមិនចាំបាច់មានការបញ្ជាក់ទេ។ មតកសាសន៍ក្រៅពីទម្រង់នៃលិខិតយថាភូតចាំបាច់ត្រូវមានការពិនិត្យ និងធ្វើការបញ្ជាក់។ យើងសង្កេតនៅក្នុងការពិនិត្យ និងការបញ្ជាក់លិខិតមតកសាសន៍ ត្រូវធ្វើឡើងដើម្បីឱ្យជនដែលមានផលប្រយោជន៍ពាក់ព័ន្ធដឹងលឺ និងដើម្បីកំណត់នូវខ្លឹមសារនៃមតកសាសន៍នោះហេតុនេះអ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ (សារការី) ត្រូវដាក់ពាក្យទៅកាន់តុលាការដោយគ្មានការយឺតយ៉ាវ។ម្យ៉ាងវិញទៀត ចំពោះលិខិតដែលមតកសាសន៍បិទដោយប្រថាប់ត្រា ត្រូវបើកនៅក្នុងនីតិវិធីតុលាការ ដើម្បីកុំឱ្យមានការកែប្រែ។ បើជនណាបើកលិខិតមតកសាសន៍ប្រភេទនេះនៅក្រៅតុលាការ ជននោះនឹងទទួលពិន័យស៊ីវិលមិនលើសពី ១.០០០.០០០ (មួយលានរៀល) ប៉ុន្តែលិខិតមតកសាសន៍មិនត្រូវបានចាត់ទុកជាមោឃៈដោយមូលហេតុនេះទេ។ ចំណែកឯមតកសាសន៍ដោយលិខិតសម្ងាត់វិញ គឺមានការចូលរួមពីសាក្សី ហើយសារការីជាអ្នករក្សាទុកនូវច្បាប់ដើម[54] ប៉ុន្តែមុនបើកមតកសាសន៍សារការីត្រូវសុំការបញ្ជាក់នៅតុលាការជាមុនសិន ព្រោះដើម្បីកុំឱ្យមានការលួចកែប្រែ។ នៅក្នុងមតកសាសន៍ជាលិខិតយថាភូត និងមតកសាន៍ដោយលិខិតសម្ងាត់ គឺមានការចូលរួមពីសារការី និងសាក្សីហេតុនេះចំពោះវិវាទអំពីភាពត្រឹមត្រូវនៃលិខិតប្រហែលជាមានតិចតួចប៉ុណ្ណោះ។ ហេតុនេះ

[51] មាត្រា ១២២៦ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧

[52] មាត្រា ១២២៨ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧

[53] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ គន្ថីទី៨ - ទី៩

[54] ឯកសារស្តីពី ការអនុវត្តជាក់ស្តែងអំពីសន្តតិកម្ម និងការរៀបចំបែងចែកសន្តតិកម្ម រៀបចំដោយ YABUKI Kimitoshi

នៅពេលដែលធ្វើការបញ្ជាក់ គេអាចស្រាវជ្រាវឯកសាររបស់មតកជន ឬសាកសួរពត៌មានពីជនដែលត្រូវសន្មតថាជាសន្តតិជន និងចុះជួបមន្ទីរសារការី។ ចំពោះមតកសាសន៍ជាលិខិតឯកជន ជាបណ្តាំដែលបានធ្វើឡើងដោយម្ចាស់បណ្តាំសរសេរដោយខ្លួនឯង និងចុះហត្ថលេខាលើខ្លឹមសារដោយមិនមានការចូលរួមពីសារការី និងសាក្សី ដូច្នេះការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃមតកសាសន៍អាចមានភាពលំបាក។ ការបញ្ជាក់គេត្រូវស្រាវជ្រាវឯកសាររបស់មតកជន និងការសាកសួរពត៌មានពីជនដែលត្រូវសន្មតថាជាសន្តតិជនគឺជាវិធីសាស្ត្រចម្បង។ នៅក្នុងការអនុវត្តជាក់ស្តែង ប្រសិនបើមិនទាន់ច្បាស់ថាមាន ឬ គ្មានមតកសាសន៍ សន្តតិជនគួរសាកល្បងពិភាក្សាបែងចែកមត៌ក[55]តាមរយៈការពិភាក្សាជាមួយសហសន្តតិជនផ្សេងទៀតបន្ទាប់នៅពេលណាក៏បាន បើកំឡុងពេលមួយខែបានកន្លងផុតទៅក្រោយពេលចាប់ផ្តើមសន្តតិកម្ម[56]។ នៅក្នុងករណីដែលមិនមានភាពឯកភាពគ្នានៅក្នុងការបែងចែកបានទេនោះ នោះត្រូវបែងចែកតាមផ្លូវតុលាការតាមការដាក់ពាក្យសុំរបស់សន្តតិជនណាម្នាក់[57]។ តាមរយៈការដាក់ពាក្យសុំទៅកាន់តុលាការឱ្យធ្វើការបែងចែក ជាលទ្ធភាពមួយខ្ពស់ដែលអាចឱ្យដឹងច្បាស់ថាមានមតកសាសន៍ ឬមិនមានមតកសាសន៍ នៅក្នុងនីតិវិធីដែលធ្វើតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ ចំពោះមតកសាសន៍ដោយលិខិតយថាភូត និងមតកសាសន៍ដោយលិខិតសម្ងាត់ គឺមានការចូលរួមពីសារការី និងសាក្សី ហេតុនេះចំពោះវិវាទអំពីភាពត្រឹមត្រូវនៃលិខិតប្រហែលជាមានតិចតួចប៉ុណ្ណោះ ប៉ុន្តែមតកសាសន៍ដោយលិខិតឯកជនមិនមានការចូលរួមតតិយជនអព្យាក្រឹត្យណាម្នាក់នោះទេ ហេតុនេះវិវាទអំពីភាពត្រឹមត្រូវនៃលិខិតអាចកើតមានឡើង។ មតកសាសន៍ជាលិខិតឯកជន ជាបណ្តាំដែលមតជនបានសរសេរដោយខ្លួនឯង ដូច្នេះការបញ្ជាក់ពីអត្ថិភាពនៃបណ្តាំគឺការធ្វើកោសល្យវិច័យនៃការសរសេរនោះ។ ភាពចាំបាច់នៃទម្រង់មតកសាសន៍ អាចធ្វើឱ្យមានចំណុចវិវាទផងដែរ ដូច្នេះសន្តតិជនអាចប្តឹងតាមនីតិវិធីរដ្ឋប្បវេណី ២០០៧ (តាមមាត្រា១១៧០ នៃក្រមរដ្ឋប្បវេណីជាដើម)។

### ២.២. សន្តតិជន

នៅពេលចាប់ផ្តើមសន្តតិកម្ម ទោះបីជាសន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មតាមមតកសាសន៍ក៏ដោយ ក៏ត្រូវផ្ទៀងផ្ទាត់អត្តសញ្ញាណ។ នៅក្នុងការបញ្ជាក់ពីសន្តតិជនសារការីត្រូវធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណសន្តតិជនឱ្យបានច្បាស់លាស់ជាមុន ដោយភ្ជាប់ជាមួយនឹងឯកសារបញ្ជាក់អត្តសញ្ញាណរបស់សន្តតិជនឱ្យបានច្បាស់លាស់ ដោយភ្ជាប់ជាមួយនឹងឯកសារបញ្ជាក់អត្តសញ្ញាណ ដែលមានអត្តសញ្ញាណញាតិជាមួយមតកជនដែលមានដូចជា៖ សំបុត្រកំណើត សៀវភៅស្នាក់នៅ សៀវភៅគ្រួសារសំបុត្រមរណភាព ឬឯកសារអត្រានុកូលដ្ឋានផ្សេង

[55] ឯកសារស្តីពី ការអនុវត្តជាក់ស្តែងអំពីសន្តតិកម្ម និងការរៀបចំបែងចែកសន្តតិកម្ម រៀបចំដោយ YABUKI Kimitoshi

[56] មាត្រា ១២៦៦ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧ កថាខណ្ឌទី១

[57] មាត្រា ១២៧០ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧ កថាខណ្ឌទី១

ទៀតដែលអាចបញ្ជាក់ពីទំនាក់ទំនងញាតិ។ ការបែងចែកមត៌ក ដោយបូករួមទាំងជនដែលគ្មានលក្ខណៈសម្បត្តិក្នុងទំហំនៃសន្តតិកម្មត្រូវចាត់ទុកជាមោឃៈ។

**កថាខណ្ឌទី២៖ មុខងារក្នុងដំណាក់កាលបែងចែក**

**១. ការប្រឹក្សាយោបល់ករណីគ្មានមតកសាសន៍**

ទោះបីជាគ្មានបណ្តាំមត៌កដែលបានបង្កើតឡើងដោយមានវត្តមានសារការីចូលរួម សន្តតិជនអាចប្រឹក្សាយោបល់ជាមួយសារការី រួមទាំងតម្រូវការលិខិតមួយចំនួន ដែលក្នុងនោះរួមមានលិខិតបញ្ជាក់សន្តតិជន បញ្ជីសារពើភ័ណ្ឌទ្រព្យជាមត៌ក ឬលិខិតទទួល ឬលះបង់មត៌កជាអាទិ៍។ នៅក្នុងដំណាក់កាលនៃការបែងចែកមត៌កទោះបីជាមត៌កដែលសន្តតិជនត្រូវទទួលជាប្រភេទសន្តតិកម្មដែលពុំមានវត្តមានសារការីក្នុងការបង្កើត ឬធ្វើការតម្កល់ និងថែរក្សាទុកក្តី ក៏សន្តតិជនអាចពិភាក្សាជាមួយសារការីមុនពេលដែលទទួលមត៌ក។ ការប្រឹក្សាជាមួយសារការី ពិតជាមានសារៈសំខាន់ណាស់សម្រាប់សន្តតិជននៅក្នុងសន្តតិកម្ម ព្រោះការពិភាក្សាជាមួយសារការីអាចបញ្ចៀសសន្តតិជនពីបំណុល ដែលមាននៅក្នុងមត៌កជាអាទិ៍។ ទ្រព្យសម្បត្តិដែលមតកជនបានបន្សល់ទុកអាចមានពីរប្រភេទគឺ ទ្រព្យសកម្ម និងទ្រព្យអកម្ម។ ជាធម្មតាប្រសិនបើទ្រព្យដែលបានបន្សល់ទុកជាទ្រព្យសកម្មមិនមែនជាបញ្ហាឡើយសម្រាប់សន្តតិជន ប៉ុន្តែអ្វីដែលជាការព្រួយបារម្ភសម្រាប់សន្តតិជននោះជាទ្រព្យអកម្ម។ ទ្រព្យអកម្ម ជាទ្រព្យជាប់បំណុលរបស់មតកជននៅពេលដែលមានជីវិត។ ដូច្នេះនៅក្នុងករណីដែលមតកជនបានទទួលមរភាពដោយបានបន្សល់ទុកនូវទ្រព្យសម្បត្តិ ហើយសន្តតិជនទាំងអស់មិនបានដឹងច្បាស់លើទ្រព្យសម្បត្តិទាំងអស់ដែលបន្សល់ទុកនោះមានជាប់បំណុល ឬទេនោះ សន្តតិជនអាចធ្វើការពិភាក្សាជាមួយសារការីដើម្បីបញ្ជាក់អំពីការណ៍ទាំងអស់នោះបាន។ សន្តតិជន មុនទទួលសន្តតិកម្មប្រសិនបើពុំមានភាពច្បាស់លាស់អំពីទ្រព្យរបស់មតកជន ក្នុងកំឡុងពេលដែលមានជីវិតមានទ្រព្យទាំងមូល និងមិនដឹងច្បាស់ថានៅពេលដែលមានជីវិតមតកជនមានកាតព្វកិច្ចប៉ុន្មានទេនោះ សន្តតិជនអាចស្នើសុំទៅកាន់តុលាការដើម្បីជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍។ ប្រសិនបើសារការី ជាបុគ្គលដែលត្រូវបានជ្រើសតាំងជាអ្នកប្រតិបត្តិមតកសាសន៍នោះសារការីត្រូវដើរតួនាទីជាអ្នកធ្វើបញ្ជីសារពើភ័ណ្ឌដើម្បីកំណត់ពីទ្រព្យសម្បត្តិដែលមតកជនមានទាំងអស់ និងកាតព្វកិច្ចដែលមតកជនមាន នឹងត្រូវបញ្ជូនទៅឱ្យសន្តតិជនដោយគ្មានការយឺតយ៉ាវ។ នៅពេលដែលទទួលបានបញ្ជីសារភ័ណ្ឌ សន្តតិជនអាចសម្រេចអំពីការទទួលយកសន្តតិកម្មទាំងស្រុង ឬមួយផ្នែក ឬបោះបង់សន្តតិកម្មតែម្តង។ ប្រសិនបើសន្តតិជន បោះបង់សន្តតិកម្មទាំងមូលនោះសន្តតិជនត្រូវដាក់ពាក្យបោះបង់សន្តតិកម្មទៅកាន់តុលាការ[58]។ ប៉ុន្តែបើសន្តតិជនយល់ព្រមទទួលសន្តតិកម្មដោយមានកម្រិត នោះសន្តតិជន

[58] មាត្រា ១២៦១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧

ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌហើយដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះ ទៅតុលាការនៅក្នុងកំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថាសន្តតិកម្មចំពោះខ្លួនចាប់ផ្តើម[59]។

**២. ការបង្កើតកិច្ចព្រមព្រៀងបែងចែកចំណែកមត៌ក**

នៅក្នុងចំណោមមត៌កទាំងអស់ មានមត៌កខ្លះត្រូវមានទម្រង់កំណត់មួយដើម្បីផ្ទេរសិទ្ធិ ឬដើម្បីឱ្យមានល័ក្ខខ័ណ្ឌតតាំង។ ហេតុនេះហើយបានជាការផ្ទេរវត្ថុចំពោះការបែងចែកមត៌ក ត្រូវធ្វើតាមទម្រង់ចាំចាច់ដើម្បីផ្ទេរសិទ្ធិនីមួយៗ។ ឧទាហរណ៍ ជាលទ្ធផលនៃការបែងចែកដីធ្លីត្រូវបានបែងចែក ក្នុងករណីដែលចំណែកនៃកម្មសិទ្ធិអវិភាគត្រូវបានផ្ទេរ ឬក្នុងករណីដែលដីធ្លីដែលមានឈ្មោះមតកជន ត្រូវដាក់ជាកម្មសិទ្ធិរបស់សន្តតិជនកំណត់ណាតែម្នាក់ឯង ដើម្បីចុះបញ្ជីបញ្ជាក់អំពីការផ្ទេរទាំងនេះត្រូវធ្វើលិខិតយថាភូត។ ម្យ៉ាងវិញទៀតក្នុងករណីដែលមានសិទ្ធិលើបំណុលជាកម្មវត្ថុនៃការបែងចែក ដើម្បីធ្វើការពិភាក្សាបែងចែកមត៌កនោះទៅឱ្យសន្តតិជនជាកំណត់ណាម្នាក់ជាម្ចាស់សិទ្ធិតែម្នាក់ឯង នោះចាំបាច់ត្រូវធ្វើតាមនីតិវិធីដើម្បីបំពេញល័ក្ខខ័ណ្ឌតតាំងដែលមាននៅក្នុងមាត្រា ១២៧៥ ដែលនៅក្នុងនោះការបែងចែកមត៌កដែលត្រូវបានធ្វើឡើងដោយលិខិតយថាភូត ការបង្ហាញលិខិតយថាភូតនេះ ការប្រគល់លិខិតចម្លងនៃលិខិតយថាភូតនេះទៅទៅកូនបំណុល ជាវិធីពិសេសមួយ។ លិខិតយថាភូត ជាលិខិតដែលបានធ្វើឡើងដោយសារការី។ លិខិតយថាភូត ជាលិខិតដែលនឹងក្លាយជាលិខិតសាធារណៈដែលត្រូវបានធានាភាពត្រឹមត្រូវពិតប្រាកដ និងមានតម្លៃស្មើនឹងសាលក្រមឬសាលដីកាស្ថាពររបស់តុលាការ។

## ផ្នែកទី៣៖ សារៈប្រយោជន៍ និងបញ្ហាប្រឈមការអនុវត្តមុខងារសារការីនៅក្នុងសន្តតិកម្ម

### កថាខណ្ឌទី១៖ ផលប្រយោជន៍នៃតួនាទីសារការីនៅក្នុងសន្តតិកម្ម

**១. ផលប្រយោជន៍ដែលមាននៅក្នុងមតកសាសន៍ដែលបង្កើតដោយសារការី**

**១.១. ការទទួលបានភាពជឿជាក់យ៉ាងរឹងមាំ**

មតកសាសន៍ជាលិខិតយថាភូត ជាប្រភេទលិខិតយថាភូតដែលនឹងក្លាយជាលិខិតសាធារណៈដែលត្រូវបានធានាពីភាពត្រឹមត្រូវ ពិតប្រាកដ ដែលត្រូវបានអាជ្ញាធរពាក់ព័ន្ធ និងតុលាការជឿជាក់នឹងទទួលស្គាល់។ ក្រៅពីលិខិតរបស់ស្ថាប័នជម្រះក្តី ឬអាជ្ញាធរមានសមត្ថកិច្ច មានតែលិខិតដែលធ្វើឡើងដោយសារការីដែលមានប្រថាប់ត្រា និងចុះហត្ថលេខារបស់សារការីប៉ុណ្ណោះដែលមានគុណសម្បត្តិជាលិខិតយថាភូត។ នៅក្នុងការបង្កើតលិខិតមតកសាសន៍ សារការីត្រូវបញ្ជាក់ឱ្យបានច្បាស់ថាមតកសាសន៍នោះបានបំពេញតាមទម្រង់នៃច្បាប់កំណត់ពេញលេញដោយគ្មានខ្វះចន្លោះឡើយ ព្រោះប្រសិនបើមានកំហុសណាមួយកើតឡើងនាំឱ្យលិខិត

[59] មាត្រា ១២៤៨ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧

បណ្តាំនោះមិនមានអានុភាពនៅក្នុងការអនុវត្តនោះទេ។ ដូច្នេះនៅក្នុងការបង្កើតលិខិតបណ្តាំនីមួយៗសារការី មានភាពប្រាកដច្បាស់លាស់ថាលិខិតនោះត្រឹមត្រូវ និងមិនមានភាពខ្វះចន្លោះនៅត្រង់កន្លែងណាមួយនោះទេ។ ការអនុវត្តតួនាទីរបស់សារការីមិនត្រឹមតែ នៅក្នុងដំណាក់កាលនៃការតាក់តែងប៉ុណ្ណោះទេ ចំពោះដំណាក់កាលបន្ទាប់ពីការតាក់តែងសារការីក៏ត្រូវតែអនុវត្តឱ្យបានខ្ជាប់ខ្ជួននៅកាតព្វកិច្ចរបស់ខ្លួនចំពោះការតម្កល់ និងថែរក្សាបណ្តាំរហូតដល់ដំណាក់កាលនៃការបែងចែករួចរាល់សព្វគ្រប់ ហើយថែមទាំងតម្កល់លិខិតមតកសាសន៍នោះរហូតដល់រយៈពេល៤០ឆ្នាំបន្តទៀត គិតចាប់ពីការបញ្ចប់សំណុំរឿង។ ជាក់ស្តែងដូចជាតួនាទីនៅក្នុងការតម្កល់ និងថែរក្សាមតកសាសន៍ មន្ទីរសារការីនីមួយៗមាននីតិវិធី និងកន្លែងតម្កល់ឯកសាររបស់គេផ្ទាល់ដែលមានលក្ខណៈដែលអាចជឿជាក់បានថាបណ្តាំរបស់មតកជនមិនមានការក្លែងបន្លំ និង ការលួចកែប្រែខ្លឹមសារនៃបណ្តាំនោះបាន។ ម្យ៉ាងវិញទៀតទោះបីជាសារការីបានធ្វើការបែងចែកមត៌កតាមបណ្តាំហើយក្តី ក៏សារការីនៅថែរក្សាបណ្តាំនោះទុកដើម្បីជាភស្តុតាងមួយ ប្រសិនបើមានវិវាទកើតឡើងក្រោយពីការបែងចែកមត៌កក្រោមច្បាប់ស្តីពីបណ្ណសារកម្ពុជា។ ប្រសិនបើយើងធ្វើការប្រៀបធៀបរវាងមតកសាសន៍ជាលិខិតឯកជនដែលមិនមានវត្តមានរបស់សារការីចូលរួមក្នុងការបង្កើត ការតម្កល់ និងការថែរក្សាទេនោះ យើងអាចមានការសង្ស័យថា បណ្តាំរបស់មតកជនជាបណ្តាំដែលកើតពីឆន្ទៈមិនពិតប្រាកដរបស់មតកជនឬយ៉ាងណា និងបណ្តាំនោះធ្លាប់មានការកែប្រែ ឬលួចបន្លំដែរទេ។ នេះជាអ្វីដែលសន្តតិជនអាចមានការព្រួយបារម្ភ ប៉ុន្តែចំពោះមតកសាសន៍ដែលមានវត្តមានសារការីគឺអាចជឿទុកចិត្តបានមិនថាចំពោះសន្តតិជន ឬមតកជនមិនចាំបាច់មានការព្រួយបារម្ភពីបញ្ហានេះទេ។

### ១.២. ធានានូវប្រសិទ្ធិភាព

ដោយសារស្ថានភាពបច្ចុប្បន្ននៃប្រទេសកម្ពុជា កំពុងតែមានបញ្ហាមួយចំនួនដែលតែងតែចោទជាមន្ទិលភាពស្មុគស្មាញនៅក្នុងការរកដំណោះស្រាយដោយប្រជាពលរដ្ឋធម្មតា ក៏ដូចជាអ្នកវិជ្ជាជីវៈច្បាប់ផងនោះគឺ ការបែងចែកចំណែកនៃមត៌កដែលក្នុងន័យច្បាប់នោះ សំដៅទៅលើសន្តតិកម្មដែលត្រូវបានបកស្រាយនៅផ្នែកខាងលើរួចមកហើយ ថានៅពេលកើតមានវិវាទក្នុងការបែងចែកមត៌ក សារការីត្រូវធ្វើបែបណាក្នុងការអនុវត្តដល់ភាគី និងការប្រតិបត្តិមុខងាររបស់ខ្លួនឱ្យបានត្រឹមត្រូវ។ ទន្ទឹមនឹងនោះសារការីបានចូលខ្លួនក្នុងការបង្ហាញនូវតួនាទី ផ្នែកមតកសាសន៍នូវការផ្តល់ជាលិខិតយថាភូតផ្អែកលើស្មារតីច្បាប់ ដោយសារការីជាអ្នកកត់ត្រាគ្រប់ទម្រង់ខ្លឹមសារនៃឆន្ទៈរបស់មត៌កជនជាលាយលក្ខណ៍អក្សរ។ ការធ្វើនូវលិខិតជាលាយលក្ខណ៍អក្សរនេះទៀតសោត មិនត្រឹមតែបង្ហាញពីជំនឿជាក់ស្របច្បាប់នោះទេ ប៉ុន្តែការណ៍ដែលស្របច្បាប់រួចហើយ ថាតើលិខិតនោះមានប្រសិទ្ធិភាពបែបណាចំពោះការអន្តរាគមន៍របស់សារការី ក៏ដូចជាការផ្តល់សារៈប្រយោជន៍ ថ្វីបើសន្តតិជនមិនពេញចិត្តនឹងការចែកចំណែកមត៌ករបស់មតកជនពេលនោះ ហើយសន្តតិជននោះអាចរកអ្នកច្បាប់ជាសារការីដើម្បីផ្តល់ប្រឹក្សាការចាត់ចែងចំណែកមត៌កនោះសារជាថ្មីដោយ យោងតាមច្បាប់ក៏ពិតមែន ហើយកាន់តែធានាបានយ៉ាងកក់ក្តៅ

ទៅទៀតនោះ កាលណាសារការីបានពិនិត្យទៅលើសមត្ថភាពម្ចាស់បណ្តាំ ខ្លឹមសារបណ្តាំ រួចសូត្របណ្តាំឱ្យលឺៗនៅចំពោះមុខសាក្សីពីររូបជាលាយលក្ខណ៍អក្សរ ពេលនោះហើយមត៌កសាសន៍ដោយលិខិតយថាភូតនោះនឹងរឹតតែធានាបាននូវភាពច្បាស់លាស់ ត្រឹមត្រូវ។ មួយវិញទៀត តាមរយៈការរក្សាទុកនូវលិខិតមតកសាសន៍ដោយសារការី ពិតជាអាចបញ្ជាក់បានថាលិខិតទាំងនោះអាចស្ថិតស្ថេរគង់វង្សយូរអង្វែងប្រកប ដោយសុវត្ថិភាពនៅក្នុងមន្ទីរសារការី ហេតុនេះចំពោះករណីក្លែងបន្លំ កែតម្រូវ បាត់បង់គឺមិនអាចកើតមានជាដាច់ខាត។ ក្នុងន័យនេះរាល់ការកែតម្រូវលុះណាតែ មានការស្នើសុំពីមតកជននៅពេលមតកជននោះចង់ត្រួតពិនិត្យ ឬមតកសាសន៍នោះមានការខ្វះខាតប៉ុណ្ណោះ។

## ២. ផលប្រយោជន៍ចំពោះប្រព័ន្ធសន្តតិកម្ម

### ២.១. ចំណេញពេលវេលាដល់ភាគីក្នុងសន្តតិកម្ម

នៅក្នុងការធ្វើសន្តតិកម្មដោយសារការីពិតជា បានផ្តល់នូវសារប្រយោជន៍ជាច្រើនដែលជាគុណប្រយោជន៍ទាំងនោះធ្វើអោយគូភាគីអាចចំណេញពេលវេលាបានច្រើនពីការផ្តល់អោយតាមរយៈសារការី ព្រោះមានមូលហេតុដោយការអនុវត្តសន្តតិកម្មដោយសារការីជាការបំពេញកិច្ចប្រកបដោយគតិយុត្តតាមការផ្តល់ការប្រឹក្សាបានយ៉ាងច្បាស់លាស់ស្ទើរតែទាំងស្រុងក្នុងនីតិវិធី និងទិដ្ឋភាពជាក់ស្តែង។

### ២.២. ការពារជនពាក់ព័ន្ធក្នុងមត៌ក

មតកសាសន៍ ដែលមានវត្តមានសារការីជាភស្តុតាងមួយដែលបង្ហាញថាខ្លឹមសារនៅក្នុងបណ្តាំជាឆន្ទៈពិតប្រាកដ ដែលតម្រូវឱ្យអ្នកដែលមានផលប្រយោជន៍នៅក្នុងសន្តតិកម្មទាំងអស់ត្រូវតែគោរពតាមឆន្ទៈនោះ។ ប៉ុន្តែចំពោះពាក្យថាគោរពនេះ មិនចាប់បង្ខំឱ្យសន្តតិជន ឬអ្នកដែលមានផលប្រយោជន៍នៅក្នុងសន្តតិកម្មត្រូវតែអនុវត្តសន្តតិកម្មដូចអ្វីដែលមតកជនបានសរសេរទុកនៅក្នុងខ្លឹមសារនៃបណ្តាំនោះឡើយ ពីព្រោះនៅក្នុងប្រព័ន្ធសន្តតិកម្មនៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាសន្តតិកម្មត្រូវទទួលដោយស្វ័យប្រវត្តិពីមតកជនមកសន្តតិជនប៉ុន្តែបញ្ញត្តិនៃច្បាប់នេះ មិនបានចាប់បង្ខំឱ្យសន្តតិជនត្រូវតែទទួលយកមត៌កដែលជាចំណែករបស់ខ្លួនដែលមាននៅក្នុងមត៌កនោះទេ ដោយហេតុថា នៅក្នុងមត៌កដែលមតកជនមានជាទ្រព្យអកម្មដូច្នេះនៅក្នុងបញ្ញត្តិស្តីពីសន្តតិកម្មអនុញ្ញាតឱ្យសន្តតិជនអាចទទួលមត៌កដោយមានកម្រិត ឬទាំងមូល ឬអាចបោះបង់សន្តតិកម្មចោលទាំងមូលតែម្តង។ ម្យ៉ាងវិញទៀតប្រសិនបើលិខិតបណ្តាំរបស់មតកជនបានបំពានភាគបម្រុងរបស់សន្តតិជននោះសន្តតិជនដែលត្រូវបានបំពានភាគបម្រុងនោះ ក៏អាចទាមទារភាគបម្រុងបានដែរ។ បើមតកជនបានកំណត់ចំណែកមត៌ក ឬវិធីបែងចែកមត៌ក ដោយធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ដោយមតកសាសន៍ ទ្រព្យសម្បត្តិជាក់លាក់នោះ ត្រូវធ្លាក់ទៅសន្តតិជនដែលនឹង

ត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយស្វ័យប្រវត្តិ ព្រមគ្នានឹងពេលមតកសាសន៍នោះបង្កើតអានុភាព[60]។ ជាគោលការណ៍ប្រសិនបើមតកជនបានកំណត់ចំណែកមត៌កនៅក្នុងមតកសាសន៍ នៅពេលដែលសន្តតិកម្មចាប់ផ្តើមនោះសន្តតិជនម្នាក់ៗនឹងទទួលបានតាមការកំណត់របស់មតកជន។ ដូច្នេះនៅពេលដែលសារការីចូលរួមក្នុងការបង្កើតលិខិតមតកសាសន៍ ដោយលិខិតយថាភូតសារការីនឹងប្រាប់ពីគន្លឹះទាំងនេះដើម្បីធ្វើយ៉ាងណាឱ្យខ្លឹមសារដែលមាននៅក្នុងបណ្តាំមានភាពងាយស្រួលនៅក្នុងការបែងចែក និងមិនប្រើប្រាស់ពេលវេលាយូរ ព្រមទាំងបង្កើតអានុភាពតាមផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាព។ ដោយសារការធ្វើនូវលិខិតយថាភូតតាមលិខិតបណ្តាំជាគោលការណ៍មួយដែលច្បាប់បានជួយរកនូវភាពត្រឹមត្រូវដល់ប្រជាពលរដ្ឋប៉ុណ្ណោះទេ តែក៏ជាការជំនួយទៅដល់ដំណោះស្រាយនៃប្រទេសជាតិមួយផ្នែកដែលកំពុងតែមានពេលខ្លះមានភាពមិនច្បាស់លាស់ថា នរណាជាអ្នកប្រតិបត្តិនូវមុខងារនេះដោយប្រជាពលរដ្ឋ ការធ្វើដូចនេះ គឺជាការរក្សាបាននូវស្ថានភាពគតិយុត្តមួយដែលប្រកបទៅដោយដំណោះស្រាយដ៏ត្រឹមត្រូវ។ ចំណុចមួយគួរកត់សម្គាល់បន្ថែមទៀតនោះគឺ ដោយសារវិជ្ជាជីវៈសារការីជាវិជ្ជាជីវៈមួយដែលឯករាជ្យ សេរីក្នុងការបំពេញដោយមិនស្ថិតនៅក្រោមស្ថាប័នណាមួយនោះទេ ពោលគឺការផ្តល់យោបល់ផ្នែកច្បាប់ស្តីពីសន្តតិកម្ម ជាជំនាញមួយដែលមានភាពត្រឹមត្រូវច្បាស់លាស់ដល់បុគ្គលពាក់ព័ន្ធដែលនាំឱ្យមានការកាត់បន្ថយនូវជម្លោះ នៅថ្ងៃខាងមុខព្រោះតម្រូវឱ្យបុគ្គលដែលជាសន្តតិជនមានភាពស្ថិតស្ថេរមួយជីវិត រហូតដល់ការធានាចំពោះការធ្វើមត៌កបន្តទៀតនៃជននោះ។

### ២.៣. កាត់បន្ថយនូវជម្លោះមត៌កក្នុងប្រព័ន្ធតុលាការ

ជាទូទៅ នៅក្នុងការដោះស្រាយបញ្ហាសន្តតិកម្មខ្លះៗមួយចំនួនអាចឈានចូលទៅដល់ការប្តឹងផ្តល់គ្នានៅតុលាការដែលនេះជាភាពរញ៉េរញ៉ៃ មានដំណាក់កាលច្រើនក្នុងវិស័យច្បាប់ ពិសេសបង្ករជាបញ្ហានិងការប្រមូលផ្តុំច្រើននៃសំណុំរឿង។ ក្នុងប្រព័ន្ធនៃការផ្ទេរទ្រព្យសម្បត្តិពីមតកជន ទៅសន្តតិជនជានិច្ចជាកាលតែងតែជួបបញ្ហាផ្សេងៗ ដែលបញ្ហាទាំងនោះច្រើនតែកើតឡើងនៅក្នុងដំណាក់កាលនៃការបែងចែក រវាងសន្តតិជននិងសន្តតិជនពោលគឺកាលណាមានសន្តតិជនច្រើននាក់ដែលនេះហើយជាការបង្កបាននូវវិវាទ និងបញ្ហាកើតមានឡើងដែលតែងតែជាកម្មវត្ថុនៃការដោះស្រាយនៅក្នុងប្រព័ន្ធតុលាការ។ បច្ចុប្បន្នការដោះស្រាយជម្លោះមត៌ក ត្រូវបានធ្វើឡើងជាដំណាក់កាល មុនពេលដែលជម្លោះនោះទៅឱ្យតុលាការជាអ្នកដោះស្រាយ។ វិវាទសន្តតិកម្ម ជាជំហានដំបូងគឺត្រូវបានដោះស្រាយនៅសាលាឃុំសង្កាត់នៅក្នុងដំណាក់កាលនេះ ជាដំណាក់កាលនៃការផ្សះផ្សារវាងសន្តតិជនប៉ុណ្ណោះ មានន័យថា មេឃុំត្រូវនិយាយដោយផ្តល់មធ្យោបាយដល់គូភាគីឱ្យទទួលយកបាន និងបញ្ឈប់នូវវិវាទ ផ្ទុយទៅវិញប្រសិនបើការផ្សះផ្សាពុំឈានដល់ដំណាក់កាលឯកភាពគ្នានោះទេ វិវាទនេះនឹងត្រូវ

[60] មាត្រា ១១៩៥ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧ កថាខណ្ឌទី១

ដាក់ជូនតុលាការខេត្ត ក្រុង(សាលាដំបូង) ជាអ្នកដោះស្រាយ។ បច្ចុប្បន្នពួកយើងសង្កេតឃើញថាមានសំណុំរឿងជាច្រើនដែលតុលាការត្រូវធ្វើការដោះស្រាយ ជាក់ស្តែងនៅក្នុងឆ្នាំ ២០២០ នេះក្រសួងយុត្តិធម៌បានបង្កើតឱ្យមានយុត្តនាការណ៍ស្តីពីការដោះស្រាយការកកស្ទះសំណុំរឿង។ បើយើងក្រឡេកមកមើលទិដ្ឋភាពនៅក្នុងសន្តតិកម្ម សារការីអាចជួយឱ្យកាត់បន្ថយសំណុំរឿងដែលត្រូវបញ្ជូនឱ្យតុលាការធ្វើការដោះស្រាយ ព្រោះដោយហេតុថា សារការីជាមន្ត្រីសារធារណៈដែលរដ្ឋប្រគល់អំណាចឱ្យមានសមត្ថកិច្ចនៅក្នុងការបំពេញតួនាទីដូចដែលបានជម្រាបជូនកន្លងមកនេះ ដូច្នេះលិខិតមតកសាសន៍ និងការបំពេញតួនាទីផ្សេងទៀតរបស់សារការីជាត្រូវបានទទួលស្គាល់ថាជាការបំពេញតួនាទីដែលមិនមានភាពខ្វះចន្លោះឡើយខាងវិស័យច្បាប់ លើកលែងតែមានភស្តុតាងដែលបានបញ្ជាក់ថាការបំពេញតួនាទីរបស់សារការីបានខុសគ្នាទៅនឹងបទបញ្ញត្តិដែលបានកំណត់ប៉ុណ្ណោះ។ លិខិតដែលសារការបានធ្វើ ជាប្រភេទលិខិតយថាភូតជាក់ស្តែងចំពោះមតកសាសន៍លិខិតយថាភូតដែលបង្កើតឡើងដោយសារការី នឹងក្លាយជាលិខិតដែលបានធានាពីភាពត្រឹមត្រូវពិតប្រាកដ ដែលត្រូវបានអាជ្ញាធរពាក់ព័ន្ធ តុលាការជឿជាក់ និងទទួលស្គាល់។ ក្រៅពីលិខិតរបស់ស្ថាប័នជម្រះក្តី ឬអាជ្ញាធរមានសមត្ថកិច្ចមានតែលិខិតដែលធ្វើឡើងដោយសារការីដែលមានប្រថាប់ត្រា និងចុះហត្ថលេខារបស់សារការីប៉ុណ្ណោះដែលមានគុណសម្បត្តិជាលិខិតយថាភូត។ ដូច្នេះនៅពេលដែលបើកបណ្តាំមត៌កសន្តតិជននឹងមានភាពជឿជាក់ថាខ្លឹមសារដែលបានសរសេរដោយសារការី ជាខ្លឹមសារដែលបានបង្កើតឡើងតាមឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំពិតប្រាកដមែន ដូច្នេះធ្វើឱ្យសន្តតិជនម្នាក់ៗមិនអាចតវ៉ាបានថាខ្លឹមសារនោះមានវិការៈនោះទេ។

## កថាខណ្ឌទី២៖ បញ្ហាប្រឈមនៃការអនុវត្តមុខងាររបស់សារការីនៅកម្ពុជា

### ១. បញ្ហាប្រជាជន

កត្តាប្រជាជន ក៏ធ្វើឱ្យវិជ្ជាជីវៈសារការីមានភាពលំបាកក្នុងការអនុវត្តតួនាទីរបស់ខ្លួននៅក្នុងសន្តតិកម្មផងដែរ។ បច្ចុប្បន្នមានប្រជាជនច្រើនណាស់ ដែលមិនចាប់អារម្មណ៍មើលពីទិដ្ឋភាពច្បាប់ដែលកំពុងមានជាធរមាននៅក្នុងប្រទេស។ ចំពោះសន្តតិកម្ម នៅក្នុងទស្សនៈប្រជាជនកម្ពុជាបច្ចុប្បន្ន ការផ្ទេរទ្រព្យសម្បត្តិរបស់ខ្លួនទៅឱ្យបុគ្គលណាម្នាក់ក្នុងចំណោមសន្តតិជន ឬជនដទៃផ្សេងទៀតធ្វើឡើងដោយផ្ទាល់មាត់ជាការគ្រប់គ្រាន់ហើយ។ តាមរយៈសកម្មភាពនៃការផ្ទេរមត៌កបែបនេះ គឺត្រូវបានអនុវត្តមកជាយូរណាស់មកហើយនៅក្នុងសង្គមកម្ពុជា។ នេះជាសកម្មភាពទម្លាប់មួយទៅហើយ ទោះបីជានិច្ចកាលមិនថានៅសម័យកាលមុន និងបច្ចុប្បន្នយើងសង្កេតឃើញថា ទំនាស់បានកើតឡើងជាច្រើនករណីដែលបណ្តាលមកពីការដណ្តើមកេរ្តិ៍មត៌កនៅក្នុងគ្រួសារ ក៏ប្រជាជននៅតែប្រើប្រាស់ទម្លាប់នេះមកទល់ពេលបច្ចុប្បន្ន។ មានមូលហេតុមួយចំនួនដែលធ្វើឱ្យប្រជាជននៅតែបន្តទម្លាប់ជាដដែលនេះនៅក្នុងការអនុវត្តសន្តតិកម្មបែបនេះ ប្រជាជនភាគច្រើនយល់ឃើញថា ការចំណាយទៅលើសារការីនាំឱ្យមានចំណាយទៅលើសេវាកម្មសារការី និងចំណាយពេលវេលាច្រើន។

**២. បញ្ហាគង្វះខាតសារការី**

បច្ចុប្បន្ន ការអនុវត្តមុខងាររបស់សារការីនៅកម្ពុជា នៅពុំទាន់មានភាពទូលំទូលាយនៅឡើយនោះទេ ដោយសារតែវិជ្ជាជីវៈមួយនេះពុំទាន់ត្រូវបានផ្សព្វផ្សាយឱ្យបានទូលំទូលាយនៅឡើយ។ ម្យ៉ាងវិញទៀតវត្តមានសារការីនៅកម្ពុជា ពុំទាន់មានបទបញ្ញត្តិជាក់លាក់ណាមួយជាការកំណត់ អំពីលក្ខន្តិកៈក្នុងការគ្រប់គ្រងវិជ្ជាជីវៈនេះនៅឡើយនោះទេ។ ចំពោះបញ្ហាសន្តតិកម្មវិញ វិជ្ជាជីវៈនេះទើបតែបានបញ្ចូលមុខងាររបស់សារការីក្នុងការសម្របសម្រួលនៅពេលដែលក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ចូលជាធរមានប៉ុណ្ណោះ។ ស្របពេលដែលសារការីបានលេចវត្តមាននៅក្នុងសន្តតិកម្មនេះឯង ការផ្សព្វផ្សាយពីវត្តមានសារការីទៅឱ្យសាធារណៈជនបានដឹងថាសារការីជានរណា ហើយសារការីមានតួនាទីអ្វីខ្លះ និងតាមរយៈការទទួលបានជំនួយពីសារការីទទួលបានផលប្រយោជន៍អ្វីខ្លះ នៅមានកម្រិតទាបនៅឡើយ។ ចំពោះវិជ្ជាជីវៈសារការីនេះផងដែរ បើយើងធ្វើការប្រៀបធៀបជាមួយនឹងបណ្តាវិជ្ជាជីវៈច្បាប់ផ្សេងទៀតដែលកំពុងអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងនោះសារការីជាអ្នកច្បាប់មួយរូប ដែលបានទទួលប្រតិភូកម្មអំណាចពីរាជរដ្ឋាភិបាល ដែលមានន័យរាល់លិខិតដែលធ្វើឡើងដោយសារការីមានអានុភាពអនុវត្តបានទូលំទូលាយ ទន្ទឹមនឹងនោះ វិជ្ជាជីវៈនេះទើបតែចាប់កំណើតនៅក្រោយសង្គ្រាម ដែលអាចនិយាយបានថាមានអាយុកាលតិចតួចបំផុត។ នេះជាមូលហេតុមួយដែលបង្កជាភាពលំបាកក្នុងការពន្យល់ណែនាំឱ្យមានការជ្រួតជ្រាបទៅដល់ពលរដ្ឋទូទាំងប្រទេស ជាពិសេសអំពីផលប្រយោជន៍ដែលសារការីអាចជួយប្រជាពលរដ្ឋ និងសង្គមក្នុងបញ្ហាសន្តតិកម្ម។ ក្នុងការអនុវត្តជាក់ស្តែង តាមរយៈរបាយការណ៍នៃស្តីពីការបណ្តុះបណ្តាលដល់សិស្សសារការីនៅកម្ពុជាចំនួនសារការីនៅកម្ពុជាក្នុងពេលបច្ចុប្បន្ននៅមានចំនួនតិចតួចនៅឡើយ។កម្ពុជាបច្ចុប្បន្នទើបតែបានបណ្តុះបណ្តាលសារការីពីរជំនាន់ប៉ុណ្ណោះ ដែលសារការីជំនាន់ទី២នឹងបញ្ចប់ការសិក្សាវគ្គបណ្តុះបណ្តាលសារការីនៅក្នុងពេលឆាប់ខាងមុខនេះ។ ម្យ៉ាងវិញទៀតនោះ ជាក់ស្តែងនៅប្រទេសកម្ពុជាបច្ចុប្បន្ន សារការីមានវត្តមាននៅក្នុងមន្ទីរសារការីនីមួយៗដែលមាននៅក្នុងទីក្រុងភ្នំពេញប៉ុណ្ណោះ ដោយនៅតាមបណ្តាលខេត្តនីមួយៗនៅក្នុងប្រទេសកម្ពុជាពុំទាន់មានវត្តមានសារការីនោះទេ។ វាជាបញ្ហាចោទដែលប្រជាជននៅតាមជនបទមិនអាចមានសារការីនៅជិតតំបន់ដែលខ្លួនបានរស់នៅ។ កាលពីសម័យសង្គមរាស្ត្រនិយមគេបង្កើតឱ្យមានមន្ទីរសារការីនៅតាមបណ្តាលខេត្តនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា កាលបង្កើតឱ្យមានសារការីនៅតាមខេត្តដូច្នេះធ្វើឱ្យការអនុវត្តមុខងារតាមច្បាប់របស់សារការីកាន់តែប្រសើរឡើង តាមរយៈតម្រូវការរបស់អតិថិជននៅក្នុងតំបន់របស់ខ្លួន។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈសម័យកាលជាច្រើនកន្លងមក យើងសង្កេតឃើញថាវត្តមានសារការី និងសន្តតិកម្មមានវត្តមានជាយូរណាស់មកហើយនៅក្នុងប្រព័ន្ធច្បាប់នៃប្រទេសកម្ពុជា ប៉ុន្តែការលេចវត្តមាននេះជារួមនៅក្នុងប្រព័ន្ធច្បាប់សម្រាប់ប្រទេសកម្ពុជា ដំបូងសារការីពុំមានតួនាទីក្នុងការបំពេញមុខងារនៅក្នុងបញ្ញត្តិស្តីពីសន្តិកម្មនោះទេ ដោយហេតុថាបញ្ញត្តិស្តីពីសន្តតិកម្មត្រូវបានអនុវត្តមុខងារដោយមន្ត្រីសារធារណៈដទៃទៀតជា មេឃុំ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួននីមួយៗ។ បន្ទាប់ពីការលុបចោលនូវប្រព័ន្ធច្បាប់ដែលមាននៅក្នុងប្រទេសកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ វត្តមានសារការី និងបញ្ញត្តិស្តីពីសន្តតិកម្មក៏ត្រូវបាត់បង់ទៅវិញ។ លុះដល់ឆ្នាំ២០០៧ តាមរយៈក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នេះតែម្តង វត្តមានសារការីបានលេចរូបរាងឡើងជាថ្មីម្តងទៀត ដែលវត្តមានជាថ្មីនេះបានធ្វើឱ្យវិជ្ជាជីវៈសារការី ចូលខ្លួនក្នុងការបំពេញតួនាទីនៅក្នុងរបបសន្តតិកម្មនៅកម្ពុជាបានគួរឱ្យកត់សម្គាល់ស្របទៅតាមគោលការណ៍ដែលបានកំណត់នៅក្នុងច្បាប់នៃប្រទេសកម្ពុជា។ តាមរយៈការអនុវត្តមុខងាររបស់សារការីនៅក្នុងបញ្ហាសន្តតិកម្ម សារការីបំពេញតួនាទីរបស់ខ្លួនតាមការកំណត់របស់ច្បាប់ ហើយគ្រប់ការទទួលបានការងារនៅក្នុងការអនុវត្តសន្តតិកម្ម សារការីត្រូវទទួលបានការពឹងពាក់ពីជន ដែលជាប់ទាក់ទងនៅក្នុងសន្តតិកម្មជាមុនសិន តួយ៉ាងដូចជា មតកជន សន្តតិជន និងជនដទៃផ្សេងទៀតដែលមានផលប្រយោជន៍នៅក្នុងសន្តតិកម្ម។ តាមរយៈមុខងារដែលបានផ្តល់ឱ្យសារការីជាមន្ត្រីសាធារណៈ ដែលធ្លាប់ឆ្លងកាត់នូវវគ្គបណ្តុះបណ្តាលជាច្រើនមុនឈានចូលជាបេក្ខជន ដែលអាចមានសមត្ថភាពក្នុងការប្រឡងប្រជែងជ្រើសជាសារការីបាន រួមទាំងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ លើសពីនេះទៅទៀតដោយក្រឡេកឃើញថាការអនុវត្តនូវមុខងាររបស់សារការីនៅក្នុងសន្តតិកម្មនេះបានដំណើរការរលូន និងទាញបាននូវផលប្រយោជន៍ជាច្រើនចំពោះភាគីពាក់ព័ន្ធខាងលើ។

យោងតាមការប្រមូលបាននូវខ្លឹមសារនៃការរៀបរាប់ខាងលើ សារការីក្នុងសន្តតិកម្មមានភារកិច្ចជាច្រើនដែលអ្នកសិក្សាមួយចំនួនមិនទាន់បានយល់ជ្រួតជ្រាបដែលនេះជាការបំពេញបន្ថែម ពិសេសការបង្ហាញដោយផ្អែកនៅលើមូលដ្ឋានច្បាប់ជាគោល ហេតុមនេះហើយការប្រើប្រាស់បាននូវបទបញ្ញត្តិដែលបានកំណត់គឺមានសារៈសំខាន់ពោលគឺមាន ព្រះរាជក្រឹត្យ៩១០ នស ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤/ អនុក្រឹត្យ ៥០៥ អនក្រ.តត ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០១/ អនុក្រឹត្យ ១៨៤ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨/ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧/ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី/ ច្បាប់ភូមិបាល និងឯកសារមួយចំនួនទៀតដែលបានលើកយកមកបង្ហាញជាអំណះអំណាង។

ដោយសារសារការីជាមន្ត្រីអនុវត្តច្បាប់ក្នុងចំណោមអ្នកច្បាប់ជាច្រើនរូប ដែលកំពុងមានការចាប់អារម្មណ៍ពីមជ្ឈដ្ឋានជុំវិញ ពិសេសការធ្វើសន្តតិកម្មដែលបានផ្តល់នូវជំនឿជាក់យ៉ាងរឹងមាំ និងការផ្តល់នូវអានុភាព

គតិយុត្តនោះគឺលិខិតមតកសាសន៍ ដែលមានតម្លៃស្មើនឹងសាលក្រមនៃសេចក្តីសម្រេច ឬសាលដីការបស់តុលាការ មានអានុភាពអនុវត្តតាំងពីថ្ងៃ ខែ ឆ្នាំនៃការបង្កើតដោយសារការីលើកដំបូងនោះមកម្ល៉េះ ពោលគឺមិនឆ្លងកាត់នូវនីតិវិធីរបស់តុលាការដែលពេលខ្លះនាំមកនូវភាពយឺតយូរ និងការខាតបង់ពេលវេលាក៏ដូចជាប្រាក់កាសបើផ្អែកលើគោលការណ៍ច្បាប់ សារការីអាចជាជំនួយការដ៏មានប្រសិទ្ធិភាពព្រោះថា ពេលស្ថិតក្នុងស្ថានភាពមួយដែលអតិថិជនបានពឹងទៅលើការតាក់តែង ឬការចាត់ចែងចំពោះមត៌កមានន័យថាសារការីជាសាក្សីម្នាក់ ជាអ្នកប្រឹក្សាច្បាប់ដ៏មានប្រសិទ្ធិភាព មិនត្រឹមតែប៉ុណ្ណោះសារការីក៏ជាអ្នករែកញែកថាគួរតែមានដំណោះស្រាយបែបណាឱ្យភាគីទាំងឡាយអាចទទួលយកបានចំពោះការប្រតិបត្តិមតកសាសន៍នេះតាមបំណងប្រាថ្នា ដែលអ្វីៗទាំងនេះ គឺជាផលប្រយោជន៍នៃមុខងារចំពោះការផ្តល់ជាការប្រឹក្សាផ្លូវច្បាប់ជុំវិញបញ្ហាសន្តតិកម្ម។

ដូច្នេះ ការប្រតិបត្តិមុខងារសារការីក្នុងសន្តតិកម្មមានអានុភាព និង អត្ថប្រយោជន៍ជាច្រើនដែលមិនត្រឹមតែបម្រើចំពោះតួនាទីជាសារការីប្រកបដោយសុក្រឹតភាព អព្យាក្រិត្យ និងយុត្តិធម៌ប៉ុណ្ណោះទេ ចំណែកឯអតិថិជនខ្លួនក៏មានភាពជឿជាក់ចំពោះសេវាកម្មផ្នែកច្បាប់មួយនេះចំពោះការពង្រឹងស្ថានភាពគតិយុត្តផងដែរ។ ម្យ៉ាងវិញទៀត នៅក្នុងការអនុវត្តនេះបង្ហាញពីការរៀបចំសណ្តាប់ធ្នាប់នៃការគោរពច្បាប់មិនឱ្យមានការបំពានពីភាគីណាមួយដោយមិនបានយល់ដឹងអំពីមូលដ្ឋានច្បាប់នោះឡើយ។

ដូចដែលបានអធិប្បាយខាងលើ ទោះបីជាមានការចាប់កំណើតបានរយៈពេលប៉ុន្មានឆ្នាំកន្លងមកហើយក៏ដោយ ក៏យើងសង្កេតឃើញថាសារការីក្នុងបញ្ហាសន្តតិកម្មនៅពុំទាន់មានវិសាលភាពទូលំទូលាយនៅឡើយទេពីសំណាក់អ្នកសិក្សា និងប្រជាពលរដ្ឋទាំងមូល ដែលមូលហេតុនេះនៅមិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការចំពោះសារការីនៅឡើយក្នុងប្រព័ន្ធសន្តតិកម្ម ម្យ៉ាងក៏មិនទាន់មានច្បាប់ស្តីពីលក្ខន្តិកៈនៃសារការីដែលនេះជាបញ្ហាមួយកំពុងតែត្រូវរកដំណោះស្រាយជាចម្បង។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានបញ្ចប់នូវសារណាក្រោមប្រធានបទ សារៈប្រយោជន៍សារការីនៅក្នុងបញ្ហាសន្តតិកម្ម រួចមកយើងខ្ញុំក៏បានមើលឃើញពីបញ្ហាមួយចំនួន ហើយពួកយើងខ្ញុំក៏សូមបញ្ចេញមតិទៅលើចំណុចខ្វះខាតមួយចំនួនដែលពួកយើងមើលឃើញនៅក្នុងប្រធានបទមួយនេះ ដែលចំណុចទាំងនោះរួមមាន៖

- នៅពេលបច្ចុប្បន្នវិជ្ជាជីវៈសារការីកំពុងតែមានវត្តមានក្នុងការបំពេញមុខងារនៅក្នុងបញ្ញត្តិស្តីពីសន្តតិកម្ម ដោយរយៈពេលកន្លងមកប្រជាពលរដ្ឋទូទៅ គឺមិនបានដឹងអំពីមុខងារមួយនេះទេ រយៈពេលកន្លងមកមានទំនាស់ជាច្រើននៅក្នុងគ្រួសារដែលបណ្តាលមកពីការដណ្តើមទ្រព្យសម្បត្តិ ដូច្នេះប្រជាពលរដ្ឋមួយចំនួនមិនដឹងថា តើគួរធ្វើយ៉ាងណាដើម្បីឱ្យបញ្ហាមួយនេះដោះស្រាយបានដោយរលូននោះទេ នេះហើយជាមូលហេតុដែលតម្រូវឱ្យមានការផ្សព្វផ្សាយតាមរយៈអ្នកសិក្សា និងអ្នកច្បាប់ ពិសេសអ្នកវិជ្ជាជីវៈមួយចំនួនដោយការបង្កើតឱ្យមានជាសិក្ខាសាលា កម្មវិធីស្វែងយល់អំពីផ្លូវច្បាប់តាមទូរទស្សន៍ ឬវិទ្យុ ក៏ដូចជាបណ្តាញផ្សព្វផ្សាយនានាធ្វើយ៉ាងណាឱ្យប្រព័ន្ធច្បាប់មានលក្ខណៈអាចទទួលយកបានប្រកបដោយប្រសិទ្ធិភាព។
- ម្យ៉ាងវិញទៀត ទោះបីជាកម្ពុជាមានវត្តមានសារការីនៅក្នុងការជួយសម្រួលនៅក្នុងសន្តតិកម្មក្តី ប៉ុន្តែចំនួនវត្តមានសារការីនៅក្នុងប្រទេសកម្ពុជា ហាក់បីដូចជាមិនទាន់គ្រប់គ្រាន់សម្រាប់តម្រូវការជាក់ស្តែងរបស់ប្រជាជននៅឡើយនោះទេ បើយើងក្រឡេកទៅមើលបច្ចុប្បន្នភាពរបស់សារការីនៅកម្ពុជានៅប្រទេសកម្ពុជាបច្ចុប្បន្ន មន្ទីរសារការីមានទីតាំងស្ថិតនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ចំពោះនៅតាមបណ្តាខេត្តវិញមិនទាន់មាននោះទេ ដែលនេះជាបញ្ហាមួយសម្រាប់ប្រជាជននៅតាមបណ្តាខេត្តដែលមានបំណងឱ្យសារការីជួយជាអន្តរាគមន៍នៅក្នុងបញ្ហាសន្តតិកម្ម ប្រសិនណាបើគាត់ចង់ឱ្យសារការីជួយសម្រួលបញ្ហានៅក្នុងសន្តតិកម្ម គាត់ត្រូវចំណាយពេលវេលា និងថវិកាច្រើនដើម្បីមករកសារការីនៅឯទីក្រុងភ្នំពេញ ដូច្នេះរដ្ឋគួរតែបង្កើតឱ្យមានមន្ទីរសារការីនៅតាមបណ្តាខេត្តដើម្បីជួយសម្រួលពីបញ្ហានេះព្រោះកន្លងមកនៅក្នុងសម័យអាណានិគមនិយមបារាំងការបង្កើតឱ្យមានសារការីជាលើកដំបូង រដ្ឋបានបង្កើតឱ្យមានសារការីនៅតាមតំបន់នៃខេត្តមួយចំនួន ដើម្បីជាការជួយសម្រួលបញ្ហាការចំណាយថវិកា និងពេលវេលាជូនប្រជាពលរដ្ឋនៅតាមបណ្តាលខេត្ត។
- បច្ចុប្បន្នកម្ពុជាមានសារការីជាច្រើន បានអនុវត្តការងាររបស់ខ្លួននៅតាមមន្ទីរសារការីជាច្រើននៅទីក្រុងភ្នំពេញ ទន្ទឹមនឹងការអនុវត្តមុខងាររបស់សារការីកម្ពុជាមិនទាន់មានបទដ្ឋានគតិយុត្តដែលរឹងមាំក្នុងការត្រួតពិនិត្យមុខងាររបស់សារការីនៅតាមមន្ទីរសារការីនីមួយៗនៅក្នុងប្រទេសកម្ពុជានៅឡើយទេ។ ដូច្នេះ

រដ្ឋគួរតែបង្កើតឱ្យមានច្បាប់លក្ខន្តិកៈសារការី ដើម្បីត្រួតពិនិត្យមុខងាររបស់សារការីឱ្យបានឆាប់រហ័សជាងនេះ។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមធ្វើការបង្ហាញពីទឹកចិត្តក្នុងការត្រួសត្រាយផ្លូវ ក៏ដូចជាសំណូមពរដល់ស្ថាប័នតុលាការ ពិសេសប្រជាពលរដ្ឋក្នុងព្រះរាជាណាចក្រកម្ពុជា ចូលរួមអនុវត្ត និងលើកតម្កើងប្រព័ន្ធច្បាប់ក្នុងប្រទេសរបស់ខ្លួនឱ្យមានដំណើរការរលូនទៅមុខឥតដាច់។ ម្យ៉ាងវិញទៀត អាចធានាបានថាសារការីនឹងបន្តកិច្ចការរបស់ខ្លួនឱ្យមានភាពយុត្តិធម៌ ប្រកបដោយគុណប្រយោជន៍ដល់ភាគី ពិសេសចូលរួមផ្សព្វផ្សាយឱ្យបានច្រើនតាមដែលអាចធ្វើទៅបានដល់សាធារណៈជន ចៀសវាងការទទួលបាននូវភាពមិនសមបំណង មិនយល់ពីផ្លូវច្បាប់ ដែលនាំឱ្យប្រទេសរបស់យើងកាន់តែឱនភាពប្រាសចាកពីវឌ្ឍនភាព។ យើងខ្ញុំសូមអរគុណយ៉ាងជ្រាលជ្រៅពីសំណាក់អ្នកសិក្សាពីគ្រប់មជ្ឈដ្ឋានដែលបានធ្វើការយកចិត្តទុកដាក់ តាមដានចំពោះការធ្វើការអធិប្បាយក្នុងប្រធានបទខាងលើនេះយ៉ាងប្រសើរ តាំងពីកិច្ចចាប់ផ្តើមនៃប្រធានបទរហូតឈានមកដល់សេចក្តីបញ្ចប់នេះផងដែរ។ យើងខ្ញុំសង្ឃឹមថាសារណាមួយនេះនឹងបានផ្តល់ជាចំណេះដឹងបន្ថែម ពិសេសបំពេញនូវចំណុចដែលពាក់ព័ន្ធ ស្តីពីការធ្វើសន្តតិកម្មពីមួយដំណាក់កាលទៅមួយដំណាក់កាលដោយសារការីដែលការធ្វើបែបនេះមានផលប្រយោជន៍បែបណា ពីការធ្វើតាមទំនៀមទម្លាប់មិនមានអំណះអំណាងច្បាស់លាស់ដែលមិត្តអ្នកអាន និងអ្នកសិក្សាបានដឹងពីមុនបន្ថែមទៀត។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- ព្រះរាជក្រមលេខ ៩១០ នស. ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ ១៩៥៤
- ព្រះរាជក្រឹត្យលេខ ១២៩.ប.រ. ចុះថ្ងៃទី១៨ មីនា គ.ស.១៩៦៥ ឆ្នាំ ១៩៦៥
- ក្រមរដ្ឋប្បវេណីចាស់ ១៩២០
- ក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីនៅចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១
- ច្បាប់ភូមិបាលឆ្នាំ ១៩៩២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២
- ច្បាប់ភូមិបាល២០០១ ចុះនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១១
- ច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ប្រកាសអោយប្រើនៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០៧
- អនុក្រឹត្យលេខ ៥០៥ អនក្រ.គត. ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០១

## សៀវភៅ និងអត្ថបទផ្សេងៗ

- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី គន្ថីទី៨ ‶សន្តតិកម្ម″ ជំពូកទី៣″សន្តតិកម្មតាមមតកសាសន៍
- សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ៦
- សន្ទានុក្រមនីតិវិធីរដ្ឋប្បវេណី
- វចនានុក្រមខ្មែរ សម្តេចសង្ឃរាជ **ជួនណាត**
- សិក្ខាសាលាស្តីពី ‶វិជ្ជាជីវៈសារការីនៃព្រះរាជាណាចក្រកម្ពុជា″ នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៨ ដោយសារការី នៅ សុជាតា និង សារការី កាន់ សុទ្ធប៉ូលីន
- សិក្ខាសាលាស្តីពី ‶សារៈសំខាន់នៃលិខិតយថាភូត″ ដោយលោកស្រីសារការី មិន្ទសុំ សូលីដា ជាសារការីនៅមន្ទីរសារការីភ្នំពេញ (website:www.ppnp.com.kh)
- សិក្ខាសាលាស្តីពី ‶លិខិតយថាភូត″ (សាកាណុស អ៊ីសសេ ទីប្រឹក្សាអមក្រសួងយុត្តិធម៌ issei-j@msj.biglobe.ne.jp

- សមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ "Research and Promotion Khmer law Asscosiation" បទបង្ហាញស្តីពីវិជ្ជាជីវៈសារការី ដោយកញ្ញា ជឹង ស្រីតូច សិស្សសារការីជំនាន់១ កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៦
- Pheakdeylaw.com/Kh/Publication/84

## គេហទំព័រ

- គេហទំព័ររាជបណ្ឌិតសភា វិជ្ជាជីវៈតុលាការ,សាលាភូមិន្ទសារការ

  http://rajp.gov.kh/Notary.html ។

# ឧបសម្ព័ន្ធ